ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# យុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ នៅកម្ពុជា ២០២៥-២០៣០

ឆ្នាំ ២០២៥

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រជាតិ
# ស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ
# នៅកម្ពុជា
# ២០២៥-២០៣០

មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
កម្មវិធីជាតិសុខភាពបន្តពូជ

ឆ្នាំ២០២៥

# បុព្វកថា

ការប្ដេជ្ញាចិត្តរបស់ក្រសួងសុខាភិបាលចំពោះសុខុមាលភាពរបស់ប្រជាពលរដ្ឋជាពិសេស ក្នុងវិស័យថែទាំសុខភាពប្រកបដោយគុណភាពខ្ពស់ បានប្រព្រឹត្តទៅយ៉ាងខ្ជាប់ខ្ជួន។ យុទ្ធសាស្ត្រនេះ គឺជាសក្ខីភាពមួយចំពោះការយកចិត្តទុកដាក់របស់យើងក្នុងការធានាថាបុគ្គលគ្រប់រូបនៅក្នុងប្រទេស មានលទ្ធភាពទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជគ្រប់ជ្រុងជ្រោយ ហើយសិទ្ធិរបស់ពួកគេក្នុងវិស័យនេះត្រូវបានរក្សា និងគោរព។

សមិទ្ធផលដែលយើងសម្រេចបានរហូតមកដល់ពេលនេះ ក្នុងការកែលម្អសុខភាពផ្លូវភេទសុខភាពបន្តពូជ សុខភាពមាតា ទារកទើបនឹងកើត និងកុមារមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់។ សកម្មភាពរបស់យើងគឺមានភាពសមស្របទៅនឹងក្របខ័ណ្ឌជាតិ និងអន្តរជាតិសំខាន់ៗ រួមទាំងយុទ្ធសាស្ត្របញ្ចកោណរបស់រដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ផែនការយុទ្ធសាស្ត្រសុខាភិបាល និងផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក(FTIRM)។

យុទ្ធសាស្ត្រនេះ គឺស្របតាមការប្ដេជ្ញាចិត្ត របស់យើងដែលបានធ្វើឡើងនៅក្នុងសន្និសីទអន្តរជាតិ ស្ដីពីប្រជាជន និងការអភិវឌ្ឍន៍ (ICPD) នៅទីក្រុងណៃរ៉ូប៊ី ក្នុងឆ្នាំ២០១៩ ដើម្បីសម្រេចបាននូវលទ្ធផលផ្លាស់ប្ដូរចំនួនបីនៅឆ្នាំ២០៣០៖ ការលុបបំបាត់ការស្លាប់មាតាដែលអាចការពារបាន ការបំពេញតម្រូវការផែនការគ្រួសារទាំងអស់ ការលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ និងការអនុវត្តដែលបង្កគ្រោះថ្នាក់។ យុទ្ធសាស្ត្រនេះ ក៏ជាផ្នែកមួយដ៏សំខាន់ នៃផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល និងផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកលនៅកម្ពុជា និងការថែទាំសុខភាពបឋម។

យុទ្ធសាស្ត្រជាតិ ស្ដីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ ឆ្នាំ២០២៥-២០៣០ នឹងក្លាយជាត្រីវិស័យណែនាំយើងឆ្ពោះទៅរកភាពប្រសើរឡើង បន្ថែមទៀតសម្រាប់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេសកុមារី និងស្ត្រីហើយទន្ទឹមនឹងការធានាថាគ្មាននរណាម្នាក់ត្រូវបានទុកចោល ស្ត្រី និងកុមារីបានអនុវត្តសិទ្ធិរបស់ពួកគេក្នុងការទទួលបានសិទ្ធិផ្លូវភេទ សុខភាពបន្តពូជ និងសុខុមាលភាពនៅឆ្នាំ២០៣០។

យើងមានឱកាសចូលរួមទាំងអស់គ្នា ដើម្បីជួយប្រជាជនកម្ពុជាឱ្យទទួលបាននូវសមធម៌ និងសុខភាពល្អប្រសើរ។

ថ្ងៃពុធ ៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ០៤ ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាង រ៉ា**

# សេចក្តីថ្លែងអំណរគុណ

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណដល់ **លោកជំទាវសាស្ត្រាចារ្យ អ៊ឹម សិទ្ធិការ្យ** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការសម្របសម្រួលក្នុងការពង្រឹងគុណភាពថែទាំ ព្យាបាលសុខុមាលភាពមាតា ទារក កុមារ និងរោគស្ត្រី ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំក្នុងដំណើរការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិឆ្នាំ២០២៥-២០៣០។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណចំពោះ កម្មវិធីជាតិសុខភាពបន្តពូជ នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងភាគីពាក់ព័ន្ធទាំងអស់ ចំពោះការរួមចំណែកដ៏មានតម្លៃក្នុងការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិនៅកម្ពុជា ឆ្នាំ២០២៥-២០៣០។ យើងសូមថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅចំពោះការប្តេជ្ញាចិត្តដ៏មុតមាំ និងការចូលរួម យ៉ាងសកម្មរបស់មន្ត្រីរាជការ និងដៃគូអភិវឌ្ឍន៍ទាំងអស់នៅក្នុងដំណើរការនេះ។

លើសពីនេះសូមថ្លែងអំណរគុណដល់ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ដែលបានផ្តល់ទាំងបច្ចេកទេស និងថវិកាក្នុងដំណើរការអភិវឌ្ឍន៍ និងបោះពុម្ពនូវយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ។

# មាតិកា


បុព្វកថា ....................................................................................2

សេចក្ដីថ្លែងអំណរគុណ ....................................................................................3

បញ្ជីរាយនាមក្រុមការងារគ្រប់គ្រង និងដឹកនាំធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រជាតិស្ដីពីសុខភាពផ្លូវភេទ សុខភាពបន្ដពូជ និងសិទ្ធ ២០២៥-២០៣០....................................................................................6

អក្សរកាត់ និងពាក្យកាត់....................................................................................8

1.មាត្រដ្ឋាន នៃបញ្ហាប្រឈម ....................................................................................10

1.1ការវិភាគស្ថានភាព និងវឌ្ឍនភាពដែលសម្រេចបាន ....................................................................................10

1.2កត្តាសំខាន់ៗដែលជះឥទ្ធិពលដល់សុខភាពផ្លូវភេទ សុខភាពបន្ដពូជ និងសិទ្ធ )SRHR( នៅកម្ពុជា..13

ការផ្សារភ្ជាប់ និងធ្វើឱ្យសមស្រប 1.3....................................................................................22

2.វិធីសាស្ត្រអភិវឌ្ឍន៍យុទ្ធសាស្ត្រ....................................................................................23

3.ចក្ខុវិស័យជាយុទ្ធសាស្ត្រ គោលការណ៍ កត្តាជំរុញល្បឿន និងអាទិភាព ....................................................................................26

គោលដៅយុទ្ធសាស្ត្រ 3.1....................................................................................26

3.2 គោលការណ៍ណែនាំ....................................................................................26

កត្តាជ 3.3ំរុញល្បឿន នៃផលប៉ះពាល់ ....................................................................................33

អាទិភាពជាយុទ្ធសាស្ត្រ 3.4....................................................................................35

4.តំបន់អន្តរាគមន៍តាមអាទិភាពជាយុទ្ធសាស្ត្រ ....................................................................................36

អាទិភាពជាយុទ្ធសាស្ត្រ ១. ធ្វើឱ្យប្រសើរឡើងនូវភាពអាចរកបាន ប្រសិទ្ធភាព សុវត្ថិភាព និងការផ្ដោតលើប្រជាជន នៃព័ត៌មាន និងសេវាកម្មរបស់ SRHR ។....................................................................................36

អាទិភាពជាយុទ្ធសាស្ត្រ ២. លើកកម្ពស់ការដាក់បុគ្គលិកសុខាភិបាលឱ្យបម្រើការងារក្នុងការផ្ដល់ព័ត៌មាន និងសេវារបស់ SRHR ។....................................................................................41

អាទិភាពជាយុទ្ធសាស្ត្រ ៣. ធ្វើឱ្យប្រសើរឡើងនូវសមាហរណកម្មសេវា និងការបញ្ជូនបន្តដើម្បីធានាបានភាពទាន់ពេលវេលា លទ្ធភាពទទួលបានសេវា SRHR គ្រប់ជ្រុងជ្រោយប្រកបដោយសមធម៌ នៅគ្រប់កម្រិត នៃការថែទាំ ....................................................................................46

អាទិភាពជាយុទ្ធសាស្ត្រ ៤. ដោះស្រាយបទដ្ឋានសង្គម និងយេនឌ័រ គោលនយោបាយ និងការអនុវត្ត ដែលបង្គ្រោះថ្នាក់ តាមរយៈការពង្រឹងអភិបាលកិច្ច និងការផ្ដល់សេវា SRHR ....................................................................................48

អាទិភាពជាយុទ្ធសាស្ត្រ៥. ផ្តល់អាទិភាពដល់ភាពជាម្ចាស់របស់សហគមន៍ ការចូលរួមជាមួយប្រព័ន្ធសុខាភិបាល និងការឆ្លើយតបដើម្បីពង្រឹងការផ្តត់ផ្គង់ និងតម្រូវការសេវា SRHR ........................................................52
អាទិភាពជាយុទ្ធសាស្ត្រ ៦. ដកចេញនូវឧបសគ្គផ្នែកហិរញ្ញវត្ថុ ក្នុងការចូលប្រើសេវាថែទាំសុខភាពឆ្ពោះទៅរកការសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល (UHC)............................................................56
អាទិភាពជាយុទ្ធសាស្ត្រ ៧. ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានផលិតផល និងបច្ចេកវិទ្យាវេជ្ជសាស្ត្រ.60
អាទិភាពជាយុទ្ធសាស្ត្រ ៨. លើកកម្ពស់ និងពង្រឹងទិន្នន័យសម្រាប់ការស្រាវជ្រាវ ការច្នៃប្រឌិត ការត្រួតពិនិត្យ និងការរៀនសូត្រ ...............................................................................................................63
អាទិភាពជាយុទ្ធសាស្ត្រ ៩. ជំរុញអភិបាលកិច្ចប្រកបដោយបរិយាបន្ន និងជំរុញភាពជាដៃគូ...............66
ឧបសម្ព័ន្ធទី១ ៖ ក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃ ............................................................................70

# បញ្ជីរាយនាមក្រុមការងារគ្រប់គ្រង និងដឹកនាំធ្វើបច្ចុប្បន្នភាពយុទ្ធសាស្រ្តជាតិស្តីពី សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធ ២០២៥-២០៣០

| | | |
|---|---|---|
| ១. លោកជំទាវសាស្ត្រាចារ្យ | **អ៊ឹម សិទ្ធិភារៀ** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ២. ឯកឧត្តមសាស្ត្រាចារ្យ | **គុំ ភាណារ៉ាល់** | ទីប្រឹក្សាក្រសួងសុខាភិបាលសមាជិកសមាគម សម្ភព និងរោគស្ត្រី |
| ៣. លោកជំទាវសាស្ត្រាចារ្យ | **ឧុង វដ្ឋាទី** | ទីប្រឹក្សាក្រសួងសុខាភិបាល |
| ៤. លោកស្រីសាស្ត្រាចារ្យជំនួយ | **គីម វត្តនា** | នាយកមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| ៥. លោកស្រីវេជ្ជបណ្ឌិត | **សៀង លំអងគន្ធា** | ប្រធានកម្មវិធីជាតិសុខភាពបន្តពូជ |
| ៦. លោកវេជ្ជបណ្ឌិត | **សុខ សុគន្ធ** | អង្គការ UNFPA |
| ៧. លោកស្រីវេជ្ជបណ្ឌិត | **ជាង កន្និដ្ឋា** | អង្គការ WHO |
| ៨. លោកស្រី | Chloe Denavit | អ្នកសម្របសម្រួល |
| ៩.លោក | **ខួន ប្រុស** | អង្គការ UNFPA |

១០. មន្ត្រីកម្មវិធីជាតិស្តីពីសុខភាពបន្តពូជ (NRHP)

១១. មន្ត្រីកម្មវិធីជាតិអាហារូបត្ថម្ភ (NNP)

១២. មន្ត្រីកម្មវិធីជាតិផ្តល់ថ្នាំបង្ការ (NIP)

១៣. មន្ត្រីកម្មវិធីជាតិប្រយុទ្ធនឹងជំងឺរលាកផ្លូវដង្ហើមស្រួច រាក និងអាសន្នរោគ ស.ព.ជ.ក (ARI-CDD-IMCI)

១៤. មន្ត្រីកម្មវិធីជាតិបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ( PMTCT)

១៥. មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

១៦. មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព

១៧. មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

១៨. នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង

១៩. ឃ្លាំងឱសថកណ្តាល

២០. នាយកដ្ឋានមន្ទីរពេទ្យ

២១. នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល

២២. នាយកដ្ឋានសុខភាពផ្លូវចិត្ត

២៣. ក្រសួងកិច្ចការនារី

២៤. ក្រសួងអប់រំ៖ នាយកដ្ឋានសុខភាពនៅតាមសាលារៀន

## អក្សរកាត់ និងពាក្យកាត់

| | |
|---|---|
| AFSRH | សុខភាពផ្លូវភេទ និងសុខភាពបន្តពូជយុវវ័យ ប្រកបដោយមិត្តភាព |
| ANC | ការថែទាំផ្ទៃពោះមុនសម្រាល |
| ART | ការព្យាបាលដោយថ្នាំប្រឆាំងនឹងមេរោគ |
| BEmONC | ការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបនឹងកើត កម្រិតមូលដ្ឋាន |
| BNM | បរិញ្ញាបត្រគិលានុបដ្ឋាយិកា និងឆ្មប |
| CAC | ការថែទាំរំលូតដោយសុវត្ថិភាព |
| CBD | អ្នកចែកចាយមធ្យោបាយពន្យារកំណើតតាមសហគមន៍ |
| CBE | ការអប់រំផ្អែកលើសមត្ថភាព |
| CEmONC | ការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបនឹងកើត ពេញលេញ |
| CPA | សំណុំសកម្មភាពបង្គ្រប់ |
| CPR | អត្រាប្រេវ៉ាឡង់ពន្យារកំណើត |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| EmONC | សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបនឹងកើត |
| FP | ផែនការគ្រួសារ |
| FTIRM | ផែនទីចង្អុលផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណមាតា និងទារក |
| GBV | អំពើហិង្សាផ្អែកលើយេនឌ័រ |
| GMAG | ក្រុមការងារបញ្ជ្រាបយេនឌ័រ នៃក្រសួងសុខាភិបាល |
| HC | មណ្ឌលសុខភាព |
| HCMC | គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព |
| HEF | មូលនិធិសមធម៌សុខភាព |
| MoH | ក្រសួងសុខាភិបាល |
| MPA | សំណុំសកម្មភាពអប្បបរមា |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NIP | កម្មវិធីជាតិផ្តល់ថ្នាំបង្ការ |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| NRHP | កម្មវិធីជាតិសុខភាពបន្តពូជ |
| NMCHC | មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| NSSRHR | យុទ្ធសាស្ត្រជាតិស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ |
| NSDP | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម |
| NQEM | យន្តការជាតិលើកកម្ពស់គុណភាព |
| OD | ការិយាល័យស្រុកប្រតិបត្តិ |
| PAC | ការថែទាំក្រោយរំលូត |
| PMTCT | ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន |
| RoGC | រាជរដ្ឋាភិបាលកម្ពុជា |
| RHAC | អង្គការថែទាំសុខភាពគ្រួសារកម្ពុជា |
| RMNCH | សុខភាពបន្តពូជ មាតា ទារក និងកុមារ |
| PNC | ការថែទាំក្រោយសម្រាល |
| PPH | ការធ្លាក់ឈាមក្រោយសម្រាល |
| SBA | ការសម្រាលកូនដោយបុគ្គលិកជំនាញ |

| | |
|---|---|
| H-EQIP | គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខភាព |
| HIV | វីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ |
| HMIS | ប្រព័ន្ធព័ត៌មានសុខាភិបាល |
| HPV | មេរោគ HPV |
| HRD | នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស |
| ICPD | សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍ប្រជាជន |
| LAPM | វិធីសាស្ត្របញ្ឈប់កំណើតអចិន្ត្រៃយ៍ |
| LARC | មធ្យោបាយពន្យារកំណើតរយៈពេលវែង |
| LGBTQI+ | ស្ត្រីស្រលាញ់ភេទដូចគ្នា បុរសស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ភេទដូចគ្នា អ្នកប្តូរភេទ Queer ឬ Intersex និងការកំណត់អត្តសញ្ញាណខ្លួនឯងផ្សេងទៀត |
| LMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងភស្តុភារ |
| MA | ការរំលូតកូនដោយឱសថ |
| MCAT | ក្រុមសម្របសម្រួលសម្ព័ន្ធធ្មប |
| MVA | ការរំលូតកូនដោយឧបករណ៍បូមដោយដៃ |
| MCH | សុខភាពមាតា និងទារក |
| MDA | ការអង្កេតមរណភាពមាតា |
| MgSO4 | ម៉ាញ៉េស្យូមស៊ុលហ្វាត |
| MMR | អត្រាមរណមាតា |
| SBCC | ទំនាក់ទំនងសម្រាប់ផ្លាស់ប្តូរសង្គម និងឥរិយាបថ |
| SMP | ពិធីសារជាតិគ្រប់គ្រងគ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់ |
| SOGIE | និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ |
| SRHR | សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ |
| TWG | ក្រុមការងារបច្ចេកទេស |
| UHS | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| UN | អង្គការសហប្រជាជាតិ |
| UNFPA | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| VAC | អំពើហិង្សាលើកុមារ |
| VAW | អំពើហិង្សាលើស្ត្រី |
| VHSG | ក្រុមទ្រទ្រង់សុខភាពភូមិ |
| VIA | ការត្រួតពិនិត្យមើលឃើញដោយអាស៊ីតអាសេទិក |
| WHO | អង្គការសុខភាពពិភពលោក |

# 1. មាត្រដ្ឋាន នៃបញ្ហាប្រឈម

## 1.1 ការវិភាគស្ថានភាព និងវឌ្ឍនភាពដែលសម្រេចបាន

យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ ២០២១-២០២២ អត្រាមរណភាពមាតាត្រូវបានប៉ាន់ប្រមាណថាមានចំនួនស្លាប់ ១៥៤ នាក់ក្នុង ១០០ ០០០ កំណើតរស់ លើសពីមធ្យមភាគនៃតំបន់ដែលមានចំនួនស្លាប់ត្រឹម ១៤០ នាក់ក្នុងឆ្នាំ២០១៩ [1]។ ស្ថានភាពនៃការស្លាប់ទារកមានភាពប្រសើរឡើង ដោយអត្រា នៃការស្លាប់បានថយចុះពីចំនួន ២៨នាក់មកនៅត្រឹម ១២នាក់ក្នុង ១០០០ កំណើតរស់ ហើយអត្រាមរណភាពកុមារក៏មានភាពប្រសើរឡើងដែរ ដោយថយចុះពីចំនួន ២០នាក់ ទៅ ១១ នាក់ក្នុង ១០០០ កំណើតរស់ នៅចន្លោះឆ្នាំ ២០១៤ និង ២០២១-២០២២ ដែលនេះបានឆ្លុះបញ្ចាំងពីសមិទ្ធផលជាច្រើនក្នុងវិស័យសុខាភិបាលកម្ពុជា។[2]

ប្រទេសកម្ពុជា ជាប់ចំណាត់ថ្នាក់ទីមួយក្នុងចំណោមបណ្តាប្រទេសអាស៊ីប៉ាស៊ីហ្វិកទាំងអស់ក្នុងគោលនយោបាយពន្យារកំណើត Atlas ដោយសម្រេចបានពិន្ទុ ៩០,១% លើមាត្រដ្ឋានសម្រាប់ការតាមដានប្រទេសនានាលើគោលនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងសិទ្ធិទទួលបាន វិធីពន្យារកំណើត។ ៦២% នៃស្ត្រីរៀបការរួចដែលមានអាយុពី ១៥-៤៩ ឆ្នាំ ប្រើប្រាស់វិធីពន្យារកំណើត ប៉ុន្តែមានតែស្ត្រី ៤៥% ប៉ុណ្ណោះដែលប្រើប្រាស់វិធីទំនើបៗ ស្ត្រីនៅទីជនបទ (៤៧%) ប្រើប្រាស់ច្រើនជាងអ្នករស់នៅក្នុងទីក្រុង (៤១%)។ ភាគរយនៃស្ត្រីរៀបការរួច និងមិនទទួលបានតម្រូវការក្នុងការធ្វើផែនការគ្រួសារ បានធ្លាក់ចុះពី ១២,៥% ក្នុងឆ្នាំ២០១៤ មកត្រឹម ១១,៥% ក្នុងឆ្នាំ ២០២១-២០២២។ ខណៈពេលនេះគឺជាការវិវឌ្ឍន៍ដ៏សំខាន់គួរឱ្យកត់សម្គាល់ គេឃើញថាគោលដៅមួយចំនួនដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ និងសិទ្ធិ (NSSRHR) ឆ្នាំ២០១៧-២០២៣ មិនទាន់បានសម្រេច ដោយគ្រាន់តែបង្ហាញពីភាពប្រសើរឡើងតិចតួចប៉ុណ្ណោះ។ ជាឧទាហរណ៍ ភាគរយ នៃស្ត្រីដែលរៀបការរួច និងប្រើមធ្យោបាយពន្យារកំណើត រយៈពេលវែង ឬមធ្យោបាយបញ្ឈប់កំណើត (ការដាក់កងក្រោមស្បែក កងដាក់ក្នុងស្បូន និងការចោះចងបំពង់បង្ហូរមេជីវិតបុរស និងការចោះចងដៃស្បូន) មានភាពប្រែប្រួលតិចតួចពី ៩,៦% ក្នុងឆ្នាំ២០១៤ ឡើងដល់ ១០% ក្នុងឆ្នាំ ២០២១-២០២២។[3] ក្នុងរយៈពេល ៣ឆ្នាំមុន ការស្ទង់មតិ ប្រហែល ២១% នៃស្ត្រីមានផ្ទៃពោះទាំងអស់បានបាត់បង់កូនដែលក្នុងនោះ ១២% គឺជាការរលូតកូន ៩% គឺជាការរំលូតកូន និងតិចជាង ១% គឺជាការស្លាប់កូនក្នុងពេលពរពោះ។

សមាមាត្រ នៃស្ត្រីវ័យជំទង់អាយុពី ១៥-១៩ឆ្នាំ ដែលមានផ្ទៃពោះបានធ្លាក់ចុះពី ១២% ទៅ ៩% ចាប់តាំងពីអង្កេតប្រជាសាស្ត្រ និងសុខភាព (CDHS) ចុងក្រោយ។ ក្នុងចំណោមក្រុមនេះ ២% នៃពួកគេ មានបទពិសោធន៍រលូតកូន ឬរំលូតកូន។ ជាងពាក់កណ្តាល នៃពួកគេ (៥៩%) មិនបានប្រើវិធីពន្យារកំណើតនោះទេ។ ក្មេងជំទង់ដែលមិនទទួលបានការអប់រំ (៣៥%) ទំនងជាមានផ្ទៃពោះច្រើនជាងអ្នកដែលមានការអប់រំ ជាពិសេសអ្នកដែលមានការអប់រំកម្រិតមធ្យមសិក្សា (៧%) ។ ការមានផ្ទៃពោះនៅវ័យជំទង់ គឺមានអត្រាខ្ពស់

---

[1] អង្គការ OECD (2019)។ សុខភាពនាពេលបច្ចុប្បន្ន៖ អាស៊ី/ប៉ាស៊ីហ្វិក 2022៖ ការវាស់វែងវឌ្ឍនភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល។

[2] វិទ្យាស្ថានជាតិស្ថិតិ (NIS) [កម្ពុជា] ក្រសួងសុខាភិបាល (MoH) [កម្ពុជា] និង ICF ។ 2023. អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា 2021-22 របាយការណ៍ចុងក្រោយ។ ភ្នំពេញ ប្រទេសកម្ពុជា និងRockville រដ្ឋ Maryland សហរដ្ឋអាមេរិក៖ NIS, MoH, និង ICF

[3] វិទ្យាស្ថានជាតិស្ថិតិ (NIS) [កម្ពុជា] ក្រសួងសុខាភិបាល (MoH) [កម្ពុជា] និងICF ។ 2023. អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា 2021-22 របាយការណ៍ចុងក្រោយ។ ភ្នំពេញ ប្រទេសកម្ពុជា និងRockville រដ្ឋ Maryland សហរដ្ឋអាមេរិក៖ NIS, MoH, និង ICF

នៅក្នុងតំបន់ជនបទ (១០%) ជាងនៅតំបន់ទីក្រុង (៨%)។ ក្នុងចំណោមក្មេងជំទង់ដែលរៀបការរួច ភាគច្រើន (៥៩%) មិនបានប្រើវិធីពន្យារកំណើតនោះទេ [4]។

ស្ត្រីភាគច្រើន (៩៩%) យ៉ាងហោចណាស់ទទួលបានការថែទាំផ្ទៃពោះមុនសម្រាលពីអ្នកផ្តល់សេវាជំនាញហើយ ៨៦% នៃស្ត្រីទទួលបានការថែទាំចំនួនបួនដង ឬច្រើនជាងនេះ។ ការសម្រាលកូននៅតាមមូលដ្ឋានសុខាភិបាលកើនឡើងយ៉ាងខ្លាំងពី ៦៦% ក្នុងឆ្នាំ២០១០ ដល់ ៩៨% ក្នុងឆ្នាំ ២០២១-២០២២ ហើយ ៩៩% នៃការសម្រាលកូនដោយបុគ្គលិកជំនាញ។ ទោះជាយ៉ាងនេះក្តី ភាគរយ នៃទារកដែលបានបៅទឹកដោះម្តាយ ក្នុងកំឡុងពេល១ម៉ោងក្រោយសម្រាល បានធ្លាក់ចុះពី ៦៣% ក្នុងឆ្នាំ ២០១៤ មក ៥៤% ក្នុងឆ្នាំ ២០២១-២០២២។ ស្ត្រីទទួលបានការថែទាំក្រោយសម្រាល បានកើនឡើងយ៉ាងខ្លាំងពី ៣១% ទៅ ៨៥% ។[5]

ចំណេះដឹងជុំវិញមេរោគអេដស៍ក៏មានភាពប្រសើរឡើងផងដែរ។ ៧៤% និង៨៣% នៃស្ត្រី និងបុរស ដឹងថាការប្រើស្រោមអនាម័យជាប់លាប់កាត់បន្ថយហានិភ័យ នៃការឆ្លងមេរោគអេដស៍។ ស្ត្រីភាគច្រើន បានធ្វើតេស្តរកមេរោគអេដស៍ ដោយអត្រាកើនឡើងពី ២៤% ក្នុងឆ្នាំ២០០០ ដល់ ៤៧% ក្នុងឆ្នាំ ២០២១-២០២២។ ទោះបីជាយ៉ាងនេះក្តី ភាគរយ នៃស្ត្រីដែលបានធ្វើតេស្តរកមេរោគអេដស៍ក្នុងអំឡុងពេល នៃការណាត់ជួបសម្រាប់ការថែទាំមុនសម្រាល និងរង់ចាំទទួលលទ្ធផលតេស្ត បានថយចុះពី ៨២,៥% ទៅ ៦៦% នៅចន្លោះឆ្នាំ២០១៤ និង២០២១-២០២២។ ក្នុងប្រទេសកម្ពុជា ប្រជាជនប្រមាណ ៧៦ ០០០នាក់ កំពុងរស់នៅជាមួយមេរោគអេដស៍ក្នុងឆ្នាំ ២០២១-២០២២ ហើយការឆ្លងមេរោគអេដស៍ថ្មីចំនួន ១ ៤០០នាក់ ទៀតត្រូវបានកត់ត្រានៅឆ្នាំនោះ។ តួលេខទាំងនេះ បង្កើនការព្រួយបារម្ភអំពីការថយចុះការយល់ដឹងអំពីហានិភ័យ នៃមេរោគអេដស៍ និងជំងឺកាមរោគក្នុងចំណោមយុវជន ដែលបណ្តាលឱ្យមានអត្រាទាប នៃការធ្វើតេស្ត និងការប្រើស្រោមអនាម័យក្នុងចំណោមប្រជាជនវ័យជំទង់សំខាន់ៗ។

ស្ត្រីកម្ពុជាគ្រប់វ័យ ១នាក់ ក្នុងចំណោម ១០នាក់ បច្ចុប្បន្នកំពុងរស់នៅជាមួយអំពើហិង្សាពីដៃគូស្និទ្ធស្នាល ហើយសមាមាត្រស្ត្រីដែលជឿថាប្តីមានហេតុផលក្នុងការវាយប្រពន្ធ គឺនៅតែមានកម្រិតខ្ពស់ក្នុងអត្រា ៣៧% ទោះបីជាមានការថយចុះកន្លងមកក៏ដោយ។ ទោះបីជាយ៉ាងនេះក្តី ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ទំនងជាត្រូវបានរាយការណ៍តិចតួចដោយសារការភ័យខ្លាចការសងសឹក ការមាក់ងាយពីសង្គម ការរើសអើង និងការមិនទុកចិត្តលើប៉ូលីស និងប្រព័ន្ធតុលាការ។[6] ខណៈ ២១% នៃអ្នកនៅរស់រានមានជីវិតស្វែងរកជំនួយពីប៉ូលីស អ្នកនៅរស់រានមានជីវិត ភាគច្រើនមានទំនោរស្វែងរកជំនួយពីគ្រួសាររបស់ពួកគេជាញឹកញាប់បំផុត។ បច្ចុប្បន្ន ៥៨% នៃករណីអំពើហិង្សា គឺប្រព្រឹត្តដោយប្តី និងដៃគូស្និទ្ធស្នាល ។ ក្នុងចំណោមស្ត្រីដែលបានជួបប្រទះហិង្សានេះ ១០% នៃករណីបានចាប់ផ្តើមក្នុងអំឡុងពេលជំងឺរាតត្បាត កូវីដ១៩។[7]

ប្រជាជនមួយចំនួនប្រឈមនឹងហានិភ័យកើនឡើង នៃការជួបប្រទះអំពើហិង្សា និងការរំលោភបំពាន ការកើនឡើងនូវឧបសគ្គក្នុងការទទួលបាន ការការពារប្រឆាំងនឹងអំពើហិង្សាទាំងនេះ ដោយសារអាយុ ទំនោរ

---

[4] វិទ្យាស្ថានជាតិស្ថិតិ (NIS) [កម្ពុជា] ក្រសួងសុខាភិបាល (MoH) [កម្ពុជា] និងICF ។ 2023. អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា 2021-22 របាយការណ៍ចុងក្រោយ។ ភ្នំពេញ ប្រទេសកម្ពុជា និងRockville រដ្ឋ Maryland សហរដ្ឋអាមេរិក៖ NIS, MoH, និងICF

[5] វិទ្យាស្ថានជាតិស្ថិតិ (NIS) [កម្ពុជា] ក្រសួងសុខាភិបាល (MoH) [កម្ពុជា] និងICF ។ 2023. អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា 2021-22 របាយការណ៍ចុងក្រោយ។ ភ្នំពេញ ប្រទេសកម្ពុជា និងRockville រដ្ឋ Maryland សហរដ្ឋអាមេរិក៖ NIS, MoH, និង ICF

[6]ការពិគ្រោះយោបល់របស់អ្នកពាក់ព័ន្ធក្នុងអំឡុងពេលដំណើរការអភិវឌ្ឍន៍ NSSRHR ។

[7] វិទ្យាស្ថានជាតិស្ថិតិ (NIS) [កម្ពុជា] ក្រសួងសុខាភិបាល (MoH) [កម្ពុជា] និងICF ។ 2023. អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា 2021-22 របាយការណ៍ចុងក្រោយ។ ភ្នំពេញ ប្រទេសកម្ពុជា និងRockville រដ្ឋ Maryland សហរដ្ឋអាមេរិក៖ NIS, MoH, និងICF

ផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ស្ថានភាពចំណាកស្រុក ស្ថានភាពពិការ ការងារ និងកត្តាផ្សេងៗទៀត។ ជាឧទាហរណ៍ ស្ត្រីពិការនៅកម្ពុជាមានអត្រាខ្ពស់ប្រឈមនឹងអាកប្បកិរិយាគ្រប់គ្រងពីដៃគូ និងប្រឈមកាន់តែខ្ពស់ពីអំពើហិង្សាគ្រប់ទម្រង់ (ផ្លូវចិត្ត ផ្លូវកាយ និងផ្លូវភេទ) ពីសមាជិកគ្រួសារ។ ឧបសគ្គចំពោះការលាតត្រដាង និងការទទួលបានសេវា គឺកាន់តែអាក្រក់ទៅៗសម្រាប់ស្ត្រីពិការជាច្រើន ដោយសារពួកគេមានស្វ័យភាព និងអំណាចលើហិរញ្ញវត្ថុ និងការសម្រេចចិត្តជាងស្ត្រីដទៃទៀត។[8] ខណៈពេលដែល HMIS បច្ចុប្បន្នមិនបែងចែកទិន្នន័យទៅតាមស្ថានភាពពិការភាព នាយកដ្ឋានព័ត៌មានសុខាភិបាល របស់ក្រសួងសុខាភិបាលបានចាប់ផ្តើមកិច្ចពិភាក្សានៅឆ្នាំ ២០២៣ អំពីរបៀបបញ្ចូលលក្ខណៈពិសេសនេះ។[9]

ស្ត្រីក្នុងសហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ក៏ប្រឈមនឹងកត្តាហានិភ័យជាក់លាក់ និងឧបសគ្គក្នុងការទទួលបានការគាំទ្រផងដែរ។ នៅខេត្តរតនគិរី ដែលសហគមន៍ជនជាតិដើមភាគតិចមានវត្តមានច្រើនជាងតំបន់ផ្សេងទៀត នៃប្រទេសមានក្មេងស្រីជាច្រើន (៤៩%) បានរៀបការនៅវ័យកុមារ[10] ដែលនេះបង្កើនហានិភ័យ នៃការប្រឈមមុខនឹងអំពើហិង្សាផ្លូវភេទ និងរាងកាយពីដៃគូរស្និទ្ធស្នាល បើធៀបនឹងអ្នកដែលរៀបការក្រោយអាយុ ១៨ ឆ្នាំ[11]។ លើសពីនេះ ស្ត្រីជនជាតិដើមភាគតិចដែលជួបប្រទះអំពើហិង្សា ប្រឈមមុខនឹងបញ្ហាប្រឈមសំខាន់ៗក្នុងការទទួលបានយុត្តិធម៌ ទីជម្រកសុវត្ថិភាព សេវាប្រឹក្សា ជំនួយផ្នែកច្បាប់ និងសេវាផ្សេងៗទៀតផងដែរ។[12]

កម្ពុជាជាប់ចំណាត់ថ្នាក់លេខពីរក្នុងតំបន់អាស៊ីអាគ្នេយ៍ បន្ទាប់ពីប្រទេសមីយ៉ាន់ម៉ា សម្រាប់ការបង់ប្រាក់ពីហោប៉ៅ (OOP) ដោយអ្នកជំងឺសម្រាប់ការថែទាំសុខភាព ដែលមានចំនួន ៦៤% នៃការចំណាយសុខភាពសរុបក្នុងឆ្នាំ២០១៩។ នេះធ្វើឱ្យប្រជាជនកម្ពុជាប្រឈមនឹងហានិភ័យខ្ពស់ នៃការចំណាយបញ្ហាសុខភាព ឬកង្វះលទ្ធភាពទទួលបានការថែទាំសុខភាព។[13] ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាថែទាំសុខភាព រដ្ឋាភិបាលកម្ពុជាបានបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. ក្នុងគោលបំណងផ្តល់សេវាធានារ៉ាប់រងសុខភាពដល់កម្មករធ្វើការក្នុងវិស័យផ្លូវការចំនួនជាង២លាននាក់ មន្ត្រីរាជការ សោធននិវត្តន៍ និងអតីតយុទ្ធជន(ប្រមាណ ៤0% នៃចំនួនប្រជាជន)។ ថ្មីៗនេះ ប.ស.ស. បានពង្រីក ដោយដាក់បញ្ចូលអ្នកដែលរស់នៅក្នុងបន្ទុករបស់ពួកគេ និងកម្មករក្រៅប្រព័ន្ធផ្លូវការផងដែរ។ លើសពីនេះទៀត នៅឆ្នាំ២000 រដ្ឋាភិបាលបានបង្កើតមូលនិធិសមធម៌សុខភាព (HEF) ដើម្បីផ្តល់ហិរញ្ញប្បទានសុខភាពសម្រាប់ប្រជាជនកម្ពុជាក្រីក្រ ក្នុងការទទួលបានសេវាសុខភាព។ HEF ត្រូវបានគ្រប់គ្រងដោយក្រសួងសុខាភិបាល ហើយបច្ចុប្បន្នគ្របដណ្តប់ប្រហែល ២,៥លាននាក់ ដែលចាត់ថ្នាក់ថាជាអ្នកក្រីក្រ។ អ្នកទទួលផលពី HEF អាចទទួលបានការព្យាបាលនៅគ្រប់គ្រឹះស្ថានសុខភាពសាធារណៈ។

រដ្ឋាភិបាលប្តេជ្ញាកាត់បន្ថយការចំណាយពីហោប៉ៅ (OOP) ពី ៦0% មកនៅ ៣0% ដោយទទួលស្គាល់ពីតម្រូវការក្នុងការពង្រីកបន្ថែមទៀតនូវលទ្ធភាពទទួលបានសេវាថែទាំសុខភាពបឋម។ ទោះជាយ៉ាងនេះក្តី ការប្រើ

---

[8]Astury, J., Walji F. (2013) គ្រោះថ្នាក់បីជង់៖ អំពើហឹង្សាផ្អែកលើយេនឌ័រ និងការរំលោភសិទ្ធិមនុស្ស បទពិសោធន៍ដោយស្ត្រីពិការនៅកម្ពុជា។ ភ្នំពេញ។ ជំនួយអូស្ត្រាលី។

[9] ការពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធ៖ ជាតុចូលពី RHAC ។

[10]វិទ្យាស្ថានជាតិស្ថិតិ (NIS) [កម្ពុជា] ក្រសួងសុខាភិបាល (MoH) [កម្ពុជា] និងICF ។ 2023. អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា 2021-22 របាយការណ៍ចុងក្រោយ។ ភ្នំពេញ ប្រទេសកម្ពុជា និងRockville រដ្ឋ Maryland សហរដ្ឋអាមេរិក៖ NIS, MoH, និងICF

[11] ក្មេងស្រីមិនមែនជាកូនក្រមុំ។ (២០២២)។ អំពើហិង្សាផ្អែកលើយេនឌ័រ និងអាពាហ៍ពិពាហ៍កុមារ ។

[12]Rendell, S, Lee, H., (2017), ការបៀតបៀនផ្លូវភេទក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា៖ ប្រេវ៉ាឡង់ និងថ្លៃដើម។ ទីក្រុងកង់បេរ៉ា៖ CARE International។

[13] ក្រសួងសុខាភិបាលកម្ពុជា។ (២០២២)។ ធ្វើបច្ចុប្បន្នភាព និងពង្រីកយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិនៅកម្ពុជា (២០១៧-២០២៣)។

របបសន្តិសុខសង្គមនៅមានកម្រិតទាប ដោយសារមណ្ឌលសុខភាពជាច្រើនប្រឈមមុខនឹងបញ្ហាផ្គត់ផ្គង់ និងតម្រូវការ ដើម្បីផ្តល់សេវាមានគុណភាពខ្ពស់។ ការកើនឡើង នៃមូលនិធិសម្រាប់ PHC និងកម្មវិធីគាំពារសង្គមក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បាននាំឱ្យមានការកើនឡើង នៃការប្រើប្រាស់ ប៉ុន្តែប្រជាជនកម្ពុជារាយការណ៍ពីចំណូលចិត្តក្នុងការទទួលសេវាពីវិស័យឯកជន ឬគ្លីនិកដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាល ដែលសេវាមួយចំនួនមិនមានភ្ជាប់ទៅនឹងកម្មវិធីធានារ៉ាប់រងសុខភាពសង្គមដែលមានស្រាប់នោះទេ។ អ្នកទទួលផលចាំបាច់ត្រូវបង្កើនការយល់ដឹងអំពីកម្មវិធីធានារ៉ាប់រងសុខភាពដែលផ្តល់មូលនិធិដោយរដ្ឋាភិបាល សេវាកម្ម និងអត្ថប្រយោជន៍អ្វីខ្លះដែលមាន ក៏ដូចជាបន្តពង្រឹងគុណភាព នៃការផ្តល់សេវាសុខភាពសាធារណៈ ដើម្បីបង្កើនតម្រូវការ និងការប្រើប្រាស់សេវានៅតាមគ្រឹះស្ថានសុខភាពសាធារណៈ។ ក្របខ័ណ្ឌការអនុវត្តកម្មវិធីជំរុញការថែទាំសុខភាពបឋមបង្ហាញពីមធ្យោបាយក្នុងការសម្រេចបាននូវ PHC ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាព ប្រកបដោយសមធម៌ និងមាននិរន្តរភាពក្នុងការសម្រេចបានការគ្របដណ្តប់សុខភាពជាសកល (UHC)។

## 1.2 កត្តាសំខាន់ៗដែលជះឥទ្ធិពលដល់សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធ (SRHR) នៅកម្ពុជា

### 1.2.1 ការរើសអើង និងវិសមភាព (រួមទាំងបទដ្ឋានសង្គម និងយេនឌ័រដែលបង្កគ្រោះថ្នាក់ និងរើសអើង)

**ការរើសអើង**

គោលនយោបាយរបស់ប្រទេសកម្ពុជា មិនមានការរើសអើងប្រឆាំងនឹងក្រុមណាមួយរួមទាំងនៅក្នុងប្រព័ន្ធសុខាភិបាល ប៉ុន្តែគោលនយោបាយទាំងនេះមិនត្រូវបានអនុវត្តពេញលេញដោយអ្នកផ្តល់សេវាសុខភាពទាំងអស់ឡើយ ដោយសារនៅមានអ្នកផ្តល់សេវាមួយចំនួនបង្ហាញអាកប្បកិរិយារើសអើង។ អ្នករកស៊ីផ្លូវភេទ (២០%) រាយការណ៍ពីការជៀសវាងការថែទាំសុខភាព ដោយសារតែភ័យខ្លាចការមាក់ងាយ និងការរើសអើង។[14] ការសិក្សាមួយដែលធ្វើឡើងក្នុងឆ្នាំ ២០១៩ ដោយបណ្តាញប្រជាជនកម្ពុជាដែលរស់នៅជាមួយមេរោគអេដស៍ (CPN+) បានរកឃើញថា ប្រជាជនមួយចំនួនបានរាយការណ៍ថាពួកគេមាន "បទពិសោធន៍មិនល្អជាមួយបុគ្គលិកសុខាភិបាល" ដែលនេះជាហេតុផលក្នុងការមិនស្វែងរកការព្យាបាលមេរោគអេដស៍បន្ទាប់ពីទទួលបានលទ្ធផលតេស្តវិជ្ជមាន។[15] ការរើសអើងជាតិសាសន៍ និងការរើសអើង រួមចំណែកដល់ការមិនអើពើ និងមិនរាប់បញ្ចូលបុគ្គល និងក្រុមគ្រួសារ និងសហគមន៍ក្នុងការថែទាំសុខភាព[16]។ មនុស្សជាច្រើននៅក្នុងក្រុមដែលត្រូវបានទុកចោល មិនទទួលបានសេវា ប្រកបដោយភាពថ្លៃថ្នូរ វប្បធម៌ និងសមរម្យទៅតាមអាយុរបស់ពួកគេឡើយ ហើយមិនមានឱកាសស្មើគ្នាក្នុងការទទួលបានធនធានហិរញ្ញវត្ថុ និងការអប់រំដែលត្រូវការដើម្បីទទួលសេវាសុខភាព ដោយសារតែការរើសអើងជាតិសាសន៍ ការរើសអើង វិសមភាព និងអសន្តិសុខ។[17] គេត្រូវតែទទួលស្គាល់ និងដោះស្រាយមូលហេតុ និងឫសគល់នៃការស្លាប់មាតា និងទារកទាំងនេះ ដើម្បីសម្រេចបាននូវសុខភាព និងសុខុមាលភាពនៅក្នុង និងក្រៅបរិបទសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ (SRHR) ។

---

[14]UNAIDS ដកស្រង់ទិន្នន័យពី BSS 2022។ ចូលប្រើនៅ https://www.unaids.org/en/regionscountries/countries/cambodia

[15]The People Living with HIV Stigma Index 2.0 Cambodia: របាយការណ៍ស្រាវជ្រាវ។ (2019)។ ចូលប្រើនៅ៖ https://www.stigmaindex.org/wp-content/uploads/2020/10/Cambodia-SI-Report-2019_English.pdf

[16]អង្គការសហប្រជាជាតិកម្ពុជា (2022), សមភាពយេនឌ័រ ស៊ីជម្រៅសម្រាប់កម្ពុជា៖ ការវិភាគប្រទេសទូទៅ។

[17]សេចក្តីថ្លែងការណ៍បញ្ចប់បេសកកម្ម៖ ដំណើរទស្សនកិច្ចរបស់ IE SOGI មកកាន់ព្រះរាជាណាចក្រកម្ពុជា នីតិវិធីពិសេសសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ខែមករា ឆ្នាំ 2023 ។

យុទ្ធសាស្ត្រនេះ ទទួលស្គាល់នូវតម្រូវការក្នុងការជំរុញឱ្យមាន ការតស៊ូមតិលើសពីបរិបទប្រព័ន្ធសុខាភិបាល ដើម្បីមានឥទ្ធិពលលើកត្តាកំណត់សង្គមដែលមានឥទ្ធិពលលើសុខភាព។ ដូចដែលបានពិពណ៌នានៅក្នុងយុទ្ធសាស្ត្រផ្នែកទី ៤ គេត្រូវការមានច្បាប់ និងគោលនយោបាយសម្រាប់គាំទ្រ ហាមឃាត់ការរើសអើងក្នុងគ្រប់វិស័យ ព្រមទាំងអនុញ្ញាតឱ្យស្ត្រីធ្វើការសម្រេចចិត្តដោយខ្លួនឯងក្នុងគ្រប់ទិដ្ឋភាព នៃជីវិត និងធ្វើឱ្យមានសមភាពយេនឌ័រក្នុងវិស័យផ្សេងទៀតដូចជាការងារ ការអប់រំ និងយុត្តិធម៌។

## វិសមភាពសេដ្ឋកិច្ចសង្គម

ឧបសគ្គចម្បងក្នុងការទទួលបានការថែទាំសុខភាពនៅក្នុងប្រទេសកម្ពុជា គឺលទ្ធភាពក្នុងការបង់ថ្លៃសេវាខណៈចំណាយពីហោប៉ៅ (OOP) ដែលរួមចំណែក ៤០% នៃការចំណាយលើសុខភាពបច្ចុប្បន្ន (CHE) ស្ថិតក្នុងចំណាត់ថ្នាក់ខ្ពស់បំផុតក្នុងតំបន់ (WHO 2023)។ គម្រោងថែទាំសុខភាពដោយស្ម័គ្រចិត្ត រួមមានជម្រើសធានារ៉ាប់រងឯកជន និងធានារ៉ាប់រងរបស់ស្ថាប័នមិនរកប្រាក់ចំណេញ រួមចំណែកតិចតួចបំផុតនៅក្នុង CHE ។ នៅខែមិថុនា ឆ្នាំ២០១៩ កម្ពុជាបានដាក់ឱ្យដំណើរការនូវគោលការណ៍ណែនាំកញ្ចប់សេវាថែទាំពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយពេលសម្រាល (១០០០ថ្ងៃ) ដោយផ្តល់នូវការណែនាំច្បាស់លាស់លើសេវាទាំងអស់ដែលបានផ្តល់ក្នុងអំឡុងពេលនេះ និងអាចចូលប្រើប្រាស់បានតាមរយៈមូលនិធិសមធម៌សុខភាព (HEF)។ ទោះជាយ៉ាងនេះក្តី ការប្រើប្រាស់គម្រោងនេះ នៅមានកម្រិតទាបនៅឡើយ ដោយសារកង្វះការយល់ដឹងគ្រប់ជ្រុងជ្រោយក្នុងចំណោមអ្នកទទួលផលដែលមានសក្តានុពល ក៏ដូចជាការយល់ឃើញពីគុណភាពមិនល្អ នៃសេវាផ្តល់ដោយប្រព័ន្ធសុខាភិបាលក្នុងវិស័យសាធារណៈ ដែលនាំឱ្យអ្នកប្រើប្រាស់ចូលចិត្តទៅទទួលសេវាពីអ្នកផ្តល់សេវាឯកជន។ នៅឆ្នាំ២០២៣ ការគ្របដណ្តប់ដោយបេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានពង្រីកដល់អ្នករស់ក្នុងបន្ទុករបស់មន្ត្រីរាជការ កម្មករក្នុងវិស័យផ្លូវការ កម្មករក្រៅប្រព័ន្ធផ្លូវការ និងបុគ្គលិកផ្នែកកម្សាន្តផងដែរ។

## បទដ្ឋានយេនឌ័រ

យេនឌ័រ គឺជាកត្តាកំណត់សង្គមដ៏សំខាន់ដែលមានឥទ្ធិពលលើសុខភាព រួមទាំង SRHR ។ បទដ្ឋានយេនឌ័រមិនត្រឹមតែប៉ះពាល់ដល់ស្ត្រី និងកុមារីនោះទេ វាក៏បង្កហានិភ័យចំពោះសុខភាព និងប៉ះពាល់ដល់អាកប្បកិរិយាស្វែងរកការថែទាំសុខភាពរបស់បុរសផងដែរ ដោយសារផ្នត់គំនិតយេនឌ័រ នៃភាពជាបុរស បង្កឱ្យពួកគេខ្វះឆន្ទៈក្នុងការស្វែងរកការថែទាំសុខភាព ព្រោះបុរសអាចត្រូវអ្នកដទៃថាទន់ខ្សោយនៅពេលទៅរកសេវាថែទាំសុខភាព។ បទដ្ឋានសង្គមនៅក្នុងប្រទេសកម្ពុជាទាក់ទងនឹងសមភាពយេនឌ័រ គឺមានភាពប្រសើរឡើងក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ប៉ុន្តែបទដ្ឋានគ្រោះថ្នាក់ជាច្រើននៅតែជះឥទ្ធិពលអវិជ្ជមានដល់សមត្ថភាពក្នុងការសម្រេចបាននូវលទ្ធផលសុខភាព និងសុខុមាលភាពល្អបំផុតរបស់ស្ត្រី និងបុរស។

ស្ត្រីម្នាក់ក្នុងចំណោមប្រាំនាក់ បានទទួលរងអំពើហិង្សាផ្លូវចិត្ត ផ្លូវកាយ ឬផ្លូវភេទដោយដៃគូស្និទ្ធស្នាលនៅពេលណាមួយក្នុងមួយជីវិតរបស់ពួកគេ (CDHS 2021-2022)។ ផ្ទុយទៅវិញមានស្ត្រីតែម្នាក់ប៉ុណ្ណោះក្នុងចំណោមប្រាំនាក់ បានទៅស្វែងរកសេវាគាំទ្រជាផ្លូវការ ដូចជាការថែទាំសុខភាព ផ្លូវចិត្ត និងរាងកាយនេះដោយសារបុគ្គលិកផ្តល់សេវាបានស្តីបន្ទោសដល់អាកប្បកិរិយារបស់ស្ត្រីថា ជាមូលហេតុនាំឱ្យមានអំពើហិង្សាដែលការស្តីបន្ទោសនេះរងឥទ្ធិពលពីបទដ្ឋានយេនឌ័រ (MoWA & WHO 2015) ។

កិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អបទដ្ឋានយេនឌ័រដែលរឹតត្បិត គឺមានភាពឃើតយ៉ាវជាពិសេសសម្រាប់ស្ត្រីដែលប្រឈមមុខនឹងទម្រង់ នៃការរើសអើងបន្ថែម ដូចជាស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច អ្នកដែលរស់នៅជាមួយនឹងពិការភាព មនុស្សដែលស្រឡាញ់ភេទដូចគ្នា បុរសស្រលាញ់បុរស អ្នកប្តូរភេទ អ្នកដែលមិនទាន់ច្បាស់អំពីអត្តសញ្ញាណរបស់ខ្លួន និងអ្នកមានភេទចម្រុះ (LGBTQI+) និងស្ត្រីដែលរស់នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា (UN 2022)។ យុវជននៅក្នុងប្រទេសកម្ពុជាបានឃើញ និងមានបទពិសោធន៍ទទួលរងអំពើហិង្សាលើរាងកាយនៅក្នុងសហគមន៍ និងផ្ទះរបស់ពួកគេ រួមមានការរំលោភសេពសន្ថវៈ ដែលនេះបញ្ជាក់ឱ្យឃើញពីតម្រូវការសេវាសុខភាព និងជំនួយដោយផ្តោតលើយុវជន ដើម្បីតម្រូវទៅតាមតម្រូវការរបស់ក្មេងជំទង់។ បទដ្ឋានយេនឌ័រត្រូវបានផ្ទេរបន្តជាច្រើនជំនាន់ ដោយសារកុមារជាច្រើនបានឃើញអំពើហិង្សាដែលកើតឡើងក្នុងចំណោមឪពុកម្តាយរបស់ពួកគេ ហើយនេះបង្កើនហានិភ័យ ដោយពួកគេនឹងធ្វើតាមនូវអាកប្បកិរិយា និងជំនឿដែលបង្កគ្រោះថ្នាក់នេះ (MoWA & WHO 2015)។

បទដ្ឋានយេនឌ័រនៅក្នុងប្រទេសកម្ពុជា និងឥទ្ធិពលរបស់វាទៅលើសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ អាចត្រូវបានបែងចែកជាបួនផ្នែកខាងក្រោមទៅតាមក្របខ័ណ្ឌវិភាគយេនឌ័រៈ

***លទ្ធភាពទទួលបានទ្រព្យសម្បត្តិៈ*** អត្រាចូលរួមក្នុងកម្លាំងពលកម្មដោយស្ត្រីនៅប្រទេសកម្ពុជាមានកម្រិតខ្ពស់ ប៉ុន្តែមានគម្លាតប្រាក់ឈ្នួលដោយផ្អែកលើយេនឌ័រគឺមានដល់ទៅ ១៩% ដោយសារតែការងាររបស់ស្ត្រីភាគច្រើនមានភាពមិនច្បាស់លាស់ ទទួលបានប្រាក់ខែទាប និងក្រៅផ្លូវការ។ មូលហេតុមួយក្នុងចំណោមមូលហេតុដែលបង្កឱ្យមានវិសមភាពនេះ គឺដោយសារតែចំនួនស្ត្រីទទួលបានកម្រិតអប់រំខ្ពស់មានតិចជាងបុរស។ ក្នុងចំណោមស្ត្រីដែលធ្វើការនៅក្នុងរោងចក្រកាត់ដេរ ការបៀតបៀន និងការស្តីបន្ទោសជនរងគ្រោះដោយសារបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ ធ្វើឱ្យមានការមាក់ងាយទាក់ទងផ្លូវភេទរបស់ស្ត្រី ហើយនេះផលប៉ះពាល់ដល់សេដ្ឋកិច្ច ដោយធ្វើឱ្យមានការថយចុះផលិតភាពរបស់ស្ត្រី។ ជាប្រវត្តិសាស្ត្រ អត្រា នៃការរំលោភបំពានផ្នែកសេដ្ឋកិច្ចដែលជាទម្រង់មួយ នៃអំពើហិង្សាដោយដៃគូស្និទ្ធស្នាល បានគ្រប់គ្រងលទ្ធភាពរបស់ជនរងគ្រោះដែលនៅរស់រានមានជីវិតក្នុងការទទួលបាន ប្រើប្រាស់ និងថែរក្សាធនធាន នៅក្នុងប្រទេសកម្ពុជា ដែលបញ្ហានេះ មានកម្រិតខ្ពស់ជាងប្រទេសដទៃទៀតនៅក្នុងតំបន់ (UN Women 2012 )។ ជាលទ្ធផល ស្ត្រីប្រហែលជាមិនមានមធ្យោបាយ ហិរញ្ញវត្ថុក្នុងការទៅទទួលបានសេវាសុខភាព ឬចំណេះដឹងអំពីរបៀបទទួលបានសេវាធានារ៉ាប់រងសុខភាពនោះទេ។ កម្រិត នៃការអប់រំទាប ក៏មានទំនាក់ទំនងទៅនឹងចំណេះដឹងទាបអំពីសុខភាព និងលទ្ធភាពក្នុងការតស៊ូមតិសម្រាប់ខ្លួនគេនៅក្នុងបរិបទសុខភាពផងដែរ។

***ជំនឿ និងការយល់ឃើញៈ*** ជំនឿបែបបុរាណបានរួមចំណែកដល់ការរឹតត្បិតសិទ្ធិស្ត្រីក្នុងការទទួលបានសេវាថែទាំសុខភាពបន្តពូជសំខាន់ៗ។ ការប្រើអំពើហិង្សា និងអំណាច និងការគ្រប់គ្រងលើស្ត្រីដោយបុរស គឺជាបទដ្ឋានសង្គមទូទៅមួយនៅក្នុងប្រទេសកម្ពុជា ហើយសង្គមមានការអត់ឱន និងទទួលយកអំពើហិង្សាលើស្ត្រីក្នុងកម្រិតខ្ពស់ (MoWA & WHO 2015)។ ស្ត្រីប្រឈមមុខនឹងឧបសគ្គក្នុងការស្វែងរកជំនួយ រួមមានការខ្មាស់អៀនចំពោះការយល់ឃើញ របស់សាធារណជនដោយសារការស្តីបន្ទោស និងការចំអកឱ្យជនរងគ្រោះគឺពេញនិយមនៅក្នុងសង្គម និងភាពអាចរកបាន នៃសេវាកម្ម (UNFPA 2021)។ បទដ្ឋានទាំងនេះ គឺជាឧបសគ្គចំពោះស្ត្រីក្នុងការស្វែងរកសេវាសុខភាព ជាពិសេសប្រសិនបើពួកគេមកពីក្រុមដែលត្រូវបានផាត់ចេញពីសង្គម។

*ការអនុវត្ត និងការចូលរួម៖* ឧបសគ្គសំខាន់មួយទៀត គឺបន្ទុកការងារមិនស្មើគ្នានៅក្នុងផ្ទះ។ ជាធម្មតា ស្ត្រីនៅក្នុងប្រទេសកម្ពុជាធ្វើការងារផ្ទះច្រើន រួមទាំងការថែទាំកុមារ សមាជិកគ្រួសារ ដែលមានជំងឺ និងមនុស្សចាស់។ ក្នុងចំណោមប្រទេសចំនួន ៦៧ ដែលត្រូវបានអង្កេតដោយ ILO ក្នុងឆ្នាំ២០១៨ បុរសនៅប្រទេសកម្ពុជាចំណាយពេលតិចបំផុតក្នុងការរួមចំណែកក្នុងការថែទាំ ឬការងារផ្ទះដែលមិនមានប្រាក់ខែ។ បុរសកម្ពុជាចំណាយពេល ១៨នាទី ធ្វើការងារនេះក្នុងមួយថ្ងៃ ធៀបនឹង ១៨៨នាទី ដែលស្ត្រីចំណាយ។[18] បន្ទុកគ្រួសារបានរារាំងស្ត្រីកម្ពុជាមិនឱ្យប្រើសក្តានុពលរបស់ពួកគេ ដោយសារស្ត្រីមួយចំនួនជ្រើសរើសឈប់ពីការងារ ឬអាជីវកម្មដោយសារតែបន្ទុកការងារផ្ទះ និងការងារថែទាំច្រើនពេក។ លើសពីនេះ ស្ត្រីជាធម្មតាមានការគ្រប់គ្រងតិច លើការសម្រេចចិត្តក្នុងគ្រួសារ រួមមានទៅលើការស្វែងរកការថែទាំសុខភាព ឬការចំណាយប្រាក់លើសុខភាព សូម្បីក្នុងករណីដែលស្វាមីគ្មានការងារធ្វើ ឬអសមត្ថភាពក៏ដោយ។ នៅក្នុងវិស័យការងារ ចំនួនស្ត្រីស្ថិតនៅក្នុងតំណែងតួនាទីជាន់ខ្ពស់ដែលមានអំណាចក្នុងការសម្រេចចិត្ត និងការដឹកនាំ គឺនៅមានតិច។ ការអនុវត្តបែបនេះ ក៏មាននៅក្នុងវិស័យសុខាភិបាលផងដែរ ដែលធ្លបភាគច្រើនគឺជាស្ត្រី ខណៈពេលដែលអ្នកផ្តល់សេវាកម្រិតខ្ពស់ភាគច្រើនគឺជាបុរស។ ភាពមានកម្រិត នៃចំនួនស្ត្រីជាអ្នកដឹកនាំ អាចធ្វើឱ្យគោលនយោបាយ និងកម្មវិធីដែលត្រូវបានរៀបចំឡើង ឬការអនុវត្ត នៃកម្មវិធី មិនមានការឆ្លើយតបទៅនឹងយេនឌ័រ ហើយរឹតត្បិតបន្ថែមចំពោះសិទ្ធិទទួលបានការថែទាំសុខភាពរបស់ស្ត្រី។

*ស្ថាប័នច្បាប់ និងគោលនយោបាយ ៖* នៅមានគម្លាតនៅក្នុងច្បាប់ដែលដោះស្រាយអំពើហិង្សាលើស្ត្រី និងកុមារ រួមមានដូចជាការមិនអនុវត្តចំពោះដៃគូដែលមិនបានរៀបការ ការរួមរស់ ជាមួយគ្នា ឬដៃគូសង្សារ និងមានករណីលើកលែងចំពោះការដាក់ពិន័យ (UNICEF 2020)។ អ្នកបង្កើតគោលនយោបាយ មិនបានដោះស្រាយបញ្ហាការងារដែលមិនមានប្រាក់ខែតាមរយៈគោលនយោបាយជាតិឡើយ ដូចជាគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា ផែនការ សកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផែនការយុទ្ធសាស្ត្រយេនឌ័ររបស់កម្ពុជា។[19] គោលនយោបាយថែទាំកុមារ ពង្រឹងការរំពឹងទុកយ៉ាងតឹងរ៉ឹងទៅលើស្ត្រីក្នុងការងារក្នុងគ្រួសារដែលភាគច្រើនគ្មានប្រាក់ខែ។ នៅក្នុងប្រព័ន្ធសុខាភិបាល អ្នកផ្តល់សេវាមិនមានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការរាយការណ៍ករណីអំពើហិង្សាទៅអាជ្ញាធរមូលដ្ឋានទេ។ ខណៈពេលដែលប្រទេសកម្ពុជាមានគោលនយោបាយក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវសមភាពយេនឌ័រ គោលនយោបាយទាំងនោះ មិនត្រូវបានអនុវត្តជាប្រព័ន្ធផ្តល់មូលនិធិ ឬត្រូវបានយល់យ៉ាងទូលំទូលាយនោះទេ។ ឧទាហរណ៍ ខណៈពេលដែលអាយុស្របច្បាប់ នៃអាពាហ៍ពិពាហ៍ នៅកម្ពុជាមានអាយុ ១៨ឆ្នាំ ក៏ដោយក្តីឃើញថាស្ត្រី ១៥% បានរៀបការមុនអាយុកំណត់នេះ (ជំរឿនឆ្នាំ២០១៩) ដែលនេះបានផ្សារភ្ជាប់ជាមួយនឹងការកើនឡើងហានិភ័យ នៃលទ្ធផលសុខភាពមិនល្អពេញមួយជីវិត។ លើសពីនេះ ស្ត្រីរាយការណ៍អំពីកម្រិតយល់ដឹងទាប នៃច្បាប់ ស្តីពីអំពើហិង្សាក្នុងគ្រួសារ។ ជាចុងក្រោយការវិនិយោគ និងការបណ្តុះបណ្តាល គឺមិនគ្រប់គ្រាន់ សម្រាប់ការទប់ស្កាត់អំពើហិង្សា និងសម្រាប់សេវាផ្លូវការដើម្បីគាំទ្រជនរងគ្រោះ។ គោលនយោបាយ និងកម្មវិធីមិនត្រូវបានត្រួតពិនិត្យ ឬវាយតម្លៃឱ្យបានល្អដើម្បីអនុញ្ញាតឱ្យមានការកែលម្អជាបន្តបន្ទាប់ ឬពង្រីកកម្មវិធីដែលទទួលបានជោគជ័យបំផុតនោះទេ។ ការវាយតម្លៃ

[18] ILO ។ (2018)។ ការងារថែទាំ និងរបរថែទាំសម្រាប់អនាគត នៃការងារសមរម្យ។

[19] ហេង ម៉ូលីកា។ (២០២២)។ សម្រាប់ស្ត្រីកម្ពុជា សមភាពចាប់ផ្តើមនៅក្នុងផ្ទះ៖ ការបែងចែកការងារផ្ទះមិនស្មើគ្នាប៉ះពាល់ដល់ការរួមបញ្ចូលសេដ្ឋកិច្ចរបស់ស្ត្រីកម្ពុជា។ *អ្នកការទូត។*

ដោយក្រសួងកិច្ចការនារី បានរកឃើញថា NAPVAW ៣ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការ កែលម្អអាកប្បកិរិយាដែលបង្កគ្រោះថ្នាក់ ប៉ុន្តែទិន្នន័យអំពីផលប៉ះពាល់ នៃកម្មវិធីនីមួយៗនៅមានកម្រិត។

### 1.2.2 ការប្រែប្រួលអាកាសធាតុ

ផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុបានពង្រីកភាពងាយរងគ្រោះ ដែលមានស្រាប់ នៅក្នុងសហគមន៍ រួមមានភាពក្រីក្រ អសន្តិសុខស្បៀង និងស្ថានភាពសុខភាពមិនល្អ។ មាត្រដ្ឋានពេញលេញ នៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលមានសក្តានុពលនាពេលបច្ចុប្បន្ន និង អនាគតមកលើសុខភាព និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា ត្រូវបានកំណត់ដោយភាពអាចរកបាន នៃទិន្នន័យ និងការព្យាករណ៍អាកាសធាតុជាក់លាក់ដែលប៉ាន់ស្មាននិន្នាការក្នុងស្រុកដោយ ផ្អែកលើទិន្នន័យទូលំទូលាយ។

ប្រទេសកម្ពុជាងាយរងគ្រោះដោយសារឥទ្ធិពល នៃការប្រែប្រួលអាកាសធាតុ ជាពិសេស ដោយសារតែទឹកជំនន់ នៃអាងទន្លេសាបរងផលប៉ះពាល់យ៉ាងខ្លាំងពីការប្រែប្រួលធាតុអាកាស ហើយទឹកជំនន់កន្លងមកមានការបំផ្លិចបំផ្លាញខ្លាំង។ ខេត្តជាប់មាត់សមុទ្រដូចជាខេត្តកំពត កោះកុង និងខេត្តព្រះសីហនុ ទំនងជាជួបប្រទះនឹងការលិចលង់ដោយទឹកសមុទ្រ និងខ្យល់ព្យុះកាន់តែខ្លាំង ដោយសារការប្រែប្រួលអាកាសធាតុ។ ខេត្តផ្សេងទៀតងាយរងគ្រោះ ដោយសារកម្លាំងពលកម្មមួយភាគធំពឹងផ្អែកលើវិស័យកសិកម្ម ហើយពួកគេទំនងជាធ្វើចំណាកស្រុកដោយសារការប្រែប្រួលអាកាសធាតុ[20]។ ការកើនឡើងហានិភ័យសុខភាព ពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា រួមមាន ជំងឺឆ្លង បង្កដោយសត្វល្អិតខាំ កង្វះអាហារូបត្ថម្ភ និងជំងឺរាគរូស ជំងឺដែលបណ្តាលមកពីសត្វខាំ ការឆ្លងមេរោគតាមផ្លូវដង្ហើម ជំងឺមិនឆ្លង ជំងឺដែលទាក់ទងនឹងកំដៅ ដូចជាភាពតានតឹងដោយសារកំដៅ (heat stress) ជំងឺដាច់សរសៃឈាមខួរក្បាលដោយសារកំដៅ (heat stroke) និងជំងឺល្វិតល្វៃដោយសារកំដៅ ដែលបង្កឱ្យមានបញ្ហាសុខភាពជាច្រើន រួមទាំងផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត។[21]

ស្ត្រី និងកុមារីរងផលប៉ះពាល់ខុសៗគ្នាពីព្រឹត្តិការណ៍ នៃការប្រែប្រួលខ្លាំង នៃអាកាសធាតុ មកលើសុខភាព និងសិទ្ធិរបស់ពួកគេ ដែលនេះធ្វើឱ្យការប្រែប្រួលអាកាសធាតុមានភាពពាក់ព័ន្ធខ្លាំងទៅនឹង SRHR។[22] កត្តាផ្សេងទៀតដូចជា ភេទ អាយុ ទ្រព្យសម្បត្តិ ស្ថានភាពជនជាតិដើមភាគតិច និងពូជសាសន៍ គឺជាកត្តាដែលធ្វើឱ្យប្រជាជនងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ហើយការប្រែប្រួលអាកាសធាតុនឹងបង្កើនវិសមភាពដែលមានស្រាប់។ កំដៅ និងអំពើហិង្សាក្នុងគ្រួសារ និងបញ្ហាសុខភាពបន្តពូជ រួមទាំងការស្លាប់របស់ទារកនៅក្នុងផ្ទៃ និងកំឡុងពេលសម្រាល គឺមានទំនាក់ទំនងដោយផ្ទាល់។[23]

ប្រទេសកម្ពុជាមានគោលនយោបាយមួយចំនួន ដើម្បីជួយដល់វិស័យសុខាភិបាលទប់ទល់នឹងផលប៉ះពាល់ដែលកំពុងកើនឡើងទាំងនេះ ដូចជាផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការបន្សាំការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុងវិស័យសុខាភិបាលឆ្នាំ ២០១៩-២០២៣ និងនាយកដ្ឋានការពារសុខភាព (PMD) ក៏ដូចជាការបង្កើតផែនការសកម្មភាពការងារលើបញ្ហាការប្រែប្រួលអាកាសធាតុសម្រាប់សុខភាពសាធារណៈ (NCCAPPH) ឆ្នាំ២០១៩-២០១៣។ គេចាំបាច់ជំរុញការអនុវត្តផែនការទាំងនេះ

---

[20] ធនាគារអភិវឌ្ឍន៍អាស៊ី។ (២០២១)។ សេចក្តីសង្ខេបអំពីប្រទេសមានហានិភ័យអាកាសធាតុៈ កម្ពុជា។

[21]WHO 2023 ។

[22]Hashim, J., និង Z. Hashim ។ បម្រែបម្រួលអាកាសធាតុ ព្រឹត្តិការណ៍អាកាសធាតុខ្លាំង និងផលប៉ះពាល់សុខភាពមនុស្សនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ Asia Pacific Journal of Public Health លេខ 28 ។ 2 (2016): 8S–14S។ doi: 10.1177/1010539515599030។

[23] How to Confront Gender-Based Violence in a Warming World | Asian Development Blog (adb.org)

ដើម្បីពង្រឹងភាពធន់របស់ប្រព័ន្ធសុខាភិបាលទៅនឹងការប្រែប្រួលអាកាសធាតុ នេះរួមបញ្ចូលទាំងការធានាថា គ្រឹះស្ថានសុខាភិបាលអាចបន្តប្រតិបត្តិការ និងផ្តល់សេវាប្រកបដោយគុណភាព ទោះបីជាមានបញ្ហាប្រឈមផ្នែក បរិស្ថាន និង រៀបចំយ៉ាងសកម្ម សម្រាប់ឆ្លើយតបទៅនឹងការផ្លាស់ប្តូរ នៃនិន្នាការជំងឺដែលជាលទ្ធផលបានមកពី ការប្រែប្រួលអាកាសធាតុ។

### 1.2.3ការព្យាករណ៍អំពីការផ្លាស់ប្តូរប្រជាសាស្ត្រ

ប្រទេសកម្ពុជាទទួលបានអត្ថប្រយោជន៍ពី "អំណោយផល នៃប្រជាសាស្ត្រ" ដែល ៣១,៤% នៃប្រជាជន មានអាយុក្រោម ១៤ឆ្នាំ និងមានតែ ៤,៣% ប៉ុណ្ណោះដែលមានអាយុលើសពី ៦៥ឆ្នាំ។[24] ប្រជាជនកម្ពុជាស្ទើរតែ ១នាក់ក្នុងចំណោម ៣នាក់ គឺជាយុវជនដែលមានអាយុពី ១៥-៣០ ឆ្នាំ។[25] គោលនយោបាយជាតិស្តីពីប្រជាជន របស់កម្ពុជា ព្យាករណ៍អំពីការកើនឡើងនូវគ្រួសារ និងភាពចាស់នៃចំនួនប្រជាជន ដែលនឹងបង្កើតតម្រូវការ សុខភាពជាក់លាក់។ និន្នាការនេះ កើតឡើងអមជាមួយនឹងកម្រិតខ្ពស់ នៃអនក្ខរភាព បញ្ហាប្រឈមផ្នែក សេដ្ឋកិច្ច និងពិការភាពក្នុងចំណោមមនុស្សចាស់ ដែលធ្វើឱ្យភាពងាយរងគ្រោះរបស់ពួកគេកាន់តែធ្ងន់ធ្ងរ។

អត្រាមរណភាពខ្ពស់ក្នុងរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥-១៩៧៩ និងការរីកដុះដាល នៃកំណើតទារក បន្ទាប់ពីរបបខ្មែរក្រហម បានបណ្តាលឱ្យមានក្រុមវ័យដ៏ធំមួយកើតនៅទសវត្សរ៍ឆ្នាំ ១៩៨០ និងដើមទសវត្សរ៍ ឆ្នាំ ១៩៩០ ដែលនេះនឹងបង្កើតនូវចំនួនមនុស្សវ័យចាស់ដ៏ច្រើននៅពេលពួកគេមានអាយុចាស់។ ការធ្វើផែនការ ចំនួនប្រជាជន ត្រូវបន្តផ្តោតលើជម្រើសដើម្បីធានាថាបុគ្គល និងគ្រួសារអាចជ្រើសរើសថាតើគួរមានកូន ឬពេល ណាគួរមានកូន ដោយផ្អែកលើសមត្ថភាពរបស់ពួកគេក្នុងការចិញ្ចឹមកូនឱ្យទទួលបានការអប់រំ ការថែទាំសុខភាព ការទទួលបានការងារសមរម្យ និងលំនៅដ្ឋានសមរម្យ។ នៅទូទាំងអាស៊ីប៉ាស៊ីហ្វិក តំបន់នេះកំពុងត្រៀមរៀបចំ សម្រាប់ប្រជាជនវ័យចំណាស់ ហើយកំពុងប្រើវិធីសាស្ត្រ ភាគលាភប្រជាសាស្ត្រមួយចំនួន រួមទាំងការគាំទ្របែប "ភាគលាភប្រាក់" ដែលរួមមានការធានាថាប្រជាជនវ័យចំណាស់មានសុខភាពល្អ និងអាចរួមចំណែកដល់សេដ្ឋកិច្ច និងសង្គម។ គេក៏ត្រូវធានាផងដែរថា ភាគលាភប្រជាសាស្ត្របែបយេនឌ័រ (Gender demographic dividend) ត្រូវបានគាំទ្រដោយការបង្កើន លទ្ធភាពទទួលបានការងារសមរម្យសម្រាប់ស្ត្រី និងកុមារី តាមរយៈការធ្វើឱ្យ ប្រសើរឡើងនូវវិធានការសុខភាព ការអប់រំ និងសមភាពយេនឌ័រ។ ការធានាថាចំនួនប្រជាជនសរុបគ្រប់វ័យ ទទួលបាន ការគាំទ្រតាមរយៈការទទួលបានការថែទាំសុខភាព និងការអប់រំ និងការបណ្តុះបណ្តាលប្រកប ដោយគុណភាព អាចធ្វើឱ្យផលប៉ះពាល់ នៃចំនួនប្រជាជនវ័យចំណាស់មានការថយចុះ។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ៣ ចែងថា ប្រទេសនានាគួរតែ "ធានាបាននូវជីវិតដែល មានសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពមនុស្សគ្រប់វ័យ"។ តម្រូវការ SRHR មានពេញមួយជីវិតរបស់ មនុស្ស រួមទាំងមនុស្សវ័យចំណាស់ផងដែរ ទោះបីជាយុទ្ធសាស្ត្រ SRHR នៅកម្ពុជាកន្លងមកបានផ្តោតជាចម្បង លើស្ត្រីស្ថិតក្នុងវ័យបន្តពូជក៏ដោយ។ ស្ត្រីដែលធ្លាប់មានផ្ទៃពោះច្រើនដង និងទទួលបានការគាំទ្រមិនគ្រប់គ្រាន់ អំឡុងពេលមានផ្ទៃពោះ ពេលសម្រាល ឬក្រោយសម្រាល អាចជួបបញ្ហាប្រឈមសុខភាពក្នុងវ័យកាន់តែចាស់។ ជំងឺមិនឆ្លងនៅវ័យចំណាស់កាន់តែធ្ងន់ធ្ងរចំពោះស្ត្រី ដោយសារឥទ្ធិពល នៃការមានផ្ទៃពោះ និងការមានកូនក្នុង វ័យបន្តពូជ។ ការថយចុះអ័រម៉ូន ការផ្លាស់ប្តូរមុខងារអូវែ និងការផ្លាស់ប្តូររាងកាយ និងផ្លូវចិត្តដែលជាផ្នែកមួយ នៃ

[24]យូណេស្កូ។ (២០២៣)។ ការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ៖ សម្រាប់អ្នកសិក្សាដែលមានសុខភាពល្អ មានព័ត៌មាន និងពង្រឹងសិទ្ធិអំណាច។

[25] ជំរឿនទូទៅប្រជាជននៃព្រះរាជាណាចក្រកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ ២០១៩

រោគសញ្ញា នៃការអស់រដូវ ប៉ះពាល់ដល់ស្ត្រី ខណៈដែលបុរសវ័យចំណាស់ក៏ប្រឈមនឹងការផ្លាស់ប្តូរអ័រម៉ូន រាងកាយ និងផ្លូវចិត្តផងដែរ។ សម្រាប់ទាំងបុរស និងស្ត្រី ជំងឺមិនឆ្លង និងការប្រើថ្នាំវេជ្ជសាស្ត្រក្នុងវ័យចំណាស់ អាចប៉ះពាល់ដល់សុខភាពផងដែរ។[26] យុទ្ធសាស្ត្រ SRHR បាន ដាក់បញ្ចូលអន្តរាគមន៍នានា ដើម្បីគាំទ្រតម្រូវការ SRHR របស់មនុស្សចាស់ និងលទ្ធផលសុខភាពដែលពាក់ព័ន្ធ។

### 1.2.4 ការចំណាកស្រុក និងនគរូបនីយកម្ម

ក្នុងឆ្នាំ២០១៣ វិទ្យាស្ថានជាតិស្ថិតិ បានប៉ាន់ប្រមាណថាជិតមួយភាគបួន នៃចំនួនប្រជាជនកម្ពុជា (ប្រមាណជា ៤,១ លាននាក់) បានផ្លាស់ប្តូរទីតាំងស្នាក់នៅរបស់ពួកគេ ដែលចំនួននេះធំជាងការប៉ាន់ប្រមាណនៃអន្តោប្រវេសន៍អន្តរជាតិចំនួន ៤ដង។ ការធ្វើចំណាកស្រុកនៅក្នុងប្រទេស ភាគច្រើន គឺនៅតាមទីជនបទ (៥៨,៤%)[27]។ ការធ្វើចំណាកស្រុកទំនងជានឹងបន្តកើនឡើង ដោយសារការប្រែប្រួលអាកាសធាតុ និងនាំមកនូវបញ្ហាប្រឈមកាន់តែខ្លាំងឡើងចំពោះការផ្តល់សេវា SRHR និងមុខងារទូទៅ នៃប្រព័ន្ធថែទាំសុខភាព។ ជាឧទាហរណ៍ ការសិក្សានៅប្រទេសផ្សេងៗក្នុងអាស៊ីបង្ហាញថា ស្ត្រីចំណាកស្រុកវ័យក្មេង ទំនងជាធ្វើការរំលូតកូននៅពេលកូនក្នុងផ្ទៃមានអាយុច្រើនខែ និងមានអត្រាទាប នៃការថែទាំក្រោយការរំលូតកូន។[28]

ពលករចំណាកស្រុកខ្មែរជាច្រើនបានចំណាកស្រុកទៅក្រៅប្រទេស ដើម្បីឱកាសការងារ ហើយស្ត្រីចំណាកស្រុកដែលទៅក្រៅប្រទេស មានទំនោរក្នុងការរកប្រាក់ចំណូលបានតិចជាងបុរសចំណាកស្រុក ខណៈដែលពួកគេផ្ញើប្រាក់ត្រឡប់មកគ្រួសារបានច្រើនជាងបុរសចំណាកស្រុកដល់ទៅ ២០% ហើយផ្ញើប្រាក់ទៅផ្ទះទៀងទាត់ជាងបុរស និងផ្ញើចំនួនទឹកប្រាក់មួយផ្នែកធំពីប្រាក់ចំណូលដែលរកបានរបស់ពួកគេ ច្រើនជាងចំនួនដែលបុរសចំណាកស្រុកផ្ញើមកផ្ទះ។[29] នៅពេលដែលជនចំណាកស្រុកនៅក្រៅប្រទេសត្រឡប់មកកម្ពុជាវិញ ពាក់កណ្តាល នៃពួកគេប្រឈមនឹងឧបសគ្គផ្នែកហិរញ្ញវត្ថុ ជាពិសេសក្នុងបរិបទ នៃការថែទាំសុខភាព និងអាហារូបត្ថម្ភ ដែលនេះជាហេតុផលញឹកញាប់បំផុតទីពីរសម្រាប់ការខ្ចីប្រាក់ដើម្បីទិញអាហារ។

ការធ្វើចំណាកស្រុកទៅទីក្រុងនៅក្នុងប្រទេសកម្ពុជាក៏កំពុងកើតឡើង នាំឱ្យមានកំណើនទីក្រុង និងបន្តមានសន្ទុះហើយនេះនឹងទាមទារឱ្យមានវិធីសាស្ត្រសមស្របក្នុងការទទួលបានការថែទាំសុខភាព។ ស្ត្រីមានចំនួនច្រើនជាងបុរសក្នុងចំនួនប្រជាជនដែលធ្វើចំណាកស្រុកទៅកាន់តំបន់ទីក្រុង ដែលនេះមានន័យថាតំបន់ទីក្រុងគួរតែរំពឹងថានឹងមានតម្រូវការកើនឡើង សម្រាប់សេវា SRHR។ ការសិក្សាបង្ហាញថា ស្ត្រីនៅទីក្រុងនាពេលបច្ចុប្បន្ន ជាទូទៅខ្វះលទ្ធភាពទទួលបានសេវាសាធារណៈដែលមានគុណភាព ដែលនេះបង្កើនភាពងាយរងគ្រោះរបស់ពួកគេ។[30] ក្នុងអំឡុងពេល នៃការរាតត្បាត នៃជំងឺកូវីដ-១៩ ការសិក្សាមួយបានបង្ហាញថាអ្នកចូលរួមក្នុងការសិក្សានេះដែលរស់នៅក្នុងទីក្រុងដែលដឹងថាវាអាចទៅរួច ក្នុងការផ្លាស់ប្តូរមធ្យោបាយពន្យារកំណើត

[26] Banke-Thomas, A., Olorunsaiye, CZ & Yaya, S. "ការមិនទុកនរណាម្នាក់ចោល" ក៏ដាក់បញ្ចូលផងដែរនូវមនុស្សចាស់ និងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ របស់ពួកគេ៖ ការផ្តោតអារម្មណ៍ថ្មីសម្រាប់សុខភាពបន្តពូជ។ Reprod Health 17, 101 (2020)។ https://doi.org/10.1186/s12978-020-00944-5

[27]វិទ្យាស្ថានជាតិស្ថិតិកម្ពុជា (២០១៣)

[28]Mou J, Griffiths S, Fong H, Dawes M. 2013. សុខភាពរបស់ជនចំណាកស្រុកនៅជនបទ-ទីក្រុងរបស់ប្រទេសចិន និងក្រុមគ្រួសាររបស់ពួកគេ៖ ការពិនិត្យឡើងវិញ នៃអក្សរសិល្ប៍ពីឆ្នាំ 2000 ដល់ឆ្នាំ 2012 ។ ព្រឹត្តិបត្រវេជ្ជសាស្ត្រអង់គ្លេស; ១០៦:១៩–៤៣

[29]មូលនិធិប្រជាជនអង្គការសហប្រជាជាតិ។ (ឆ្នាំ ២០២០)។ ការវាយតម្លៃយ៉ាងរហ័សលើផលប៉ះពាល់សង្គម និងសុខភាពនៃមេរោគកូវីដ-១៩ ក្នុងចំណោមពលករចំណាកស្រុកដែលត្រឡប់មកកម្ពុជាវិញ។

[30]UNFPA ។ របាយការណ៍ស្តីពីនគរូបនីយកម្ម និងទំនាក់ទំនងរបស់វាទៅនឹងបញ្ហាសេដ្ឋកិច្ចសង្គម និងបរិស្ថាន (2014)។

គឺមានតិចជាងអ្នកចូលរួមនៅតាមជនបទ។[31] បុរសចំណាកស្រុកពីជនបទទៅទីក្រុង ក៏មានបញ្ហាបណ្តាលមកពីលទ្ធផល SRHR ដែលមិនល្អផងដែរ។ ពួកគេទំនងជាមិនសូវរាយការណ៍អំពីការប្រើស្រោមអនាម័យនៅពេលរួមភេទលើកដំបូង និងការប្រើមធ្យោបាយពន្យារកំណើតជាប់លាប់ជាមួយដៃគូដំបូងរបស់ពួកគេ បើធៀបនឹងអ្នកមិនចំណាកស្រុក និងជនចំណាកស្រុកពីទីក្រុងទៅទីក្រុង។[32]

សមាមាត្រដ៏សំខាន់ (៤៥%) នៃប្រជាជនទីក្រុងក្នុងប្រទេសកម្ពុជា រស់នៅក្នុងតំបន់អនាធិបតេយ្យ ដែលកំណត់ដោយ WHO[33]។ ការសិក្សានៅទូទាំងពិភពលោកបានបង្ហាញថាអ្នករស់នៅក្នុងតំបន់អនាធិបតេយ្យនៅក្នុងតំបន់ដែលមានប្រាក់ចំណូលទាប ប្រឈមមុខនឹងការលំបាកខ្លាំងបំផុតក្នុងការទទួលបានសេវា SRHR ដោយសារតែកត្តាដូចជា កង្វះពេលវេលាក្នុងការទទួលបានការថែទាំ ទីតាំងនៅឆ្ងាយពីសេវាដែលមានតម្លៃសមរម្យ និងមានគុណភាពខ្ពស់ និងការដាក់បញ្ចូលមិនបានគ្រប់ជ្រុងជ្រោយ នៃក្រុមមនុស្សទាំងនេះទៅក្នុងផែនការប្រព័ន្ធសុខភាពសាធារណៈ។ ទាំងនេះ ធ្វើឱ្យមានលទ្ធផលខ្ពស់ នៃការមិនទទួលបានតម្រូវការសេវាផែនការគ្រួសារ (FP) ។[34]

ចំណាកស្រុកពីជនបទទៅទីក្រុង ត្រូវបានជំរុញមួយផ្នែកធំដោយកត្តាឱកាសការងារ។ ការសិក្សាដែលធ្វើឡើងនៅទីក្រុងភ្នំពេញក្នុងឆ្នាំ ២០១៤ បានបង្ហាញថា ៥៨,៥% នៃស្ត្រីបានធ្វើចំណាកស្រុកមកទីក្រុងភ្នំពេញដើម្បីធ្វើការក្នុងរោងចក្រកាត់ដេរ (៣២,២%) អាជីវកម្មខ្នាតតូច (២៣,៤%) ការងារតាមផ្ទះ (១១,១%) និងវិស័យសេវាកម្ម និងកម្សាន្ត (១០,៣) %)។ ស្ត្រីទាំងនេះ "ងាយនឹងជួបការបោកបញ្ឆោត ការកេងប្រវ័ញ្ច ការបៀតបៀន និងអំពើហិង្សាដោយអ្នកដទៃជាពិសេសបុរស"។[35] កម្មកររោងចក្រកាត់ដេរភាគច្រើនជាស្ត្រីក្នុងវ័យបន្តពូជ ដែលបានធ្វើចំណាកស្រុកពីខេត្តជនបទមកទីក្រុងភ្នំពេញ ហើយលក្ខខណ្ឌការងារមិនល្អនៅក្នុងរោងចក្រនាំឱ្យស្ត្រីទាំងនេះពន្យារការមានកូន។ ពួកគេក៏ប្រឈមមុខនឹងហានិភ័យសុខភាពបន្តពូជ (SRHR) ជាក់លាក់ដោយសារតែបរិយាកាសការងារ មធ្យោបាយដឹកជញ្ជូនសម្រាប់ការធ្វើដំណើរ និងភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុ។[36]

### 1.2.5 បច្ចេកវិទ្យា និងឌីជីថលនីយកម្ម

វត្តមានកាន់តែច្រើនឡើង នៃបច្ចេកវិទ្យានៅក្នុងសង្គមកម្ពុជា និងនៅក្នុងប្រព័ន្ធសុខាភិបាល នឹងមានឥទ្ធិពលលើ SRHR ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ ការអភិវឌ្ឍន៍ទាំងនេះនាំមកនូវឱកាសដើម្បីបង្កើនចំណេះដឹង ការផ្លាស់ប្តូរឥរិយាបថ ការត្រួតពិនិត្យហានិភ័យ និងការផ្លាស់ប្តូរអាកប្បកិរិយាទាក់ទងនឹង SRHR ។ នៅក្នុងប្រទេសកម្ពុជា ឌីជីថលនីយកម្មត្រូវបានស្នើឡើងជាយុទ្ធសាស្ត្រដើម្បីធ្វើឱ្យមានសមភាព និងធ្វើឱ្យប្រសើរឡើងនូវ

[31]អ៊ុង, អិម, ឡាំ, អេស, ទូត, អេស et al ។ ការទទួលបាន និងការផ្តល់សេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជនៅក្នុងប្រទេសកម្ពុជា អំឡុងពេលជំងឺរាតត្បាតកូវីដ-១៩៖ ការសិក្សាវិធីសាស្ត្រចម្រុះនៃភាពខុសគ្នានៃទីក្រុង-ជនបទ។ Reprod Health 20, 74 (2023)។ https://doi.org/10.1186/s12978-023-01614-y

[32]Sudhinaraset M, Astone N, Blum RW ។ ការធ្វើចំណាកស្រុក និងការរួមភេទដោយមិនបានការពារនៅក្នុងទីក្រុងសៀងហៃ ប្រទេសចិន៖ ទំនាក់ទំនង នៃការប្រើប្រាស់ស្រោមអនាម័យ និងភាពជាប់លាប់ នៃការពន្យាកំណើតនៅទូទាំងយុវជនចំណាកស្រុក និងមិនមែនអន្តោប្រវេសន៍។ J Adolesc Health ។ 2012 ខែមីនា; 50 (3 ជំនួយ): S68-74 ។ doi: 10.1016/j.jadohealth.2011.12.007 ។ PMID: 22340859; PMCID: PMC4166512 ។

[33]WHO 2023

[34]Ganle, JK, Baatiema, L., Ayamah, P. et al ។ ការធ្វើផែនការគ្រួសារសម្រាប់តំបន់អនាធិបតេយ្យក្នុងទីក្រុងនៅក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម៖ ការពិនិត្យវិសាលភាពនៃអន្តរាគមន៍ ឬគំរូ នៃការផ្តល់សេវា និងផលប៉ះពាល់របស់វា។ Int J Equity Health 20, 186 (2021) ។ https://doi.org/10.1186/s12939-021-01518-y

[35]UNFPA ។ របាយការណ៍ស្តីពីនគរូបនីយកម្ម និងទំនាក់ទំនងរបស់វាទៅនឹងបញ្ហាសេដ្ឋកិច្ចសង្គម និងបរិស្ថាន (2014)។

[36]មូលនិធិប្រជាជនអង្គការសហប្រជាជាតិ។ (២០២៣)។ បទដ្ឋានសង្គមដែលបង្កគ្រោះថ្នាក់ និងអំពើហិង្សាផ្អែកលើយេនឌ័រនៅកម្ពុជា។ គន្លងនិទ្ទេសដែលបានកំណត់ចំណាំ។

លទ្ធភាពទទួលបានសេវាសម្រាប់ប្រជាជនដែលមិនទាន់ទទួលបានការគ្របដណ្តប់។ ការប្រឹក្សាព័ត៌មានសុខភាពតាមរយៈទូរស័ព្ទ (Telehealth) ទទួលបាននូវភាពទាក់ទាញ។

"កម្មវិធីសុខភាពយុវជន" គឺជាកម្មវិធីទូរស័ព្ទដែលផ្តល់នូវការចូលទៅរកព័ត៌មានអំពីសេវាសំខាន់ៗ ដែលអាចទុកចិត្តបាន និងព័ត៌មានជាក់ស្តែងទាក់ទងនឹង SRHR និងសេវាការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ (CSE) ក៏ដូចជាព័ត៌មានអំពីយេនឌ័រ និងការគាំទ្រសុខភាពផ្លូវចិត្ត (MHPSS) ដោយឥតគិតថ្លៃសម្រាប់ក្មេងជំទង់ និងមនុស្សវ័យក្មេង ។ លើសពីនេះ "កម្មវិធីសុវត្ថិភាព" គឺជាកម្មវិធីទូរស័ព្ទ ដែលកំពុងត្រូវបានបង្កើតឡើងដើម្បីផ្តល់ព័ត៌មាន អំពីអំពើហិង្សាផ្អែកលើយេនឌ័រ (GBV) និងសេវាដែលមានសម្រាប់គាំទ្រជនរងគ្រោះ ដែលនៅរស់រានមានជីវិត និងការគាំទ្រសេវាសុខភាព។

ការប្រឹក្សាអំពីការថែទាំវេជ្ជសាស្ត្រពីចម្ងាយ (Telemedicine) សម្រាប់សេវា និងព័ត៌មានសំខាន់ៗទាក់ទងនឹង SRHR ដែលបច្ចុប្បន្នកំណត់គោលដៅភូមិនៅក្នុងតំបន់ដាច់ស្រយាល និងទីតាំងក្នុងតំបន់ភាគឦសានគឺកំពុងអនុវត្ត ហើយចំនួនអ្នកប្រើកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ កម្មវិធីនេះត្រូវបានបង្កើតឡើងក្នុងអំឡុងពេលជំងឺរាតត្បាត COVID-19 ហើយនៅបន្តដំណើរការសម្រាប់បម្រើដល់ស្ត្រី គូស្វាមីភរិយា និងបុគ្គលដែលមិនអាចទៅទទួលសេវាកម្មដោយផ្ទាល់បានដោយសារហេតុផលផ្សេងៗគ្នា។

វេទិកាសិក្សាអំពីសេវា SRHR សំខាន់ៗតាមប្រព័ន្ធអេឡិចត្រូនិក ក៏ត្រូវបានបង្កើតឡើងផងដែរដើម្បីឆ្លើយតបទៅនឹងជំងឺរាតត្បាត COVID-19 និងប្រើដើម្បីឱ្យអ្នកផ្តល់សេវាថែទាំសុខភាពបន្តអភិវឌ្ឍន៍វិជ្ជាជីវៈរបស់ពួកគេ។ ប្រធានបទកាន់តែច្រើនត្រូវបានដាក់បញ្ចូល ហើយចំនួនអ្នកតាមដាន និងអ្នកសិក្សាកាន់តែច្រើនបានចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអនឡាញ។

ទោះជាយ៉ាងនេះក្តី បច្ចេកវិទ្យា និងឌីជីថលនីយកម្ម ក៏មានហានិភ័យផងដែរ រួមមានដូចជាការរំលោភបំពានព័ត៌មានអំពីសុខភាពរបស់បុគ្គល ការរីករាលដាលយ៉ាងរហ័ស នៃព័ត៌មានមិនពិតតាមអ៊ីនធឺណិត ការព្រួយបារម្ភអំពីគុណភាពសេវាកម្មដែលផ្តល់ពីចម្ងាយ និងការមិនរាប់បញ្ចូលអ្នកដែលមិនមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យា។ នេះជាការពិត ជាពិសេសព័ត៌មានអំពីស្ថានភាពសុខភាពរបស់អ្នកជំងឺ ដែលនាំឱ្យមានការមាក់ងាយក្នុងសង្គម និងបង្កឱ្យមានការរើសអើង ដូចជាមេរោគអេដស៍។ នៅក្នុងប្រទេសកម្ពុជា បទប្បញ្ញត្តិស្តីពីទិន្នន័យជុំវិញការធ្វើតេស្ត និងព្យាបាលមេរោគអេដស៍ ត្រូវបានដាក់ឱ្យដំណើរការដើម្បីការពារឯកជនភាព និងសុវត្ថិភាពទិន្នន័យ។ ទោះបីជាយ៉ាងនេះក្តី ប្រព័ន្ធទិន្នន័យផ្សេងគ្នាត្រូវបានប្រើប្រាស់សម្រាប់មេរោគអេដស៍ ដោយសារតែកម្មវិធីនេះផ្តោតទៅលើជំងឺជាក់លាក់ ការផ្តល់មូលនិធិ និងការត្រួតពិនិត្យ ហើយយន្តការការពារទិន្នន័យដ៏តឹងរ៉ឹងទាំងនេះ មិនត្រូវបានអនុវត្តចំពោះសេវាកម្ម SRHR ផ្សេងទៀតមានហានិភ័យ នៃការមាក់ងាយដូចជាការធ្វើផែនការគ្រួសារ ឬការរំលូតកូននោះទេ។

យុទ្ធសាស្ត្រជាតិស្តីពីសុខភាពឌីជីថល ២០២១-២០៣០ បច្ចុប្បន្នកំពុងត្រូវបានព្រាងហើយយុទ្ធសាស្ត្រនេះនឹងដាក់បញ្ចូលផែនការអភិវឌ្ឍនូវប្រព័ន្ធកំណត់ត្រាវេជ្ជសាស្ត្រតាមអេឡិចត្រូនិក។ យុទ្ធសាស្ត្រនេះទទួលស្គាល់ពីសារៈសំខាន់ នៃការអនុវត្តប្រព័ន្ធនេះតាមរយៈកិច្ចសហការពហុដៃគូ។ ឧទាហរណ៍ ឱកាសជាច្រើនសម្រាប់ការចូលរួមពីវិស័យឯកជនត្រូវបានស្នើឡើង ដូចដែលបានរៀបរាប់នៅក្នុងយុទ្ធសាស្ត្រអាទិភាពទី៩ ស្តីពីភាពជាដៃគូ រួមមានការចូលរួមរបស់ពួកគេនៅក្នុងគណៈកម្មាធិការដឹកនាំសុខភាពឌីជីថល (DHSC) ការអនុវត្តកិច្ចព្រមព្រៀងចែករំលែកទិន្នន័យ ការផ្តល់មូលនិធិ ទិន្នន័យគ្លីនិកដែលមានកាតព្វកិច្ច និងឯកសារព័ត៌មាន

សុខភាព ការចែករំលែក និងការរាយការណ៍ ការផ្តល់អាជ្ញាប័ណ្ណ និងការផ្តល់អាជ្ញាប័ណ្ណឡើងវិញដល់គ្រឹះស្ថានឯកជន និងការអនុវត្តគោលការណ៍ណែនាំសន្តិសុខតាមអ៊ីនធឺណិត។

### 1.2.6 ជំងឺរាតត្បាតនាពេលអនាគត

ការវិនិយោគក្នុងវិស័យថែទាំសុខភាព គឺចាំបាច់ក្នុងការពង្រឹងសមត្ថភាពបន្សាំខ្លួន និងត្រៀមរៀបចំសម្រាប់ការផ្ទុះឡើង នៃជំងឺនាពេលអនាគត។ ជំងឺរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច និងវិស័យសុខាភិបាលកម្ពុជា បង្កើនផលវិបាក នៃបទដ្ឋានសង្គម និងយេនឌ័រ។ ខ្សែចង្វាក់ផ្គត់ផ្គង់ត្រូវបានកាត់ផ្តាច់ បណ្តាលឱ្យមានការពន្យារពេល និងកង្វះខាតផលិតផលចាំបាច់សម្រាប់ SRHR ។ ជាញឹកញាប់អ្នកផ្តល់សេវាសុខភាព មិនអាចបន្តផ្តល់ការថែទាំសុខភាពប្រកបដោយការគោរព និងគុណភាពខ្ពស់ដល់អ្នកជំងឺដែលកំពុងស្វែងរកសេវាថែទាំសុខភាព ។ ជំងឺរាតត្បាតធ្វើឱ្យស្ត្រីមិនសូវស្វែងរកសេវា ព្រោះវាបានប៉ះពាល់ដល់ធនធានៈ និងលទ្ធភាពក្នុងការស្វែងរកសេវារបស់ពួកគេ។[37] ជំងឺរាតត្បាត COVID-19 ក៏បានរំខានដល់លទ្ធភាពទទួលបានសេវារៀបចំផែនការគ្រួសារ ដែលនេះបណ្តាលឱ្យមានការមានគភ៌ដោយអចេតនា និងការកើនឡើង នៃករណីអំពើហិង្សាផ្អែកលើយេនឌ័រ។[38]

លទ្ធភាព នៃការមានវិបត្តិសុខភាពនាពេលអនាគតគឺខ្ពស់ ជាពិសេសនៅពេលមានការប្រែប្រួលអាកាសធាតុ។ ដូចនេះ ប្រព័ន្ធសុខាភិបាលត្រូវតែវិនិយោគលើភាពធន់ ប្រព័ន្ធប្រកាសអាសន្នជាមុន និងការសម្របខ្លួនដើម្បីបង្កើនសមត្ថភាពរបស់ខ្លួន ដើម្បីទ្រទ្រង់ការផ្តល់សេវាដែលមានគុណភាពខ្ពស់ក្នុងអំឡុងពេលមានវិបត្តិសុខភាពនាពេលអនាគត ជាពិសេសសម្រាប់អ្នកដែលត្រូវការសេវាច្រើនបំផុត។

## 1.3 ការផ្សារភ្ជាប់ និងធ្វើឱ្យសមស្រប

NSSRHR គឺជាយុទ្ធសាស្ត្រអនុវិស័យដែលផ្តោតជាពិសេសលើសុខភាពបន្តពូជ សុខភាពផ្លូវភេទ និងសិទ្ធិ។ យុទ្ធសាស្ត្រនេះ រួមចំណែកដល់គោលនយោបាយ គោលការណ៍ណែនាំ និងផែនការយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនទៀត។ បញ្ជីខាងក្រោមបង្ហាញពីឯកសារសំខាន់ៗ ប៉ុន្តែមិនពេញលេញនោះទេ ៖

*ពហុវិស័យ*

- រាជរដ្ឋាភិបាលកម្ពុជា (២០១៧) ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៥-២០២៥)។
- យុទ្ធសាស្ត្របញ្ចកោណឆ្នាំ (២០២៤-២០២៨) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០២៤-២០២៨)។
- ក្រសួងផែនការ (២០២២) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០។
- ក្រសួងកិច្ចការនារី (២០២០) ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣)។
- ក្រសួងផែនការ (២០១៦)គោលនយោបាយជាតិស្តីពីប្រជាជន (២០១៦-២០៣០)។

---

[37]Nadia Akseer, Goutham Kandru, Emily C Keats និង Zulfiqar A Bhutta ។ 2020. យុទ្ធសាស្ត្រកាត់បន្ថយការរាតត្បាត COVID-19៖ ផលប៉ះពាល់សម្រាប់សុខភាពមាតា និងទារក និងអាហារូបត្ថម្ភ។ The American Journal of Clinical Nutrition 112, 2:251–256។

[38]អង្គការសុខភាពពិភពលោក។ (២០២៣)។ សង្ខេបបច្ចេកទេស៖ ការវិនិយោគលើសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិ៖ ជាគុសំខាន់ៗនៃការគ្របដណ្តប់សុខភាពជាសកល។

- ក្រសួងកិច្ចការនារី (២០២០) នារីរតនៈ ៥ ផែនការយុទ្ធសាស្រ្តប្រាំឆ្នាំសម្រាប់ការពង្រឹងការបញ្រ្ជាបយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចរបស់ស្រ្តី (២០១៩-២០២៣)។
- ក្រសួងអប់រំ យុវជន និងកីឡា (២០២២) ផែនការសកម្មភាពជាតិសម្រាប់សុខភាពនៅតាមសាលារៀន (២០២១-២០៣០)។
- ក្រសួងអប់រំ យុវជន និងកីឡា (២០២២) ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍន៍យុវជនកម្ពុជា (២០២២-២០២៦)។

*វិស័យសុខាភិបាល*

- ការប្តេជ្ញាចិត្តជាតិចំពោះ ICPD+25 នៅណៃរ៉ូប៊ីក្នុងឆ្នាំ ២០១៩។
- ក្រសួងសុខាភិបាល (២០២៣) ផែនការយុទ្ធសាស្រ្តសុខភាព (២០២៣-២០៣៣) សង្ខេបទិដ្ឋភាពទូទៅ ។
- ក្រសួងសុខាភិបាល (២០២៣) ក្របខ័ណ្ឌការអនុវត្តកម្មវិធីជំរុញការថែទាំសុខភាពបឋម (PHC-BIF)
- ក្រសួងសុខាភិបាល (២០២៥) ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក (២០២៥-២០៣០)។
- ក្រសួងសុខាភិបាល (២០១៩) ផែនការសកម្មភាពជាតិសម្រាប់ការបង្ការជំងឺមហារីកមាត់ស្បូន និងការគ្រប់គ្រង ឆ្នាំ(២០១៩-២០២៣) ។
- ក្រសួងសុខាភិបាល (២០២២) ផែនការយុទ្ធសាស្រ្តជាតិសម្រាប់ការបង្ការ និងគ្រប់គ្រងជំងឺមិនឆ្លង (២០២២-២០៣០)។
- ក្រសួងសុខាភិបាល (២០២០) ផែនការយុទ្ធសាស្រ្តជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព (២០២០-២០២៤)។
- ក្រសួងសុខាភិបាល (២០២១) ផែនការយុទ្ធសាស្រ្តជាតិសម្រាប់ការបង្ការការចម្លងពីម្តាយទៅកូន នៃមេរោគអេដស៍ មេរោគស្វាយ និងជំងឺរលាកថ្លើមប្រភេទ B (២០២១-២០២៥)។
- ក្រសួងសុខាភិបាល (២០១៤) គោលការណ៍ណែនាំជាតិសម្រាប់ការគ្រប់គ្រងអំពើហិង្សាលើស្រ្តី និងកុមារនៅក្នុងប្រព័ន្ធសុខាភិបាល។

## 2. វិធីសាស្រ្តអភិវឌ្ឍន៍យុទ្ធសាស្រ្ត

NSSRHR ២០២៥-២០៣០ ត្រូវបានបង្កើតឡើងតាមរយៈដំណើរការពិគ្រោះយោបល់ និងព័ត៌មានបានពីការពិនិត្យឡើងវិញយ៉ាងម៉ត់ចត់នៃ NSSRHR ឆ្នាំ ២០១៧-២០២៣ និងឯកសារពាក់ព័ន្ធ។

<u>ការពិនិត្យឯកសារពាក់ព័ន្ធ និងវឌ្ឍនភាព</u>

ដើម្បីធានាបានថាយុទ្ធសាស្រ្តនេះឆ្លុះបញ្ចាំងពីការអនុវត្តល្អបំផុតជាសកល និងថ្នាក់ជាតិ ហើយសមស្របទៅនឹងយុទ្ធសាស្រ្តពហុវិស័យ ការប្តេជ្ញាចិត្ត និងយុទ្ធសាស្រ្តក្នុងវិស័យសុខាភិបាលដែលពាក់ព័ន្ធនៅក្នុងប្រទេស

កម្ពុជា និងដើម្បីឆ្លុះបញ្ចាំងទៅនឹងលទ្ធផលដែលបានមកពីការត្រួតពិនិត្យ និងវាយតម្លៃក្នុងប្រទេស។ ដំណើរការអភិវឌ្ឍន៍យុទ្ធសាស្ត្រនេះ ត្រូវបានបង្កើតឡើងជាមួយនឹងការពិនិត្យឡើងវិញនូវឯកសារពាក់ព័ន្ធនានា រួមមានផែនការ និងយុទ្ធសាស្ត្រជាតិ របាយការណ៍ត្រួតពិនិត្យយុទ្ធសាស្ត្រ អត្ថបទសិក្សាដែលបានពិនិត្យដោយបញ្ញវន្ត និងការសិក្សាពាក់ព័ន្ធដែលបានធ្វើឡើងតាំងពីឆ្នាំ២០១៧។

លើសពីនេះក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃរបស់ NSSRHR ពីមុនត្រូវបានធ្វើបច្ចុប្បន្នភាព និងពិនិត្យដើម្បីវាយតម្លៃវឌ្ឍនភាព ដែលសម្រេចបានពីការអនុវត្តកម្មវិធីអន្តរាគមន៍ ចាប់តាំងពីគ្រាដំបូង។ ភស្តុតាងនេះផ្តល់ព័ត៌មានសម្រាប់ការចាត់ថ្នាក់ នៃប្រភេទអន្តរាគមន៍នីមួយៗទៅតាមវឌ្ឍនភាពរបស់ពួកគេ ឱ្យមានភាពប្រសើរឡើង គ្មានការផ្លាស់ប្តូរ ឬកាន់តែអាក្រក់ទៅៗ។ បន្ថែមពីលើការពិនិត្យមើលវឌ្ឍនភាពបែបបរិមាណនេះ ការពិពណ៌នាបែបគុណភាព នៃវឌ្ឍនភាពដែលសម្រេចបាននៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានធ្វើឡើងដំបូងក្នុងឆ្នាំ២០២២ ក្នុងអំឡុងពេល នៃដំណើរការពង្រីកយុទ្ធសាស្ត្រ ត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពសម្រាប់ឆ្នាំ ២០២៣។

<u>វិធីសាស្ត្រពិគ្រោះយោបល់</u>

ទិដ្ឋភាពដ៏សំខាន់ នៃដំណើរការអភិវឌ្ឍយុទ្ធសាស្ត្រ គឺដើម្បីប្រមូលយកព័ត៌មានស៊ីជម្រៅពីភាគីពាក់ព័ន្ធជុំវិញតម្រូវការ SRHR របស់ប្រជាជនកម្ពុជា ជាពិសេសអ្នកដែលត្រូវបានទុកចោល និងមិនទាន់ទទួលបានការគ្របដណ្តប់សេវា និងប្រមូលបទពិសោធន៍អំពីការអនុវត្តល្អបំផុតដើម្បីជានាប្រសិទ្ធភាព និងប្រសិទ្ធផលរបស់ព័ត៌មាន និងការផ្តល់សេវា SRHR ក៏ដូចជាការកំណត់អាទិភាពតាមធនធានមានកំណត់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រ។

សិក្ខាសាលាពិគ្រោះយោបល់ជាបន្តបន្ទាប់ត្រូវបានធ្វើឡើង ៖

**សិក្ខាសាលាលើកទីមួយ** ត្រូវបានធ្វើឡើងនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ហើយបានផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធក្នុងការផ្តល់យោបល់លើវិធីសាស្ត្រដែលបានស្នើឡើង ការរកឃើញបឋមពីការពិនិត្យឯកសារពាក់ព័ន្ធ ដើម្បីផ្តល់ជាព័ត៌មានសម្រាប់អភិវឌ្ឍន៍យុទ្ធសាស្ត្របន្ទាប់ និងឯកសារបន្ថែមផ្សេងៗទៀតដែលនឹងត្រូវដាក់បញ្ចូលក្នុងការត្រួតពិនិត្យ។

**សិក្ខាសាលាលើកទីពីរ** ត្រូវបានធ្វើឡើងដោយផ្ទាល់នៅរាជធានីភ្នំពេញនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។ ក្នុងសិក្ខាសាលានេះ សិក្ខាកាមបានផ្តល់នូវធាតុចូលលើរចនាសម្ព័ន្ធដែលបានស្នើឡើង របកគំហើញពីការស្រាវជ្រាវផ្នែកអក្សរសាស្ត្រដ៏ទូលំទូលាយ បញ្ហាប្រឈម និងផ្នែកអន្តរាគមន៍សំខាន់ៗ។ អ្នកចូលរួមសិក្ខាសាលារួមមានមន្ត្រីសុខាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាគណៈធ្មបកម្ពុជា បុគ្គលិកដៃគូអភិវឌ្ឍន៍ដែលធ្វើការនៅក្នុងវិស័យ SRHR អង្គការសង្គមស៊ីវិល។

សេចក្តីព្រាងយុទ្ធសាស្ត្រត្រូវបានចែករំលែកទៅដល់ភាគីពាក់ព័ន្ធតាមរយៈអ៊ីមែល មុនពេលសិក្ខាសាលាដើម្បីជួយសម្រួលដល់ការពិនិត្យឡើងវិញ និងការផ្តល់មតិយោបល់ឱ្យស៊ីជម្រៅ។ បន្ទាប់ពីសិក្ខាសាលា មតិយោបល់ត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារយុទ្ធសាស្ត្រ និងចែកចាយ ត្រឡប់ទៅភាគីពាក់ព័ន្ធវិញ។

សិក្ខាសាលាលើកទីបី ត្រូវបានប្រារព្ធឡើងតាមអ៊ីនធើណិតនៅក្នុងឆ្នាំ២០២៤ ដើម្បីបង្ហាញកំណែចុងក្រោយ នៃយុទ្ធសាស្ត្រ និងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ (M&E) ដើម្បីទទួលបានការផ្ដល់សុពលភាពពីភាគីពាក់ព័ន្ធទាំងអស់។

<u>ភាគីពាក់ព័ន្ធដែលបានពិគ្រោះយោបល់</u>

ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងជាមួយនឹង NRHP សមាជិក នៃអនុក្រុមការងារ បច្ចេកទេសសុខភាពមាតា និងទារក NMCHC (MCH Sub-TWG) អង្គការសង្គមស៊ីវិល (CSOs) និងសមាជិក នៃសមាគមដែលជាសមាជិកពាក់ព័ន្ធ។ ជាពិសេសភាគីពាក់ព័ន្ធដែលបានពិគ្រោះយោបល់ គឺជាតំណាង នៃក្រុមដូចខាងក្រោម៖

- តំណាងរដ្ឋាភិបាលកម្ពុជា រួមមានតំណាងក្រសួងសុខាភិបាលមកពី NMCHC កម្មវិធីជាតិ និងមជ្ឈមណ្ឌលជាតិពាក់ព័ន្ធផ្សេងៗទៀត ដែលមានឥទ្ធិពលលើព័ត៌មាន និងសេវា SRHR
- ទីភ្នាក់ងារអង្គការសហប្រជាជាតិផ្ដល់ជំនួយបច្ចេកទេសដល់ NMCHC និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតលើបញ្ហាទាក់ទងនឹង SRHR
- អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ក្នុងស្រុក ដៃគូផ្សេងទៀតដែលផ្ដល់ជំនួយបច្ចេកទេស ការអនុវត្តកម្មវិធីទាក់ទងនឹង SRHR រួមទាំងបញ្ហាសុខភាពដែលពាក់ព័ន្ធ
- អ្នកផ្ដល់សេវាថែទាំសុខភាព រួមទាំងឆ្មបផងដែរ
- គ្រឹះស្ថានសុខភាពឯកជនដែលផ្ដល់សេវា SRHR
- ក្មេងស្រី និងក្មេងប្រុសជំទង់ដែលមានអាយុពី ១២-១៩ ឆ្នាំ ទាំងក្នុងសាលា និងក្រៅសាលា
- ជនជាតិដើមភាគតិច រួមទាំងយុវជន និងស្ត្រី
- អ្នកដឹកនាំប្រពៃណី សាសនា និងជំនឿ
- ជនពិការ រួមទាំងស្ត្រីមានអាយុក្នុងវ័យបន្តពូជ
- អ្នកផ្ទុកមេរោគអេដស៍
- ស្ត្រីមានអាយុក្នុងវ័យបន្តពូជ
- ក្រុមប្រជាជន LGBTQI+
- ប្រជាជនសំខាន់ៗ រួមមានអ្នករកស៊ីផ្លូវភេទ អ្នកដែលមានបញ្ហាប្រើប្រាស់សារធាតុញៀន អ្នកនៅក្នុងពន្ធនាគារ
- អ្នកដែលមានបទពិសោធន៍ទទួលរងអំពើហិង្សាផ្អែកលើយេនឌ័រដោយផ្ទាល់ និងមានបញ្ហាប្រឈមនឹងសុខភាពផ្លូវចិត្តដែលទាក់ទងទៅ SRHR ។

# 3. ចក្ខុវិស័យជាយុទ្ធសាស្ត្រ គោលការណ៍ កត្តាជំរុញល្បឿន និងអាទិភាព

## 3.1 គោលដៅយុទ្ធសាស្ត្រ

នៅឆ្នាំ ២០៣០ ស្ត្រី បុរស ក្មេងជំទង់ទាំងអស់ និងជាពិសេសអ្នកដែលមិនទាន់ទទួលបានការគ្របដណ្តប់សេវានៅក្នុងគ្រប់ស្ថានភាពទាំងអស់ នឹងទទួលបានពេញលេញ និងប្រកបដោយសមធម៌នូវ SRHR ដែលមានលក្ខណៈប្រកបដោយការគោរពសិទ្ធិមនុស្ស ការផ្លាស់ប្តូរយេនឌ័រ បរិយាបន្ន សមាហរណកម្ម និងគុណភាពខ្ពស់ តាមរយៈប្រព័ន្ធសុខាភិបាលដែលមានភាពធន់ ដើម្បីបំពេញសក្តានុពលរបស់ពួកគេ ដែលជាមូលដ្ឋានគ្រឹះនៃការថែទាំសុខភាពបឋម និងការគ្របដណ្តប់សុខភាពជាសកល។

## 3.2 គោលការណ៍ណែនាំ

### 3.2.1 ផ្អែកលើសិទ្ធិ

ស្មើភាពគ្នា និងមិនរើសអើង

ដើម្បីធានាបាននូវការផ្តល់សេវាថែទាំសុខភាពប្រកបដោយសមធម៌ វាជាការចាំបាច់ដែលសេវាសុខភាពគ្មានការរើសអើង ធានានូវលទ្ធភាពទទួលបានព័ត៌មាន និងសេវាកម្មប្រកបដោយគុណភាពសម្រាប់បុគ្គលគ្រប់រូប ដោយមិនគិតពីអាយុ ជាតិសាសន៍ ភេទ វណ្ណៈ សាសនា ទីក្រុង ជនបទ សេដ្ឋកិច្ច ស្ថានភាពអាពាហ៍ពិពាហ៍ ឬក្រុមងាយរងគ្រោះផ្សេងទៀត ដោយមិនលំអៀង។ តម្រូវឱ្យមានការប្តេជ្ញាចិត្តចំពោះភាពយុត្តិធម៌ ប្រើប្រាស់វិធីសាស្ត្រប្រសព្វគ្នា ដើម្បីកុំឱ្យនរណាម្នាក់ត្រូវបានទុកចោល។

ភាពអាចរកបាន

ជាការចាំបាច់ដែលត្រូវតែមានសេវាកម្មគ្រប់ជ្រុងជ្រោយ រួមមានវិធីពន្យារកំណើតចម្រុះ (៦-១០) ដែលមានរាយក្នុងបញ្ជីឱសថសំខាន់ៗ។ ជាងនេះទៅទៀត ការផ្តល់នូវចំនួនគ្រប់គ្រាន់ នៃទីតាំងផ្តល់សេវាដែលមានមុខងាររៀបចំចែកចាយ ដោយផ្អែកលើការវាយតម្លៃអំពីតម្រូវការ គឺចាំបាច់សម្រាប់ការធានាបាននូវភាពងាយស្រួល និងការរួមបញ្ចូលបុគ្គលទាំងអស់។

អាចចូលប្រើបាន

ព័ត៌មានអំពី SRHR ត្រូវតែមានជាភាសាដែលពាក់ព័ន្ធ ដោយប្រើពាក្យដែលមនុស្សទាំងអស់អាចយល់បាន និងក្នុងទម្រង់សមរម្យសម្រាប់ពួកគេដើម្បីទទួលបានព័ត៌មាន (ឧទាហរណ៍ ដូចជាការសរសេរ វីដេអូ សំឡេង អក្សរស្ទាប)។ ប្រជាជនត្រូវតែមានលទ្ធភាពទទួលបានសេវាទៅតាមភូមិសាស្ត្រ និងហិរញ្ញវត្ថុក្នុងកាលៈទេសៈប្រកបដោយភាពងាយស្រួល ក៏ដូចជាការទទួលបានព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងគោលនយោបាយសមស្រប។ លទ្ធភាពទទួលបានសេវា ក៏ជាក់បញ្ចូលផងដែរនូវសុវត្ថិភាព នៃមធ្យោបាយពន្យារកំណើត ការសង្គ្រោះជីវិតមាតា និងទារក និងការផ្គត់ផ្គង់ទៅកាន់គ្រឹះស្ថានចែកចាយដោយគ្មានការដាច់ស្តុក ជាមួយនឹងការធានាបាននូវការផ្គត់ផ្គង់នៅពេលចាំបាច់។ ម៉ោងពេលផ្តល់សេវា ប្រកបដោយភាពងាយស្រួល ធានាបានថាសេវាអាចរកបាន រួមមានសម្រាប់ក្មេងជំទង់ និងស្ត្រីមានផ្ទៃពោះដែលត្រូវការសេវា២៤ម៉ោងក្នុង១ថ្ងៃ និងពេញមួយសប្តាហ៍។ លើសពីនេះ សមាហរណកម្មសេវា ធានាឱ្យប្រជាជនទទួលបានសេវាសុខភាពជាបន្តបន្ទាប់ដែលសម្របសម្រួលនៅគ្រប់កម្រិត និងកន្លែងថែទាំផ្សេងៗគ្នា ទាំងក្នុង និងលើសពីបរិបទវិស័យសុខាភិបាល និងពេញ

មួយជីវិត។ ឧទាហរណ៍ សេវារៀបចំផែនការគ្រួសារ គួរតែត្រូវបានផ្តល់ជូនក្នុងអំឡុងពេលសម្រាលកូន និងក្រោយសម្រាល។

អាចទទួលយកបាន

ដើម្បីធានាថាសេវាថែទាំសុខភាពអាចទទួលយកបានសម្រាប់អ្នកប្រើប្រាស់ គេចាំបាច់ពិចារណាលើកត្តាផ្សេងៗ រួមមានការទទួលយកសេវា SRHR ដោយសហគមន៍ និងវិធីសាស្ត្រជាក់លាក់ ការចូលរួមរបស់សហគមន៍ និងគ្រួសារក្នុងការគាំទ្រសិទ្ធិរបស់ស្ត្រីក្នុងការជ្រើសរើសសេវា SRHR ដែលមិនបង្កផលវិបាកដល់ពួកគេ ក៏ដូចជាការពេញចិត្តរបស់ពួកគេចំពោះសេវា SRHR ។

គុណភាពខ្ពស់

សេវាកម្មត្រូវតែមានគុណភាពខ្ពស់ រួមមានគុណភាព និងសមត្ថភាពបច្ចេកទេសខ្ពស់ ទំនាក់ទំនងរវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវាប្រកបដោយបរិយាបន្ន និងការប្រឹក្សាជាមួយអតិថិជនដែលធានាភាពឯកជន សេចក្តីថ្លៃថ្នូរ និងការគោរពក្នុងអំឡុងពេលផ្តល់សេវា។ ការបន្តនៃការថែទាំ ក៏មានផលប៉ះពាល់ដល់គុណភាពសេវាកម្មផងដែរ ព្រោះវាមានឥទ្ធិពលលើដំណើរការនៃការថែទាំដែលត្រូវបានទទួល (ឧទាហរណ៍ ភាពទាន់ពេលវេលា) និងលទ្ធផល នៃការថែទាំ (ឧទាហរណ៍ កាត់បន្ថយចំនួនអតិថិជនដែលខកខានក្នុងការតាមដាន)។

ឯកជនភាព និងការសម្ងាត់

សកម្មភាពរបស់អតិថិជនមិនគួរត្រូវបានសង្កេតឃើញ ឬស្តាប់ដោយនរណាម្នាក់ផ្សេងទៀតដោយគ្មានការយល់ព្រមពីអតិថិជននោះទេ។ កំណត់ត្រាអំពីអតិថិជន មិនគួរត្រូវបានចែករំលែកដោយនរណាម្នាក់ឡើយ ហើយកំណត់ត្រាទាំងនោះមិនគួរឱ្យអ្នកផ្សេងអាចចូលទៅរកបាននៅតាមអ៊ីនធឺណិតដោយងាយស្រួលឡើយ (រួមទាំងតាមរយៈការបំពានលើសុវត្ថិភាពមូលដ្ឋានទិន្នន័យ) ដូច្នេះព័ត៌មានអតិថិជនមិនត្រូវបានបង្ហាញឱ្យអ្នកផ្សេងៗដឹងនោះទេ។ គោលការណ៍ណែនាំ និងបទប្បញ្ញត្តិ ត្រូវតែមាន និងអនុវត្ត ដើម្បីធានាភាពឯកជន និងការសម្ងាត់ នៃព័ត៌មានអ្នកជំងឺ។

គណនេយ្យភាព

ប្រព័ន្ធ SRHR គួរតែដាក់បញ្ចូលនូវយន្តការសម្រាប់ឱ្យសមាជិកសហគមន៍ និងអតិថិជនផ្តល់នូវធាតុចូល និងមតិកែលម្អលើសេវាកម្ម ជាមួយនឹងដំណើរការពិនិត្យមតិកែលម្អនោះនៅនឹងកន្លែងឈ្វេងយល់ និងឆ្លើយតបទៅនឹងមតិកែលម្អទាំងនេះប្រកបដោយប្រសិទ្ធភាព។ លើសពីនេះជម្រើស និងសិទ្ធិរបស់អតិថិជនគួរតែត្រូវបានដាក់បញ្ចូលទៅក្នុងការវាយតម្លៃការអនុវត្តការងារ ដែលបានរំពឹងទុករបស់បុគ្គលិក ដើម្បីធានានូវវប្បធម៌ នៃការគោរព និងការពង្រឹងភាពម្ចាស់ការ។ ការត្រួតពិនិត្យជាទៀងទាត់ទៅលើជម្រើសនិងសិទ្ធិ គួរតែត្រូវបានធ្វើឡើងជាមួយនឹងយន្តការបង្កើតឡើងដើម្បីស៊ើបអង្កេត និងដោះស្រាយការចោទប្រកាន់ ឬការរំលោភបំពានដែលបានបញ្ជាក់។ វិធីសាស្ត្រដ៏សកម្មនេះ លើកកម្ពស់តម្លាភាព គណនេយ្យភាព និងការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់សេចក្តីថ្លៃថ្នូរ និងស្វ័យភាពរបស់បុគ្គលនៅក្នុងប្រព័ន្ធថែទាំសុខភាព។

ការចូលរួម

កម្មវិធី SRHR គួរតែមានការចូលរួមយ៉ាងសកម្មពីសហគមន៍ និងបុគ្គលនានាក្នុងការធ្វើផែនការ និងការត្រួតពិនិត្យកម្មវិធី ដោយធានាថាសំឡេងរបស់ពួកគេត្រូវបានឮ ហើយតម្រូវការរបស់ពួកគេត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព។ អាជ្ញាធរមូលដ្ឋានត្រូវតែដឹងអំពីការថែទាំដែលផ្តោតលើបុគ្គល សមភាពយេនឌ័រ និង SRHR ដែលអនុញ្ញាតឱ្យពួកគេផ្តល់នូវការឆ្លើយតបសមស្របទៅនឹងតម្រូវការសហគមន៍ ជាពិសេសនៅក្នុងករណីដូចជាអំពើហិង្សាផ្អែកលើយេនឌ័រ (GBV) ដែលការទទួលបានសេវា SRHR គឺពិតជាសំខាន់ខ្លាំងណាស់។ តំណាងផ្នែកច្បាប់នៅកម្រិតសហគមន៍គួរតែត្រូវបានធានាផ្តល់សិទ្ធិអំណាចដល់បុគ្គលក្នុងការតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគេ។ កិច្ចខិតខំប្រឹងប្រែងធ្វើឱ្យមានការយល់ដឹងគួរផ្តោតលើបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ដែលរារាំងដល់ការទទួលបានសេវា SRHR ការសម្របសម្រួលការដឹកនាំដោយសហគមន៍ក្នុងការផ្លាស់ប្តូរបទដ្ឋានផ្នត់គំនិតរួមមានការចូលរួមពីបុរស និងក្មេងប្រុសជាសម្ព័ន្ធមិត្តក្នុងការលើកកម្ពស់ការផ្លាស់ប្តូរជាវិជ្ជមាន។ តាមរយៈការជំរុញឱ្យមានវិធីសាស្ត្រប្រកបដោយបរិយាបន្ន និងឆ្លើយតប ប្រព័ន្ធ SRHR អាចឆ្លើយតបតម្រូវការចម្រុះរបស់សហគមន៍បានកាន់តែប្រសើរ និងជំរុញសមភាពយេនឌ័រ និងសិទ្ធិបន្តពូជ។

ការការពារស្វ័យភាពរាងកាយ ភ្នាក់ងារ និងការពង្រឹងអំណាច

ប្រព័ន្ធសុខាភិបាលគួរតែធានាថា បុគ្គលទាំងអស់ ដោយមិនគិតពីភេទ ឬស្ថានភាពសង្គម រួមមាន ក្រុមប្រជាជនដែលងាយរងគ្រោះ និងក្រុមដែលត្រូវបានទុកចោល មានចំណេះដឹងទូលំទូលាយអំពី SRHR ។ ជាងនេះទៅទៀត គំនិតផ្តួចផ្តើមក្នុងការពង្រឹងអំណាច គួរតែជំរុញឱ្យមានការយល់ដឹងស៊ីជម្រៅ និងការទាមទារ សិទ្ធិបន្តពូជ និងសិទ្ធិមនុស្សក្នុងចំណោមក្មេងស្រី ក្មេងប្រុស ស្ត្រី និងបុរសនៅទូទាំងផ្នែកទាំងអស់ នៃសង្គម។ ចំណុចស្នូល នៃប្រព័ន្ធនេះ គឺជាគោលការណ៍ស្វ័យភាពរបស់អតិថិជន ដែលបុគ្គលម្នាក់ៗត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីធ្វើ និងអនុវត្តការសម្រេចចិត្តផ្ទាល់ខ្លួនរបស់ពួកគេទាក់ទងនឹងសុខភាពបន្តពូជរបស់ពួកគេ ដោយមិនមានការគាបសង្កត់ពីខាងក្រៅ ឬឧបសគ្គដែលមានក្នុងប្រព័ន្ធថែទាំសុខភាព សមាជិកសហគមន៍ ឬគ្រួសារ រួមទាំងប្តីប្រពន្ធ ឬដៃគូជិតស្និទ្ធ។ ការសម្រេចចិត្តប្រកបដោយព័ត៌មាន និងដោយស្ម័គ្រចិត្តគួរទទួលបានការគាំទ្រយ៉ាងសកម្ម ជាមួយនឹងវិធីសាស្ត្រគ្រប់គ្រងដោយអតិថិជនជាច្រើនត្រូវបានបង្កើតឡើង។ ចាំបាច់បណ្តុះបណ្តាលឱ្យមានបទដ្ឋានយេនឌ័រប្រកបដោយការគាំទ្រនៅក្នុងសហគមន៍ ដើម្បីសម្រួលដល់ដំណើរការនេះ។ ជាចុងក្រោយ បុគ្គលម្នាក់ៗគួរតែមានសេរីភាពក្នុងការជ្រើសរើសថាតើសេវា SRHR និងវិធីសាស្ត្រមួយណាដែលត្រូវប្រើដោយផ្អែកលើព័ត៌មានត្រឹមត្រូវ ការយល់ដឹង និងភាពចម្រុះ នៃជម្រើសផ្សេងៗ ដោយគ្មានទម្រង់ នៃការបង្ខិតបង្ខំ ឬឧបសគ្គណាមួយឡើយ។

ផ្តោតលើប្រជាជន

គំរូ នៃការផ្តល់សេវាដែលផ្តោតលើប្រជាជន ចាត់ទុកអ្នកជំងឺជាបុគ្គល និងជាដៃគូដែលមានភាពស្មើៗគ្នានៅក្នុងដំណើរការផ្តល់ការថែទាំ កំណត់ករណីទៅតាមបុគ្គលម្នាក់ៗ និងតម្រូវការ និងសំណើរបស់ពួកគេ។

### 3.2.2 គ្រប់គ្រងប្រកបដោយបរិយាបន្ន

ភាពជាម្ចាស់ និងដឹកនាំដោយសហគមន៍

ស្ត្រី កុមារ និងមនុស្សវ័យជំទង់ គឺជាភ្នាក់ងារដ៏មានឥទ្ធិពលបំផុតក្នុងការកែលម្អសុខភាពរបស់ពួកគេ និងសម្រេចបាននូវការលូតលាស់។[39] ដើម្បីឱ្យសហគមន៍អាចចូលរួមយ៉ាងពេញលេញនៅក្នុងអភិបាលកិច្ច នៃប្រព័ន្ធសុខាភិបាលដែលផ្តល់សេវា SRHR អន្តរកម្មសុខភាពមានសារៈសំខាន់ ហើយគួរតែត្រូវបានជំរុញតាមរយៈការអប់រំ និងការសន្ទនាជាមួយវិស័យសាធារណៈ។ អ្នកដឹកនាំសហគមន៍ត្រូវតែចូលរួមនៅក្នុងប្រព័ន្ធសុខភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរាប់ចាប់ពីគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព រហូតដល់ដំណើរការកំណត់អាទិភាពថ្នាក់ជាតិ ពីតម្រូវការសុខភាពរបស់ពួកគេ និងស្នើដំណោះស្រាយ។ ឧទាហរណ៍ វិធីសាស្ត្រ EmONC គួរតែត្រូវបានពង្រីកដើម្បីដាក់បញ្ចូលសុខភាពសហគមន៍ និងការចូលរួមពីគ្រួសារក្នុងការសម្រេចចិត្តស្វែងរកការថែទាំ។

<u>គណនេយ្យភាពនៅគ្រប់កម្រិត</u>

“គណនេយ្យភាពធានាបានថា អ្នកធ្វើការសម្រេចចិត្តមានព័ត៌មានចាំបាច់ដើម្បីបំពេញតម្រូវការសុខភាព និងដឹងពីសិទ្ធិរបស់ស្ត្រី កុមារ និងមនុស្សវ័យជំទង់ទាំងអស់ ហើយដាក់ពួកគេជាបេះដូង នៃកិច្ចខិតខំប្រឹងប្រែងដែលពាក់ព័ន្ធ។”[40] គណនេយ្យភាព គឺជាស្នូល នៃវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស និងរបៀបវារៈឆ្នាំ២០៣០សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមមាន ការប្តេជ្ញាចិត្តចំពោះការទទួលខុសត្រូវកាន់តែច្រើននៅគ្រប់កម្រិតទាំងអស់។ NSSRHR នេះមានទំនួលខុសត្រូវចំពោះប្រជាជនកម្ពុជាទាំងអស់ក្នុងនាមជា អ្នកមានសិទ្ធិ និងអ្នកមានកាតព្វកិច្ចក្នុងរដ្ឋាភិបាលឱ្យទទួលខុសត្រូវក្នុងការអនុវត្តកិច្ចអន្តរាគមន៍ ដែលនឹងធ្វើឱ្យប្រសើរឡើងនូវលទ្ធផល SRHR ដូចដែលបានកំណត់ឡើងតាមរយៈវិធីសាស្ត្របែបចូលរួម។ យន្តការតាមដាន វាយតម្លៃ និងសិក្សាដូចជា ការតាមដាន និងពិនិត្យការស្លាប់មាតា និងទារក (MPDSR) គឺជាយន្តការគណនេយ្យភាពដ៏សំខាន់សម្រាប់ SRHR ព្រោះយន្តការនេះអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធ នៃប្រព័ន្ធនេះ រួមមានបុគ្គលិកសុខាភិបាល អ្នកគ្រប់គ្រង MCH នៅថ្នាក់ក្រោមជាតិ ថ្នាក់ដឹកនាំជាតិ អាជ្ញាធរមូលដ្ឋាន សាលារៀន ។ល។ ចងភ្ជាប់នូវការតព្វកិច្ច និងមានគណនេយ្យភាពចំពោះប្រជាជនដែលយន្តការនេះត្រូវការពារ។ សមាសធាតុជាច្រើនដែលជាគន្លឹះ នៃគណនេយ្យភាព ក្នុងការគ្រប់គ្រង SRHR រួមមាន ការតាមដានធនធានដែលបានចំណាយលើ SRHR និងប្រភព នៃធនធានទាំងនោះ ការវាយតម្លៃលទ្ធផលសុខភាពផ្អែកលើយេនឌ័រ និងការកែលម្អប្រព័ន្ធការអនុវត្តប្រកបដោយការឆ្លើយតបដោយផ្អែកលើមតិកែលម្អពីសហគមន៍ ។

<u>ជំរុញភាពជាដៃគូ</u>

ក្រុមការងារសុខភាពមាតា និងទារក នឹងធ្វើការជាមួយសហគមន៍ មេឃុំ អ្នកដឹកនាំបែបប្រពៃណី និងសាសនា ក្រុមស្ត្រី អង្គការសង្គមស៊ីវិល សាលារៀន និងដៃគូផ្សេងទៀត។ ប្រធានបទសុខភាពដែលមានលក្ខណៈរសើបចំពោះវប្បធម៌ គឺពឹងផ្អែកជាពិសេសទៅលើភាពជាដៃគូយុទ្ធសាស្ត្រ ការអប់រំជុំវិញការរំលូតកូនដោយសុវត្ថិភាព ឬអំពើហិង្សាផ្អែកលើយេនឌ័រ ត្រូវតែពាក់ព័ន្ធនឹងការយល់ឃើញ និងការផ្សព្វផ្សាយព័ត៌មានតាមរយៈការសន្ទនាក្នុងសហគមន៍ និង "អ្នកមានឥទ្ធិពល" រួមទាំងអ្នកដឹកនាំសាសនា។ ភាពជាដៃគូជាមួយបុរស និងក្មេងប្រុសជាសម្ព័ន្ធមិត្ត គឺជាតម្រូវការជាមុនមួយផ្សេងទៀតសម្រាប់ជម្នះទៅនឹងបទដ្ឋានជុំវិញភាពជាបុរស ដែលនេះអាចធ្វើឱ្យប្រសើរឡើងនូវសមភាពយេនឌ័រ។ វិស័យឯកជនផ្តល់សេវា SRHR ជាច្រើនហើយភាពជាដៃគូ

---

[39]អង្គការសហប្រជាជាតិ។ (2015)។ យុទ្ធសាស្ត្រសកលរបស់អង្គការសហប្រជាជាតិសម្រាប់សុខភាពស្ត្រី កុមារ និងមនុស្សវ័យជំទង់ (២០១៦-២០៣០)។

[40]អង្គការសហប្រជាជាតិ។ (2015)។ យុទ្ធសាស្ត្រសកលរបស់អង្គការសហប្រជាជាតិសម្រាប់សុខភាពស្ត្រី កុមារ និងមនុស្សវ័យជំទង់ (២០១៦-២០៣០)។

សាធារណៈ និងឯកជន ផ្តល់អត្ថប្រយោជន៍ទៅវិញទៅមកតាមវិធីជាច្រើន។ ប្រព័ន្ធផ្សព្វផ្សាយមានតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មាន និងអាចជះឥទ្ធិពលលើបទដ្ឋានវប្បធម៌ ដើម្បីបង្កើតសង្គមមួយ ដែលប្រកបដោយបរិយាបន្នកាន់តែច្រើន។ ភាពជាដៃគូសំខាន់ៗត្រូវបានគូសបញ្ជាក់នៅទូទាំងយុទ្ធសាស្ត្រនេះ ហើយវាមានសារៈសំខាន់ណាស់ក្នុងការពិចារណាអំពីភាពជាដៃគូសម្រាប់រាល់អន្តរាគមន៍ទាំងអស់ដែលមាន។

បរិយាបន្ន ជាពិសេសសំឡេងពីប្រជាជនសំខាន់ៗ និងប្រជាជនដែលប្រឈមហានិភ័យ

វិសមភាពសេដ្ឋកិច្ច គឺជាកត្តាបង្កឱ្យមានវិសមភាពក្នុងវិស័យថែទាំសុខភាព ហើយសេវា SRHR ចាំបាច់ត្រូវរចនាឡើង និងវាយតម្លៃដោយមានការគិតគូរទៅលើអ្នកដែលមិនទាន់ទទួលបានការគ្របដណ្តប់ នៃសេវា។[41] ជនជាតិភាគតិច ជាតិសាសន៍ ឬសាសនា ប្រឈមមុខនឹងឧបសគ្គបន្ថែមក្នុងការទទួលបាន SRHR ប្រកបដោយគុណភាព។[42,43] យន្តការអភិបាលកិច្ច ត្រូវដាក់បញ្ចូលក្រុមដែលត្រូវបានទុកចោលនៅក្នុងមុខតំណែង នៃភាពជាអ្នកដឹកនាំ និងមានអំណាចធ្វើសេចក្តីសម្រេចចិត្ត ដូចនេះពួកគេអាចការពារសំឡេង តម្រូវការ និងសិទ្ធិរបស់អ្នកដែលមិនទាន់ទទួលបានការគ្រប់ដណ្តប់ នៃសេវា។ ទិន្នន័យអំពីលំហូរមូលនិធិ និងសេវាកម្ម ត្រូវប្រមូល និងវិភាគដោយបែងចែកទៅតាមស្ថានភាពសេដ្ឋកិច្ច យេនឌ័រ ក្រុមជនជាតិ និងពិការភាព ដើម្បីឱ្យយន្តការអភិបាលកិច្ចទទួលបានការយល់ដឹងអំពីវិសមភាពក្នុងការផ្តល់សេវា SRHR និងកសាងប្រព័ន្ធប្រកបដោយបរិយាបន្នបន្ថែមទៀត។

តម្លាភាព

ជាចាំបាច់ដែលអភិបាលកិច្ច នៃការផ្តល់សេវា SRHR ត្រូវតែមានតម្លាភាព ដោយមានការចែករំលែកព័ត៌មានអំពីដំណើរការ និងលទ្ធផលដែលបានមកពីដំណើរការត្រួតពិនិត្យ និងការចូលរួមក្នុងកិច្ចសន្ទនាប្រកបដោយបរិយាបន្ន។ តម្លាភាព អនុញ្ញាតឱ្យមានការចូលរួមប្រកបដោយអត្ថន័យពីសហគមន៍ ដៃគូ អ្នកផ្តល់មូលនិធិ និងអ្នកស្រាវជ្រាវ ដើម្បីកំណត់គោលដៅរួម នាំឱ្យមានយន្តការគណនេយ្យភាពដែលត្រូវបានដាក់ឱ្យដំណើរការ និងអនុវត្តបានខ្ជាប់ខ្ជួន។ ឧទាហរណ៍ វិធីសាស្ត្រអភិវឌ្ឍន៍យុទ្ធសាស្ត្រ NSSRHR អ្នកពាក់ព័ន្ធនឹងត្រូវបានចែករំលែក ប្រភពទិន្នន័យត្រូវបានកំណត់ឡើង ហើយវឌ្ឍនភាពឆ្ពោះបញ្ចាំងនឹងគោលដៅ និងត្រូវបានរាយការណ៍ជាសាធារណៈ។ ព័ត៌មាននេះ ត្រូវតែមានសម្រាប់សហគមន៍ ដែលយុទ្ធសាស្ត្រនេះមានគោលបំណងបម្រើទៅដល់ ហើយក៏សម្រាប់អ្នកដែលរៀបចំ និងផ្តល់អន្តរាគមន៍សុខភាពនៅគ្រប់កម្រិតផងដែរ ដូច្នេះពួកគេអាចបន្តធ្វើឱ្យមានភាពប្រសើរឡើង និងសហការជាបន្តបន្ទាប់។

### 3.2.3 និរន្តរភាព

ធនធាន

គោលដៅ និងអន្តរាគមន៍ដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ ត្រូវតែមានធនធានគ្រប់គ្រាន់ ទាំងក្នុងរយៈពេលខ្លី និងយូរអង្វែង ដើម្បីអនុវត្តឱ្យបានពេញលេញ ជាបន្តបន្ទាប់ និងនិរន្តរភាព។ អន្តរាគមន៍ដែលខ្វះថវិកា

---

[41]Catherine Arsenault, Keely Jordan, Dennis Lee, et al ។ 2018. សមធម៌ក្នុងគុណភាពនៃការថែទាំមុនពេលសម្រាល៖ ការវិភាគលើការស្ទង់មតិគ្រួសារជាតិចំនួន 91 ។ The Lancet Global Health 6, 11: e1186–e1195។

[42]Yuan Huang, David Shallcross, Li Pi, Fan Tian, Jay Pan និង Carine Ronsmans។ ឆ្នាំ 2018. ជនជាតិ និងលទ្ធផលសុខភាពមាតា និងទារក និងការគ្របដណ្តប់សេវានៅភាគខាងលិចប្រទេសចិន៖ ការពិនិត្យឡើងវិញជាប្រព័ន្ធ និងការវិភាគមេតា។ The Lancet Global Health 6, 1: e39–e56 ។

[43]M. Knight, J. J. Kurinczuk, P. Spark, P. Brocklehurst និងក្នុងនាម UKOSS ។ 2009. វិសមភាពក្នុងសុខភាពមាតា៖ ការសិក្សាចម្រុះជាតិ ស្តីពីជំងឺធ្ងន់ធ្ងររបស់មាតា។ BMJ 338, mar03 2: b542–b542 ។

មានហានិភ័យបង្កគ្រោះថ្នាក់ ខ្ជះខ្ជាយធនធាន ឬធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តសាធារណៈនៅក្នុងប្រព័ន្ធ។ មូលនិធិរបស់ម្ចាស់ជំនួយត្រូវតែបែងចែកទៅឱ្យអាទិភាពដែលបានកំណត់ជាមុនដោយរដ្ឋាភិបាល។ ធនធានក្នុងស្រុកត្រូវតែបែងចែកក្នុងបរិមាណគ្រប់គ្រាន់ និងទាន់ពេលវេលា ដោយផ្អែកលើតម្រូវការដែលបានកំណត់ និងការវិភាគពីតម្លៃអត្ថប្រយោជន៍។ កម្ពុជាត្រូវតែធ្វើការដើម្បីកាត់បន្ថយការពឹងផ្អែកលើម្ចាស់ជំនួយ និង "ផ្លាស់ប្តូរពីការពឹងផ្អែកលើមូលនិធិទៅជាហិរញ្ញប្បទាន" នៅពេលដែលអាចធ្វើទៅបាន ដើម្បីរក្សាភាពជាម្ចាស់លើប្រព័ន្ធសុខាភិបាល និងស្វ័យភាព។ វិនិយោគហិរញ្ញវត្ថុរយៈពេលវែងទៅលើកិច្ចខិតខំប្រឹងប្រែង ជំរុញឱ្យមានភាពធន់ និងការសម្របខ្លួន គឺមានសារៈសំខាន់ណាស់ចំពោះប្រព័ន្ធដ៏រឹងមាំដែលអាចប្រឈមមុខនឹងបញ្ហាសុខភាពនាពេលអនាគតដូចជាបញ្ហាដែលនឹងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

<u>ភាពធន់</u>

នៅក្នុងបរិបទ នៃនិន្នាការប្រជាសាស្ត្រ ហានិភ័យ នៃជំងឺរាតត្បាតនាពេលអនាគត និងការប្រែប្រួលអាកាសធាតុ គេចាំបាច់ណាស់ត្រូវពង្រឹងភាពធន់ក្នុងការផ្តល់សេវា SRHR ដោយធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ប្រព័ន្ធក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងមិនបានរំពឹងទុក។ ការពង្រឹងភាពទន់ខ្សោយនាពេលបច្ចុប្បន្ន តាមរយៈការអនុវត្តយុទ្ធសាស្ត្រនេះ និងការវិនិយោគក្នុងអន្តរាគមន៍ត្រៀមលក្ខណៈ គឺជាគន្លឹះសម្រាប់ដោះស្រាយបញ្ហា។ ការកសាងសមត្ថភាពធនធានមនុស្ស ផ្តល់អាទិភាពដល់កិច្ចអន្តរាគមន៍ទប់ស្កាត់ដូចជា ANC និង CSE ការណែនាំអំពីសេវាសុខភាពផ្លូវចិត្តអំឡុងពេលមានផ្ទៃពោះ ការពង្រីកវ៉ាក់សាំងសុខភាពស្ត្រីដូចជា HPV និងការពង្រឹងប្រព័ន្ធបញ្ជូនបន្ត គឺមានសារៈសំខាន់ក្នុងការកសាងភាពធន់។ គ្រឹះស្ថានផ្តល់សេវានានាក្នុងប្រទេសកម្ពុជា ដែលស្ថិតក្នុងភូមិសាស្ត្រដែលងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ គួរតែអនុវត្តវិធានការត្រៀមលក្ខណៈសង្គ្រោះបន្ទាន់បន្ថែម ដូចជាអ្នកផ្តល់សេវាត្រូវទទួលបានការបណ្តុះបណ្តាលស្តីពីកញ្ចប់សេវាកម្មដំបូងអប្បបរមា (MISP) សម្រាប់ SRHR ក្នុងស្ថានភាពវិបត្តិ។ សេវាកម្ម SRHR ប្រកបដោយនិរន្តរភាព និងភាពធន់ ក៏ធានាផងដែរថាសេវាអាចត្រូវបានផ្តល់ជូនដោយគ្មានការរំខាន។

<u>ការបន្សាំ</u>

វិធីសាស្ត្រមួយចំនួនអនុញ្ញាតឱ្យសម្របខ្លួនរហ័សទៅនឹងវិបត្តិ លើសពីសមត្ថភាពរបស់សេវាសុខភាពដែលមានស្រាប់។ សេវា SRHR ត្រូវតែមានលក្ខណៈសម្របខ្លួនដើម្បីឆ្លើយតបទៅនឹងតម្រូវការដ៏ស្មុគស្មាញពិសេសក្នុងករណីមានភាពអាសន្ននិងជំងឺរាតត្បាត តំបន់ភូមិសាស្ត្រពិបាកទៅដល់ ឬក្រុមជាក់លាក់ (ឧទាហរណ៍ យុវជនជនជាតិដើមភាគតិច ជនចំណាកស្រុក ជនពនេចរ ប្រជាជនដែលគ្មានជម្រក អ្នកប្រើប្រាស់គ្រឿងញៀន អ្នកជាប់ពន្ធនាគារ)។

### 3.2.4 ភស្តុតាង - ជូនដំណឹង

<u>ដំណើរការដោយទិន្នន័យ</u>

ការប្រើទិន្នន័យដែលមានគុណភាពខ្ពស់ ជាក់លាក់ និងមានបច្ចុប្បន្នភាព គឺមានសារៈសំខាន់ចំពោះ ការកែលម្អលទ្ធផលសុខភាពក្នុងរយៈពេលវែងប្រកបដោយសមធម៌ ប្រសិទ្ធភាព និងប្រសិទ្ធផល។ ទិន្នន័យគឺមានសារៈសំខាន់សម្រាប់ការយល់ដឹងពីតម្រូវការរបស់ប្រជាជន ជាពិសេសក្រុមដែលមិនទាន់ទទួលបានសេវា ឬក្រុម

ជនជាតិភាគតិចដោយសារតម្រូវការរបស់ពួកគេប្រហែលជាមិនត្រូវបានយល់ច្បាស់ដោយអ្នកដឹកនាំ ហើយទិន្នន័យក៏សំខាន់សម្រាប់ការរៀបចំកម្មវិធីអន្តរាគមន៍ឱ្យបានត្រឹមត្រូវ ការកំណត់បញ្ហាដែលរាំងស្ទះ និងការធ្វើឱ្យការអនុវត្តមានភាពប្រសើរឡើង ការវាយតម្លៃផលប៉ះពាល់របស់ ក្រុមការងារសុខភាពមាតា និងទារក និងអន្តរាគមន៍របស់ដៃគូ ការយល់ដឹងអំពីផលប៉ះពាល់ នៃការផ្តល់ថវិកា និងតម្លៃ ប្រសិទ្ធភាពរបស់អន្តរាគមន៍ ការផ្តល់អនុសាសន៍ត្រឹមត្រូវដល់អ្នកបង្កើតច្បាប់ និងគោលនយោបាយ និងធ្វើឱ្យមានគណនេយ្យភាពក្នុងអភិបាលកិច្ច។[44]

នៅក្នុងប្រទេសកម្ពុជា ប្រព័ន្ធព័ត៌មានសុខាភិបាល (HMIS) ត្រូវបានប្រើប្រាស់ដោយភាគីពាក់ព័ន្ធរបស់រដ្ឋាភិបាលដើម្បីរៀបចំផែនការ តាមដាន និងពិនិត្យឡើងវិញនូវអន្តរាគមន៍នានា ដើម្បីពង្រឹងការផ្តល់សេវាសុខភាពសាធារណៈរួមទាំង SRHR ផងដែរ។ ការធ្វើបច្ចុប្បន្នភាព និងការពង្រឹងសូចនាករ SRHR និងការបែងចែកទិន្នន័យនៅក្នុង HMIS ជាគន្លឹះក្នុងការកែលម្អគោលនយោបាយ និងកម្មវិធីដែលជំរុញដោយទិន្នន័យ។ នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល (DPHI) ស្វាគមន៍ជាទៀងទាត់នូវសំណើសម្រាប់ការកែប្រែសូចនាករកម្មវិធី ហើយក្រុមការងារសុខភាពមាតា និងទារកជាអ្នកដាក់សំណើ។ ដៃគូត្រូវតែបន្តគាំទ្រ ក្រុមការងារសុខភាពមាតា និងទារកដើម្បីកំណត់សូចនាករ និយមន័យ និងការបែងចែកទិន្នន័យដែលពាក់ព័ន្ធសម្រាប់ SRHR ដូច្នេះគេអាចបញ្ជូនទៅ DPHI និងអនុវត្តនៅថ្នាក់ក្រោមជាតិទូទាំងប្រទេស។ បន្ថែមពីលើ HMIS ការចុះបញ្ជីរង្គប្បវេណី និងស្ថិតិសំខាន់ៗ (CRVS) ផ្តល់ទិន្នន័យសំខាន់ៗអំពី SRHR ជាពិសេសទាក់ទងនឹងការស្លាប់របស់មាតា និងទារក។

នៅក្នុងប្រទេស និងបរិបទជាច្រើន ទិន្នន័យអំពីចំនួនប្រជាជនដែលមិនទាន់ទទួលបានការគ្របដណ្តប់គឺមានកម្រិត។ មានយុទ្ធសាស្ត្រជាច្រើនដើម្បីកំណត់ចំនួនប្រជាជន និងតម្រូវការរបស់ពួកគេនៅពេលដែលគ្មានទិន្នន័យ។ យុទ្ធសាស្ត្រទាំងនេះរួមមានការប្រើប្រាស់ទិន្នន័យដែលអាចជំនួសបាន (Proxy Data) ដូចជាប្រជាជនក្រីក្រ ក្មេងដែលមិនទាន់ចាក់វ៉ាក់សាំង ការចូលប្រើទិន្នន័យពីវិស័យផ្សេងទៀត ការអប់រំ សេវាសង្គម ឬការប្រើប្រាស់ឧបករណ៍ច្នៃប្រឌិតដូចជាទិន្នន័យភូមិសាស្ត្រ។ ការកសាងសមត្ថភាពបច្ចេកវិទ្យាដើម្បីភ្ជាប់ ទិន្នន័យ ដែលមានស្រាប់រវាងវិស័យផ្សេងៗ ឬការស្ទង់មតិ ក៏ជាជំហានដ៏សំខាន់មួយក្នុងការប្រមូលព័ត៌មានអំពីសហគមន៍ ដែលមិនទាន់ទទួលបានការគ្របដណ្តប់។ បង្កើនការប្រើប្រាស់ទិន្នន័យប្រកបដោយគុណភាព និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធអាចជាដំណោះស្រាយដ៏ល្អនៅពេល ដែលទិន្នន័យបែបបរិមាណមានមិនគ្រប់គ្រាន់ធនធានមនុស្សត្រូវតែអភិវឌ្ឍសមត្ថភាពប្រើប្រាស់ប្រព័ន្ធទិន្នន័យ ទាក់ទងនឹងការបញ្ចូលទិន្នន័យ ការចូលប្រើ ការវិភាគ ការបកស្រាយ និងការប្រើប្រាស់ទិន្នន័យដើម្បីធ្វើការសម្រេចចិត្ត។ ប្រព័ន្ធសុខភាពក៏នឹងពឹងផ្អែកលើសមត្ថភាពព័ត៌មាន និងបច្ចេកវិទ្យា (IT) ជាក់លាក់ដើម្បីបង្កើត ដំណោះស្រាយសេវាសុខភាពតាមអេឡិចត្រូនិក (Ehealth) ថែរក្សាប្រព័ន្ធ និងដោះស្រាយបញ្ហាបច្ចេកទេស និងបន្តធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធដើម្បីរក្សាបាននូវអត្ថប្រយោជន៍ និងភាពជឿនលឿននៃបច្ចេកវិទ្យា។

ប្រកបដោយភាពឆ្លើយតប

អន្តរាគមន៍ និងកម្មវិធីត្រូវតែឆ្លើយតបទៅនឹងភស្តុតាង។ នេះអាចសម្រេចបានតាមរយៈក្របខណ្ឌការត្រួតពិនិត្យ និងការវាយតម្លៃដ៏រឹងមាំ ការពិនិត្យឡើងវិញ នៃទិន្នន័យបរិមាណមុននឹងរៀបចំវិធីសាស្ត្រ ឬវាយតម្លៃ

[44]អង្គការសុខភាពពិភពលោក។ (២០២៣)។ ក្របខណ្ឌតំបន់សម្រាប់ការឈានទៅដល់ការមិនទាន់សម្រេចនៅប៉ាស៊ីហ្វិកខាងលិច (2022-2030)។

វឌ្ឍនភាព ការចូលរួមពីសហគមន៍ដើម្បីទទួលបានការណែនាំពីសហគមន៍ទៅលើវិធីសាស្ត្ររៀបចំផែនការ ឬការអនុវត្ត ការបង្កើត និងប្រើប្រាស់យន្តការផ្តល់យោបល់លើសេវា SRHR និងការធានាឱ្យមានការចូលរួមពី ពហុភាគីពាក់ព័ន្ធ បរិយាបន្ន និងដំណើរការកំណត់អាទិភាពតាមបែបការចូលរួម។

## 3.3 កត្តាជំរុញល្បឿន នៃផលប៉ះពាល់

បើកដំណើរការភាពជាអ្នកដឹកនាំ និងការចូលរួមរបស់ក្មេងជំទង់

ការវិភាគស្ថានភាពយុវជននៅកម្ពុជាឆ្នាំ២០២០ បង្ហាញអំពីកង្វះ នៃការចូលរួមរបស់យុវជនក្នុងការដឹកនាំក្នុងការកំណត់គោលនយោបាយ និងកម្មវិធីដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។ មានតែ ១១% នៃយុវជនដែលឆ្លើយសំណួរស្ទង់មតិ អាយុពី ១០-២៤ ឆ្នាំប៉ុណ្ណោះ ដែលអាចនិយាយអំពីគំនិតរបស់ពួកគេ ឬផ្លាស់ប្តូរគំនិតជាមួយក្រុមមនុស្ស ឬអង្គការហើយមានតែ ៦% ប៉ុណ្ណោះដែលបានដឹកនាំ ឬចូលរួមក្នុងសកម្មភាព ឬកម្មវិធីនៅក្នុងសហគមន៍របស់ពួកគេ។ មនុស្សវ័យជំទង់ រងផលប៉ះពាល់ខុសៗគ្នា ពីលទ្ធផលសុខភាពមិនល្អ ហើយពួកគេមានការយល់ដឹងដ៏មានតម្លៃអំពីមូលហេតុឫសគល់ដែលបណ្តាលឱ្យមានសុខភាពមិនល្អក្នុងចំណោមពួកគេ និងគំនិតសម្រាប់កាត់បន្ថយឧបសគ្គទាំងនេះដើម្បីទទួលបានការថែទាំសុខភាព។ ការវិនិយោគលើភាពជាអ្នកដឹកនាំរបស់យុវជន និងការចូលរួមនៅក្នុង SRHR បង្ហាញពីឱកាសពិសេសមួយដើម្បីពន្លឿនការកែលម្អលទ្ធផលសុខភាព និងបង្កើតអ្នកដឹកនាំជំនាន់ក្រោយក្នុងវិស័យ SRHR ។ ជាឧទាហរណ៍ នេះអាចត្រូវបានធ្វើដោយការរៀបចំតំណាងយុវជនក្នុងអភិបាលកិច្ចមូលដ្ឋាន ដោយបញ្ចូលយុវជនទៅក្នុងគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ (CCWC) និងសម្របសម្រួលការសន្ទនារវាងយុវជន និងអ្នកដឹកនាំសហគមន៍ ដើម្បីឱ្យយុវជនអាចបង្ហាញពីទស្សនៈ និងអារម្មណ៍របស់ពួកគេលើបញ្ហាដែលប៉ះពាល់ដល់ពួកគេ។ នៅថ្នាក់ជាតិ NMCHC អាចចាប់ដៃគូជាមួយសកម្មជនយុវជនដែលយកចិត្តទុកដាក់លើបញ្ហា SRHR និងចូលរួមជាមួយពួកគេក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីកសាងសមត្ថភាពយុវជនបន្តិចម្តងៗ ឱ្យពួកគេអាចចូលរួមចំណែកប្រកដោយអត្ថន័យក្នុងការសម្រេចចិត្តថ្នាក់ជាតិ និងធ្វើឱ្យប្រសើរឡើងនូវ លទ្ធភាពទទួលបានសេវាដើម្បីបំពេញតម្រូវការរបស់ពួកគេ។ ពួកគេក៏អាចចូលរួមជាមួយបណ្តាញយុវជន ក្លឹបកុមារ និងសមាជិកក្លឹបយុវជន និងអ្នកដឹកនាំបែបប្រពៃណី និងជំនឿ អ្នកដែលអាចមានឥទ្ធិពលលើជម្រើសរបស់មនុស្សវ័យក្មេង។

បង្កើនការប្រើប្រាស់ការច្នៃប្រឌិត បច្ចេកវិទ្យា និងឌីជីថល

ការកើនឡើង នៃឧបករណ៍សុខភាពឌីជីថល និងការជ្រៀតចូល នៃបច្ចេកវិទ្យាឌីជីថលក្នុងចំណោមប្រជាជនទាំងអស់នៅក្នុងប្រទេសកម្ពុជានាំមកនូវឱកាស និងហានិភ័យថ្មីៗទាក់ទងនឹង SRHR។ ឧបករណ៍កំពុងត្រូវបានបង្កើតឡើងក្នុងគោលបំណង ធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកទទួលផល វិធីសាស្ត្ររបស់បុគ្គលិកសុខាភិបាល និងការតាមដានលទ្ធផល។ ឌីជីថលនីយកម្មអាចត្រូវបានប្រើប្រាស់ដើម្បីកាត់បន្ថយវិសមភាព ដោយធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាសម្រាប់ប្រជាជន ដែលមិនទាន់ទទួលបានការគ្របដណ្តប់ តាមរយៈអន្តរាគមន៍ដូចជា សេវាថែទាំវេជ្ជសាស្ត្រពីចម្ងាយ (telemedicine) ជាដើម។ ការអនុវត្តការថែទាំខ្លួនឯងជាច្រើន ដូចជាស្ត្រីអាចប្រើថ្នាំសម្រាប់រំលូតកូនតាមវេជ្ជសាស្ត្រដោយខ្លួនឯងមិននៅនឹងគ្រឹះស្ថានសុខាភិបាល អាចត្រូវបានសម្របសម្រួលដោយជំនួយឌីជីថល ដូចជាវីដេអូ ឬការពិគ្រោះយោបល់ពីចម្ងាយ។ ទោះជាយ៉ាងនេះក្តី បច្ចេកវិទ្យា និងឌីជីថលនីយកម្មក៏បង្កើតហានិភ័យថ្មីដែលទាក់ទងនឹង

ការផ្ទុកព័ត៌មានសុខភាព ដែលអាចកំណត់អំពីអត្តសញ្ញាណផ្ទាល់ខ្លួន ការចែកចាយនូវព័ត៌មានមិនពិត និងជំនឿខុសឆ្គង និងឧបសគ្គក្នុងការប្រើប្រាស់ដោយសារគ្មានជំនាញ ឬធនធានក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថល។ គេចាំបាច់បង្កើនការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងប្រទេសកម្ពុជា និងរក្សាការផ្តោតទៅលើការចូលប្រើប្រាស់បានសុវត្ថិភាព សន្តិសុខ និងឯកជនភាព។

<u>កំណត់គោលដៅអន្តរាគមន៍ដើម្បីទៅដល់ប្រជាជនសំខាន់ៗដែលមានហានិភ័យ</u>

សហគមន៍ដែលមិនទាន់ទទួលបានការគ្របដណ្តប់ ប្រឈមមុខនឹងឧបសគ្គពិសេសក្នុងការទទួលបានសេវាថែទាំសុខភាពរហូតមកដល់បច្ចុប្បន្ន។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងបានចាប់ផ្តើមនៅក្នុងទសវត្សរ៍កន្លងមកក៏ដោយ។ ដើម្បីឈានទៅដល់ចំនួនប្រជាជនទាំងនេះ អន្តរាគមន៍របស់ SRHR ត្រូវតែកែតម្រូវ ដើម្បីកាត់បន្ថយឧបសគ្គពិសេសដែលប្រឈមមុខដោយពួកគេ និងផ្តល់លទ្ធភាពទទួលបានសេវាសុខភាពដែលផ្តោតលើបុគ្គលទាំងនោះ។ យុទ្ធសាស្ត្រនេះ បង្ហាញពីអន្តរាគមន៍ដែលបែងចែកទៅតាមប្រជាជន ឬកត្តាហានិភ័យដែលពាក់ព័ន្ធដើម្បីធានាថាតម្រូវការជាក់លាក់របស់ពួកគេត្រូវបានដោះស្រាយ។

<u>វិធានការបង្ការ ដោយការដោះស្រាយបទដ្ឋានសង្គមដែលបង្កគ្រោះថ្នាក់ដែលជំរុញ</u>

<u>វិសមភាពយេនឌ័រ អំពើហិង្សា (រួមទាំង GBV) និងការរើសអើង</u>

បទដ្ឋានសង្គមដែលបង្កគ្រោះថ្នាក់ រួមទាំងបទដ្ឋានយេនឌ័រ គឺជាមូលហេតុធ្វើឱ្យមានលទ្ធផលសុខភាព និងសុខុមាលភាពមិនល្អ។ ការដោះស្រាយតែលទ្ធផលដែលកើតចេញបទដ្ឋានទាំងនេះតាមរយៈការផ្តល់សេវាសុខភាព ការព្យាបាល និងបញ្ជូនអ្នករងគ្រោះដែលទទួលរងនូវផលវិបាកទាំងនោះទៅរកសេវា គឺមិនបានដោះស្រាយមូលហេតុឫសគល់ នៃបញ្ហាឬអាចនាំទៅរកការកែលម្អប្រកបដោយនិរន្តរភាព នៃសុខភាព សុខុមាលភាព និងការលូតលាស់បាននោះទេ។ យុទ្ធសាស្ត្រនេះ ដាក់បញ្ចូលផ្នែកយុទ្ធសាស្ត្រ ដែលផ្តោតលើការផ្លាស់ប្តូរបទដ្ឋានទាំងក្នុង និងក្រៅបរិបទវិស័យសុខាភិបាលដោយសារវិធានការនេះមានសារៈសំខាន់ ក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជាទាំងអស់បានយូរអង្វែង និងប្រកបដោយសមធម៌។

<u>ពង្រឹងស្ថាប័នថ្នាក់ក្រោម សមត្ថភាពមូលដ្ឋាន និងការចូលរួម</u>

បទដ្ឋានសហគមន៍ ឧបសគ្គផ្នែកហិរញ្ញវត្ថុ និងការសម្រេចចិត្តក្នុងគ្រួសារដើរតួនាទីយ៉ាងសំខាន់ទាក់ទងពេលវេលា និងទីកន្លែងដែលគេត្រូវស្វែងរកព័ត៌មាន និងសេវាកម្មរបស់ SRHR និងវិសាលភាពដែលស្ត្រីអាចអនុវត្តសិទ្ធិរបស់ពួកគេ។ យុទ្ធសាស្ត្រនេះ ទទួលស្គាល់ពីតម្រូវការក្នុងការបង្កើនតួនាទីរបស់អ្នកដើរតួក្នុងសហគមន៍ដើម្បីកំណត់បញ្ហាប្រឈមក្នុងការទទួលបាន និងស្នើដំណោះស្រាយជាក់ស្តែង។ វាជារឿងសំខាន់ដែលថ្នាក់ដឹកនាំ SRHR ថ្នាក់ជាតិបន្តចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន មេឃុំ សាលារៀន ក្រុមសហគមន៍ អ្នកដឹកនាំបែបប្រពៃណី និងសាសនា ក្រុមស្ត្រី អង្គការសង្គមស៊ីវិល និងដៃគូផ្សេងទៀតក្នុងការសម្រេចចិត្ត ការធ្វើផែនការ ការអនុវត្ត និងការរៀនសូត្រដើម្បីកែលម្អ។ នៅក្នុងប្រព័ន្ធសុខាភិបាល ជាអ្នកដើរតួកម្រិតស្រុកប្រតិបត្តិ (OD) និង PHD ជាពិសេសអ្នកគ្រប់គ្រង MCH និងអ្នកគ្រប់គ្រងឃ្លាំង ដើរតួនាទីយ៉ាងសំខាន់ក្នុងគ្រប់ទិដ្ឋភាពនៃការអនុវត្ត និងអន្តរាគមន៍ត្រួតពិនិត្យ។ ការវិនិយោគលើតួអង្គទាំងនេះ មានសក្តានុពលធ្វើឱ្យមានកត្តាជះឥទ្ធិពលលើការអនុវត្តលទ្ធផលជាក់ស្តែង។

<u>អនុម័តវិធីសាស្ត្រវដ្តជីវិតក្នុងការធ្វើផែនការ និងបង្កើតអន្តរាគមន៍ SRHR</u>

ស្របតាម ICPD យុទ្ធសាស្ត្រនេះទទួលស្គាល់ថាស្ត្រី បុរស និងបុគ្គលម្នាក់ៗមានតម្រូវការសុខភាពពេញមួយជីវិតរបស់ពួកគេ ហើយតម្រូវការសុខភាពបន្តពូជស្ត្រី ប្រែប្រួលអាស្រ័យលើអាយុរបស់ពួកគេ។[45] ការផ្លាស់ប្តូរប្រជាសាស្ត្រនៅក្នុងប្រទេសកម្ពុជា អាចបណ្តាលឱ្យស្ត្រីពន្យារពេលក្នុងការមានកូនរហូតដល់វ័យរាងចាស់ ដែលនេះមានន័យថា សេវាត្រូវតែកែតម្រូវទៅតាមបំណងដើម្បីបំពេញតម្រូវការពិសេសរបស់ម្តាយដែលមានវ័យចំណាស់។ ដំណាក់កាលក្រោយមកទៀតក្នុងជីវិត ស្ត្រីក៏មានតម្រូវការ SRHR ជាក់លាក់ក្នុងអំឡុងពេលអស់រដូវរបស់ពួកគេ។ ការអនុម័តវិធីសាស្ត្រវដ្តជីវិត គឺជាវិធីមួយក្នុងការអនុវត្តគោលការណ៍ផ្អែកលើសិទ្ធិមនុស្សរបស់យុទ្ធសាស្ត្រនេះ។

## 3.4 អាទិភាពជាយុទ្ធសាស្ត្រ

អាទិភាពជាយុទ្ធសាស្ត្រខាងក្រោមនឹងណែនាំពីការកំណត់ប្រយោគបញ្ហា បញ្ហាប្រឈមសំខាន់ៗ ដែលរួមចំណែកដល់អាទិភាពទាំងនោះ និងអន្តរាគមន៍ដែលបានស្នើឡើងដើម្បីដោះស្រាយ។

| **អាទិភាពជាយុទ្ធសាស្ត្រណែនាំ NSSRHR ២០២៤-២០៣០** |
|---|
| ១. កែលម្អភាពអាចរកបាន ប្រសិទ្ធភាព សុវត្ថិភាព និងការផ្តោតលើប្រជាជន នៃព័ត៌មាន និងសេវាកម្ម SRHR |
| ២. លើកកម្ពស់បុគ្គលិកសុខាភិបាលដើម្បីផ្តល់ព័ត៌មាន និងសេវាកម្មរបស់ SRHR ឱ្យសមស្របតាមគោលបំណង |
| ៣. ធ្វើឱ្យប្រសើរឡើងនូវការដាក់បញ្ចូលសេវាកម្ម និងការបញ្ជូនបន្តដើម្បីធានាបានទាន់ពេលវេលា និងសមភាពក្នុងការទទួលបានសេវា SRHR គ្រប់ជ្រុងជ្រោយនៅគ្រប់កម្រិត នៃការថែទាំ |
| ៤. ដោះស្រាយបទដ្ឋានសង្គម និងយេនឌ័រ គោលនយោបាយ និងការអនុវត្តដែលបង្កគ្រោះថ្នាក់តាមរយៈការពង្រឹងអភិបាលកិច្ច និងការផ្តល់សេវារបស់ SRHR |
| ៥. ផ្តល់អាទិភាពដល់ភាពជាម្ចាស់របស់សហគមន៍ ការចូលរួមជាមួយប្រព័ន្ធសុខាភិបាល និងការឆ្លើយតបដើម្បីពង្រឹង ការផ្គត់ផ្គង់ និងតម្រូវការសេវា SRHR |
| ៦. លុបបំបាត់ឧបសគ្គផ្នែកហិរញ្ញវត្ថុក្នុងការចូលប្រើសេវាថែទាំសុខភាព ឆ្ពោះទៅរកការសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល (UHC) |
| ៧. ធ្វើឱ្យប្រសើរឡើងនូវភាពអាចរកបាន នៃផលិតផលវេជ្ជសាស្ត្រ និងបច្ចេកវិទ្យា |
| ៨. ផ្សព្វផ្សាយ និងពង្រឹងទិន្នន័យសម្រាប់ការស្រាវជ្រាវ ការច្នៃប្រឌិត ការត្រួតពិនិត្យ និងការរៀនសូត្រ |
| ៩. ជំរុញអភិបាលកិច្ចរួម និងជំរុញភាពជាដៃគូ។ |

[45] Sundewall, Jesper, និង Hannah Kaiser ។ "សិទ្ធិ និងសុខភាពផ្លូវភេទ និងបន្តពូជ៖ ជាធាតុសំខាន់នៃការគ្របដណ្តប់សុខភាពជាសកល។ ឯកសារប្រវត្តិសាវតាសម្រាប់កិច្ចប្រជុំកំពូលណៃរ៉ូប៊ី ស្តីពី ICPD25-ការពន្លឿនការសន្យា។" (2019)។

## 4. តំបន់អន្តរាគមន៍តាមអាទិភាពជាយុទ្ធសាស្ត្រ

### អាទិភាពជាយុទ្ធសាស្ត្រ ១. ធ្វើឱ្យប្រសើរឡើងនូវភាពអាចរកបាន ប្រសិទ្ធភាព សុវត្ថិភាព និងការផ្តោតលើប្រជាជន នៃព័ត៌មាន និងសេវាកម្មរបស់ SRHR ។

#### ប្រយោគបញ្ហា

ភាពអាចរកបាន ប្រសិទ្ធភាព សុវត្ថិភាព និងការផ្តោតលើប្រជាជន នៃព័ត៌មាន និងសេវា SRHR នៅកម្ពុជា គឺមានមិនទាន់គ្រប់គ្រាន់ដើម្បីធ្វើឱ្យប្រសើរឡើងនូវ SRHR ប្រកបដោយនិរន្តរភាពនៅឡើយ។

#### បញ្ហាប្រឈមសំខាន់ៗ

WHO កំណត់ការថែទាំសុខភាពប្រជាជន ដែលប្រកបដោយគុណភាព ដោយឈរលើប្រសិទ្ធភាព (ការផ្តល់សេវាថែទាំសុខភាពផ្អែកលើភស្តុតាង) សុវត្ថិភាព (ជៀសវាងគ្រោះថ្នាក់) និងការផ្តល់ការថែទាំដែលឆ្លើយតបទៅនឹងចំណង់ចំណូលចិត្ត តម្រូវការ និងគុណតម្លៃ ។[46]

1) ភាពអាចរកបាន

នៅក្នុងប្រទេសកម្ពុជា មានការលំបាកក្នុងការវាយតម្លៃភាពអាចរកបាន នៃសេវា ដោយសារតែគេមិនដឹងអំពីចំនួនពិតប្រាកដ និងទីតាំងគ្រឹះស្ថានសុខាភិបាលដែលមានកញ្ចប់ RMNCH ពេញលេញ ដែលអាចរកបាននៅគ្រប់កម្រិត នៃគ្រឹះស្ថានសុខាភិបាល (MPA, CPA ។ល។) ខណៈ MPA ពេញលេញមិនមាននៅគ្រប់មណ្ឌលសុខភាពទាំងអស់នោះទេ ។[47] ជាលទ្ធផលសេវាមួយចំនួនមានមិនគ្រប់គ្រាន់ក្នុងចំនួន និងចែកចាយមិនស្មើភាពគ្នាតាមភូមិសាស្ត្រ បើធៀបនឹងស្តង់ដារបស់ UN និងស្តង់ដារជាតិ។ ឧទាហរណ៍ ការគ្របដណ្តប់ BEmONC គឺបានតែពាក់កណ្តាលនូវចំនួន ដែលតម្រូវឱ្យបំពេញតាមស្តង់ដាររបស់អង្គការសហប្រជាជាតិប៉ុណ្ណោះ។ ចំនួនគ្រឹះស្ថានសាធារណៈដែលផ្តល់ជូន CAC បានកើនឡើងពីចំនួន ៧៦២ ក្នុងឆ្នាំ ២០១៧ ទៅ ៨២០ នៅឆ្នាំ ២០២៤។[48]

ក្នុងចំណោមសេវាដែលគេដឹងថាអាចរកបាន សេវាជាក់លាក់មួយចំនួនគឺមាន ប៉ុន្តែត្រូវការពង្រីកបន្ថែមទៀត។ ការដាក់ឱ្យប្រើប្រាស់នូវសេវាកម្មថ្មីៗ ដូចជាការចាក់វ៉ាក់សាំង HPV សម្រាប់ក្មេងស្រី គឺជាភាពជឿនលឿនមួយ ប៉ុន្តែការគ្របដណ្តប់ត្រូវតែពង្រីកដល់យុវជនកម្ពុជាទាំងអស់។

ជាងនេះទៅទៀតកញ្ចប់សេវានៅតាមគ្រឹះស្ថានសាធារណៈ នៅខ្វះសេវាសង្គ្រោះជីវិតមួយចំនួន ដែលចាំបាច់ត្រូវណែនាំដូចជា ការថែទាំសុខភាពផ្លូវចិត្តអំឡុងពេលមានផ្ទៃពោះដើម្បីការពារសុខុមាលភាពផ្លូវចិត្ត-សង្គមរបស់ឳពុកម្តាយអំឡុងពេលមានផ្ទៃពោះ និងក្រោយសម្រាល។ ដូចគ្នានេះផងដែរ កន្លែងសាធារណៈមិនផ្តល់សេវាទាក់ទងនឹងការអស់រដូវ និងភាពគ្មានកូននោះទេ។

ព័ត៌មាន SRHR ក៏មិនមានជាប់លាប់សម្រាប់អ្នកដែលត្រូវការដែរ។ កម្មវិធីអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ (CSE) នៅសាលារៀន បានចាប់ផ្តើមអនុវត្តនៅក្នុងខេត្តមួយចំនួន ប៉ុន្តែមិនទាន់បានអនុវត្តនៅទូទាំងប្រទេស

[46] WHO 2023 ចូលមើលនៅ៖ www.who.int/health-topics/quality-of-care

[47] ក្រសួងសុខាភិបាលកម្ពុជា។ (២០២២)។ ធ្វើបច្ចុប្បន្នភាព និងពង្រីកយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិនៅកម្ពុជា (២០១៧-២០២៣)។

[48] កំណត់ត្រាមជ្ឈមណ្ឌលសុខភាពមាតា និងទារកជាតិ (NMCHC) ឆ្នាំ 2024 ។

នោះទេ ដោយសារការបណ្តុះបណ្តាលគ្រូដោយផ្ទាល់គឺពឹងផ្អែកលើមូលនិធិរបស់ម្ចាស់ជំនួយទោះបីជាផែនការបន្តដំណើរការជាដំណាក់កាលកំពុងដំណើរការក៏ដោយ។ លើសពីនេះ គ្រូបង្រៀនដែលទទួលខុសត្រូវក្នុងការផ្តល់កម្មវិធីសិក្សាCSE អាចខ្វះការបណ្តុះបណ្តាល និងជំនាញសមត្ថភាពនេះ។ ព័ត៌មានអំពីសេវាកម្មដែលមាននៅក្នុងគ្រឹះស្ថានសាធារណៈ មិនត្រូវបានធ្វើទំនាក់ទំនងយ៉ាងល្អនៅកម្រិតសហគមន៍នោះទេ។

2) ប្រសិទ្ធភាព និងសុវត្ថិភាព នៃសេវាកម្ម

មានទិន្នន័យតិចតួចអំពីលទ្ធផលសុខភាពដែលកើតចេញពីសេវាដែលបានផ្តល់ ឧបករណ៍ និងប្រព័ន្ធធានាគុណភាពត្រូវបានណែនាំ ប៉ុន្តែមិនត្រូវបានប្រើប្រាស់ជាប្រព័ន្ធទេ។ ទិន្នន័យដែលទាញដោយឧបករណ៍ធានាគុណភាពជាក់លាក់ មិនត្រូវបានគេប្រើប្រាស់ជាប្រព័ន្ធដើម្បីផ្តល់ព័ត៌មានសម្រាប់ការកែលម្អនោះទេ ដោយសារមូលនិធិមានកម្រិតសម្រាប់អនុវត្តអន្តរាគមន៍ ការណែនាំ ឬវគ្គបណ្តុះបណ្តាលដែលត្រូវការ។ គុណភាពនៃការថែទាំនៅគ្រឹះស្ថានឯកជន មិនត្រូវបានត្រួតពិនិត្យ ឬប្រៀបធៀបជាមួយនឹងការណែនាំដែលមាន (ដូចជាគោលការណ៍ណែនាំជាតិ ពិធីសារ និង SOPs ជាដើម)។ មិនមានការគាំទ្រសម្រាប់ការកែលម្អគុណភាពទៅលើចំណុចដែលខ្វះខាតនោះទេ ហើយការអនុវត្តល្អបំផុតក្នុងចំណោមគ្រឹះស្ថានដែលទទួលបានជោគជ័យ គឺកម្រត្រូវបានចែករំលែកជាមួយអ្នកផ្សេងទៀតដើម្បីពង្រីកភាពជោគជ័យ។

សេវាកម្ម មិនត្រូវបានផ្តល់ជូនដោយសុវត្ថិភាពពេញលេញស្របតាមពិធីសារនៅកម្រិត នៃការថែទាំនីមួយៗ (MPA, CPA 1-2-3)។ ជាឧទាហរណ៍ ធាតុទាំងអស់ នៃសេវាកម្ម ANC ដែលត្រូវផ្តល់ជូននៅកម្រិត MPA មិនត្រូវបានផ្តល់ឱ្យជាប់លាប់ក្នុងអំឡុងពេលការណាត់ ANC ។ នៅកម្រិតថែទាំសុខភាពខ្ពស់ជាងនេះ ការសម្រាលកូនដោយវះកាត់ត្រូវបានផ្តល់ជូនអ្នកជំងឺតាមការស្នើសុំរបស់អ្នកជំងឺ ក្នុងករណីដែលវេជ្ជសាស្ត្រមិនបានបង្ហាញពីភាពចាំបាច់សម្រាប់ការវះកាត់ នេះបង្ហាញពីហានិភ័យសុខភាព។[49] ដូចគ្នានេះផងដែរ សុវត្ថិភាពអ្នកជំងឺមិនត្រូវបានគាំទ្រពេញលេញនោះទេ នៅពេលដែលគេត្រូវការសេវាកម្មផ្សេងទៀតដែលមិនមែនជាសេវាសុខភាពដូចជាតម្រូវការរបស់ជនរងគ្រោះដែលនៅរស់រានមានជីវិតពីអំពើហិង្សាផ្អែកលើយេនឌ័រ (GBV) ទៅលើជំនួយផ្នែកច្បាប់ដើម្បីធានាការការពាររាងកាយរបស់ពួកគេ។

ក្រុមការងារសុខភាពមាតា និងទារកដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក ការរៀបចំការត្រួតពិនិត្យជាតិ នៃប្រព័ន្ធស្រាវជ្រាវមរណភាពមាតា (MDA) ឆ្លុះបញ្ចាំងពីការពិតដែលថានៅក្នុងប្រទេសកម្ពុជាមានតែជំហានដំបូងក្នុងចំណោមជំហានទាំងប្រាំមួយ នៃការតាមដានការស្លាប់របស់មាតា និងការឆ្លើយតបប៉ុណ្ណោះដែលត្រូវបានធ្វើ។ MDA ត្រូវបានប្រើដើម្បីកំណត់បញ្ហាប្រឈមនៅក្នុងដំណើរការកំណត់គុណភាពនៃកិច្ចប្រជុំ MDA ថ្នាក់ខេត្ត និងវាយតម្លៃអនុសាសន៍ដែលចេញដោយកិច្ចប្រជុំទាំងនេះ។ បញ្ហាប្រឈមដែលបានកំណត់រួមមានដូចជា៖ អសមត្ថភាពក្នុងការចាត់ថ្នាក់ការស្លាប់របស់មាតាមួយចំនួន បញ្ហាប្រឈមក្នុងការកត់ត្រា និងការរាយការណ៍ពីមូលហេតុ នៃការស្លាប់ទាំងអស់ ការផ្តល់មតិត្រឡប់ដែលមិនស៊ីចង្វាក់គ្នាដល់គណៈកម្មាធិការ MDA នៃខេត្តដែលអនុវត្ត និងមានករណីមរណភាពមាតា បាត់ទិន្នន័យពីព័ត៌មាន នៃការពិនិត្យផ្ទៃពោះ ការរាយការណ៍ខ្វះអំពីចំនួន នៃការស្លាប់ និងគុណភាពមិនល្អ នៃអនុសាសន៍ MDA ។[50] ប្រព័ន្ធស្រាវជ្រាវមរណភាព ទារកទើបនឹងកើត (NDA) ត្រូវបានបង្កើតថ្មី ដោយផ្អែកលើការណែនាំ និងវិធីសាស្ត្ររបស់អង្គការ

[49] ក្រសួងសុខាភិបាលកម្ពុជា។ (២០២២)។ ធ្វើបច្ចុប្បន្នភាព និងពង្រីកយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិនៅកម្ពុជា (២០១៧-២០២៣)។
[50]ក្រសួងសុខាភិបាល ពិនិត្យលើផែនទីបង្ហាញផ្លូវគំនិតផ្តួចផ្តើមរហ័ស ដើម្បីកាត់បន្ថយអត្រាមរណភាពមាតា និងទារក ២០១៦-២០២០។

សុខភាពពិភពលោក ហើយត្រូវបានសាកល្បងនៅក្នុងមន្ទីរពេទ្យខេត្តចំនួន ៣ គឺបាត់ដំបង កំពង់ចាម និងតាកែវ ក្នុងឆ្នាំ ២០១៨ហើយពង្រីកទៅមន្ទីរពេទ្យខេត្តចំនួន២ផ្សេងទៀត គឺប៉ៃលិន និងពោធិ៍សាត់ក្នុងឆ្នាំ ២០១៩។ ប៉ុន្តែប្រព័ន្ធនេះមិនទាន់ត្រូវបានពិនិត្យឡើងវិញនៅឡើយទេ។ ការពិនិត្យឡើងវិញ និងការឆ្លើយតប គួរធ្វើឡើងដោយមូលដ្ឋានសុខាភិបាលនីមួយៗ ដែលទទួលខុសត្រូវ ដែលផែនការទាំងនេះមានឱកាសកាន់តែច្រើនក្នុងការទប់ស្កាត់ការស្លាប់ដែលកើតឡើងដដែលៗ បណ្តាលមកពីមូលហេតុដែលអាចបង្ការបាន ប្រសិនបើសកម្មភាពត្រូវបានអនុវត្ត។ ជាងនេះទៅទៀត កម្ពុជាកំពុងខ្វះខាតប្រព័ន្ធស្រាវជ្រាវគ្រោះថ្នាក់ដល់ជីវិត សម្រាប់មាតា ហើយ MPDSR មិនត្រូវបានបញ្ចូលទៅក្នុងដំណើរការធានាគុណភាពនៅឡើយ។

3) ផ្តោតលើអ្នកជំងឺ

ការថែទាំដោយផ្តោតលើអ្នកជំងឺ គឺជាការថែទាំសុខភាពដែលចាត់ទុកអ្នកជំងឺជាដៃគូស្មើគ្នា ដោយទទួលស្គាល់សមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងសុខភាព និងជួយពួកគេឱ្យទទួលបានចំណេះដឹង ជំនាញ និងទំនុកចិត្តដើម្បីជួយខ្លួនឯង។ អ្នកជំងឺគឺជាសសរស្តម្ភកណ្តាល នៃ "វិធីសាស្ត្រផ្អែកលើសិទ្ធិ" ដែលរដ្ឋាភិបាលកម្ពុជា (ដែលជា "អ្នកកាន់កាតព្វកិច្ច") អាចឱ្យប្រជាជនកម្ពុជា (ដែលជា "អ្នកកាន់សិទ្ធិ") ការប្រើប្រាស់សិទ្ធិរបស់ពួកគេ រួមទាំងសិទ្ធិទទួលបានសុខភាពផងដែរ។

យន្តការសម្រាប់អ្នកជំងឺ និងអតិថិជនផ្តល់មតិកែលម្អដល់អ្នកផ្តល់សេវា អំពីរបៀបដែលតម្រូវការរបស់ពួកគេអាចត្រូវបានដោះស្រាយឱ្យកាន់តែប្រសើរឡើង ជាពិសេសសម្រាប់អ្នកដែលមិនទាន់ទទួលបានការគ្របដណ្តប់ គឺនៅមានចំនួនកំណត់។ ការសិក្សាក្រៅផ្លូវការ ឬការសិក្សាដែលធ្វើឡើងតែមួយដងដើម្បីទទួលបានមតិកែលម្អ បង្ហាញថាអ្នកប្រើប្រាស់សេវាថែទាំសុខភាពមានការមិនពេញចិត្តចំពោះអាកប្បកិរិយា និងឥរិយាបថរបស់បុគ្គលិកសុខាភិបាល បង្ហាញថាអ្នកផ្តល់សេវាថែទាំសុខភាពខ្វះជំនាញ និងទឹកចិត្តក្នុងការផ្តល់សេវាថែទាំដែលផ្តោតលើអ្នកជំងឺ និងខ្វះភាពរួសរាយរាក់ទាក់។ លើសពីនេះ ពួកគេខ្វះព័ត៌មានគ្រប់គ្រាន់ដើម្បីផ្តល់ឱ្យអ្នកជំងឺនូវចំណេះដឹងពេញលេញអំពីសេវាកម្ម និងអត្ថប្រយោជន៍ ដើម្បីឱ្យពួកគេអាចជួយខ្លួនឯងបាន។ ជាឧទាហរណ៍ ចំណេះដឹង និងការយល់ដឹងអំពីកញ្ចប់១០០០ថ្ងៃ ក្នុងចំណោមបុគ្គលិកថែទាំសុខភាព គឺនៅមានកម្រិត ហើយម្តាយត្រូវបានគេរាយការណ៍ជាញឹកញាប់ជឿថាសេវានេះគឺសម្រាប់កូនរបស់ពួកគេតែប៉ុណ្ណោះ ដែលនេះនាំឱ្យមានការកាត់បន្ថយការចង់ស្វែងរកសេវាថែទាំក្រោយសម្រាល។[51]

សេវាប្រកបដោយមិត្តភាពសម្រាប់មនុស្សវ័យជំទង់ និងយុវវ័យ (AYFS) មិនអាចប្រើបានពេញលេញទេ ហើយការរក្សាឯកជនភាព គឺមិនមានភាពជាប់លាប់នៅតាមមូលដ្ឋានថែទាំសុខភាពឡើយ។ ទាំងនេះ គឺជាឧបសគ្គដល់អ្នកជំងឺក្នុងការទទួលបានការថែទាំ ទំនុកចិត្ត និងការគ្រប់គ្រងសុខភាពរបស់ពួកគេផ្ទាល់។ សហគមន៍ដែលត្រូវបានគេផាត់ចេញ ប្រឈមមុខនឹងឧបសគ្គខ្ពស់ក្នុងការចូលទៅកាន់សេវា SRHR រួមមានការរើសអើងដោយប្រព័ន្ធសុខាភិបាល។ ភាពមិនស្មើគ្នានៃការគ្របដណ្តប់សេវា ANC និង PNC នៅតាមខេត្ត កម្រិតនៃការអប់រំ និងចំណាត់ថ្នាក់ នៃប្រាក់ចំណូលបង្ហាញពីបញ្ហានេះ។

WHO ក៏បញ្ជាក់ផងដែរថា គុណភាព នៃការថែទាំក៏អាស្រ័យទៅលើសេវាដែល៖ ១) ទាន់ពេលវេលាដើម្បីជៀសវាងការពន្យារពេលដែលបង្កគ្រោះថ្នាក់ ២) សមធម៌ក្នុងការទទួលបានការថែទាំដែលមានគុណភាព

[51]លទ្ធផលសិក្សាសាកល្បងពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ផ្តល់តាមរយៈការពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធនៅកម្រិតអនុក្រុមការងារបច្ចេកទេសស្តីពីសុខភាពមាតា និងទារក។

សម្រាប់ប្រជាជនទាំងអស់ ៣) ការដាក់បញ្ចូលសេវាពេញលេញពេញមួយជីវិត និង៤) បង្កើនធនធានប្រកបដោយប្រសិទ្ធភាព។ ការបញ្ជូនបន្ត និងសមាហរណកម្មសេវាកម្មដែលមានបង្ហាញនៅក្នុងយុទ្ធសាស្ត្រផ្នែកទី ៣។ ការថែទាំប្រកបដោយសមធម៌ និងប្រសិទ្ធភាព នៃការចំណាយត្រូវបានបញ្ជ្រាប និងបង្ហាញយ៉ាងស៊ីជម្រៅនៅក្នុងយុទ្ធសាស្ត្រផ្នែកទី ៦។

**អន្តរាគមន៍ដែលបានស្នើឡើង៖**

1) ភាពអាចរកបាន

- ពង្រឹងភាពអាចរកបាន នៃសំណុំសកម្មភាពអប្បបរមា ដែលបានធ្វើបច្ចុប្បន្នភាព(MPA) និងសំណុំសកម្មភាពបង្គ្រប់ (CPA) នៅទូទាំងប្រទេស
- បង្កើនសមត្ថភាពអ្នកផ្តល់សេវាសម្រាប់ការផ្តល់ប្រឹក្សាស្តីពីការពន្យារកំណើត និងការផ្តល់សេវាផែនការគ្រួសារតាមរយៈការបណ្តុះបណ្តាល ការបង្វឹកនៅនឹងកន្លែងធ្វើការផ្ទាល់ និងការចុះអភិបាលគាំទ្រ
- បង្កើនមធ្យោបាយពន្យារកំណើតនៅតាមមន្ទីរពេទ្យបង្អែក រួមទាំងមធ្យោបាយអចិន្ត្រៃយ៍
- បង្កើនការផ្គត់ផ្គង់ និងការប្រើប្រាស់មធ្យោបាយពន្យារកំណើតរយៈពេលវែងយ៉ាងតិចមួយមុខ (កងដាក់ក្នុងស្បូន ឬកងដាក់ក្រោមស្បែក)
- ពង្រឹងភាពជាដៃគូវិស័យសាធារណៈឯកជន ដើម្បីធានាការផ្តល់សេវាពន្យារកំណើតប្រកបដោយគុណភាព និងការរាយការណ៍ដោយទាន់ពេលវេលា និងត្រឹមត្រូវពីវិស័យឯកជន
- បង្កើនចំនួន និងការចែកចាយតាមភូមិសាស្ត្រនៃសេវាសុខភាពដែលមានប្រសិទ្ធភាពខ្ពស់ដែលមានស្រាប់ ដែលមិនទាន់បានពង្រីកនៅទូទាំងប្រទេស៖ មធ្យោបាយពន្យារកំណើត ការចាក់វ៉ាក់សាំង HPV ការពិនិត្យ និងព្យាបាលជំងឺមហារីកមាត់ស្បូន សេវារំលូតកូនដោយសុវត្ថិភាព ការគាំទ្រទាក់ទងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ
- ណែនាំសេវាថ្មីដែលមានប្រសិទ្ធភាពខ្ពស់ ដែលមិនទាន់មាននៅក្នុងប្រទេសកម្ពុជាទៅក្នុងយុទ្ធសាស្ត្រជាតិ ធានានូវភាពដែលអាចរកបានប្រកបដោយសមធម៌ និងនិរន្តរភាព (រួមទាំងសេវាសុខភាពផ្លូវចិត្តទាក់ទងនឹង SRHR ការប្រឹក្សា ឬការព្យាបាលរោគសញ្ញាទាក់ទងនឹងការផ្លាស់ប្តូរអំឡុងពេលអស់រដូវ ការព្យាបាលធ្វើឱ្យមានកូន សេវា SRHR សម្រាប់បុរស)។
- ពង្រឹងសេវាឌីជីថលដែលមានស្រាប់ ឬដាក់បញ្ចូលសេវាឌីជីថលថ្មីសម្រាប់ការផ្តល់សេវាថែទាំវេជ្ជសាស្ត្រពីចម្ងាយ(telemedicine) ទៅក្នុងគំរូ នៃការថែទាំដែលមានស្រាប់ ជាពិសេសសម្រាប់ប្រជាជនដែលពិបាកទៅដល់។
- ផ្តល់ការអប់រំជាលក្ខណៈប្រព័ន្ធអំពី CSE និងអនាម័យពេលមករដូវ ដល់សិស្សានុសិស្សទាំងអស់នៅសាលារៀន និងយុវជនក្រៅសាលា រួមទាំងការកសាងសមត្ថភាពរបស់អ្នកអប់រំក្នុងការផ្តល់កម្មវិធីសិក្សា។

2) ប្រសិទ្ធភាព និងសុវត្ថិភាព

- ពង្រឹងបទប្បញ្ញត្តិ និងការត្រួតពិនិត្យគុណភាព នៃការថែទាំអនុវត្តដោយសេវាឯកជននៅកម្រិត PHC និងកម្រិតខ្ពស់ជាងនេះ (បន្ទប់ពិគ្រោះ ព្យាបាល បន្ទប់ថែទាំ...)
- ពង្រីកការប្រមូលទិន្នន័យដើម្បីកំណត់គុណភាពនៃសេវាទាំងអស់ដែលទាក់ទងនឹង SRHR តាមរយៈទិន្នន័យរដ្ឋបាល និងយន្តការសម្រាប់អ្នកជំងឺផ្តល់ព័ត៌ត្រឡប់ជាប្រចាំ ដើម្បីកំណត់ភាពខ្វះខាត នៃគុណភាព និងពង្រឹងគុណភាព
- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពកញ្ចប់សេវាសំខាន់ៗ ដើម្បីដាក់បញ្ចូលសេវា វាយតម្លៃ ផ្លូវចិត្ត-សង្គម និងការគាំទ្រដល់ឪពុកម្តាយអំឡុងពេលមានផ្ទៃពោះ និងក្រោយ ពេលសម្រាល
- ការពង្រឹងគុណភាពនៃការផ្តល់សេវា ដែលកន្លងមកមានស្ថានភាពមិនល្អ ឬជាប់គាំង ដូចជា អតិថិជនក្នុងពេល ANC ដែលធ្វើតេស្តរកមេរោគអេដស៍ និងទទួលបានលទ្ធផលរបស់ពួកគេ ភាគរយ នៃអតិថិជនដែលធ្វើតេស្តរកពេគស្វាយ ភាគរយនៃស្ត្រីដែលរៀបការរួចកំពុងប្រើមធ្យោបាយពន្យារកំណើតរយៈពេលវែង ឬជាអចិន្ត្រៃយ៍
- ពង្រីកការអនុវត្តឧបករណ៍ និងប្រព័ន្ធធានាគុណភាពដែលមានស្រាប់នៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន
- ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំដើម្បីឆ្លុះបញ្ចាំងពីការអនុវត្តល្អបំផុតជាសាកល និង ពង្រឹងប្រសិទ្ធភាព និងភាពងាយស្រួល នៃគោលការណ៍ណែនាំ
- ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រជាតិស្តីពី MPDSR និងធ្វើបច្ចុប្បន្នភាពទម្រង់ និងដំណើរការទាំងអស់ស្របតាមការណែនាំជាសាកល ដោយសង្កត់ធ្ងន់កាន់តែខ្លាំងលើការអនុវត្តថ្នាក់ក្រោមជាតិ រួមទាំងការកសាងសមត្ថភាពនៅកម្រិតមូលដ្ឋានផ្តល់សេវាដូច្នេះការត្រួតពិនិត្យឡើងវិញ និងផែនការឆ្លើយតប រួមចំណែកដល់ការកែលម្អគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព រួមមាន ប្រព័ន្ធស្រាវជ្រាវមរណភាពមាតា (MDA) និងប្រព័ន្ធស្រាវជ្រាវមរណភាពទារកទើបនឹងកើត (NDA) និងផ្តួចផ្តើមប្រព័ន្ធស្រាវជ្រាវមរណភាពមាតាដែលប្រឈមនឹងគ្រោះថ្នាក់ខ្ពស់
- អនុវត្តការត្រួតពិនិត្យទៅលើចំណាត់ថ្នាក់តាមវិធីសាស្ត្រ Robsons ចំពោះការសម្រាលកូនដោយវះកាត់ និងកំណត់គោលដៅសម្រាប់វាយតម្លៃមន្ទីរពេទ្យ ទាំងនៅក្នុងគ្រឹះស្ថានសាធារណៈ និងឯកជន
- ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងជាមួយវិស័យផ្សេងទៀត សម្រាប់អ្នកស្វែងរកការថែទាំសុខភាពដែលត្រូវការជំនួយបន្ថែម ដូចជាអ្នករស់រានមានជីវិតពី GBV ជាដើម សម្របសម្រួលវិធីសាស្ត្រទំនាក់ទំនងដោយផ្អែកលើក្រុម។

3) ផ្តោតលើអ្នកជំងឺ

- ធ្វើការស្រាវជ្រាវលើគុណភាព នៃសេវាសុខភាពនៅគ្រប់កម្រិត តាមរយៈវិធីសាស្ត្រដែលបានរៀបចំឡើងជាមួយសហគមន៍ ដើម្បីវាយតម្លៃការយល់ឃើញរបស់អ្នកជំងឺ ដើម្បីកំណត់គម្លាត និងប្រើប្រាស់ព័ត៌មានដើម្បីកែលម្អគុណភាពសេវា
- ពង្រឹងធនធានមនុស្សលើជំនាញថែទាំសុខភាពផ្អែកលើសិទ្ធិ ដូចជាការពង្រឹងទំនាក់ទំនងឱ្យកាន់តែប្រសើរឡើង ការថែទាំប្រកបដោយការគោរព និងការផ្តល់សិទ្ធិអំណាចដល់អតិថិជន ពង្រឹងសមត្ថភាព ជំនាញ និងចំណេះដឹងរបស់អ្នកផ្តល់សេវា ក្នុងការកំណត់អត្តសញ្ញាណ និងឆ្លើយតបចំពោះស្ត្រី និងកុមាររងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់
- ជូនដំណឹងដល់សហគមន៍អំពីរបៀបក្នុងការស្វែងរកទីកន្លែងផ្តល់សេវាដែលមានសុវត្ថិភាព និងអាចដោះស្រាយបញ្ហារបស់ពួកគេ
- ពង្រឹងការអនុវត្តន៍សេវាសុខភាពយុវវ័យប្រកបដោយមិត្តភាព (AYFS) នៅតាមមូលដ្ឋានសុខាភិបាល និងតាមរយៈការចូលរួមរបស់បុគ្គលិកសុខាភិបាលជាមួយសាលារៀន និងសហគមន៍
- ពង្រឹង SOPs និងគោលការណ៍ណែនាំជុំវិញការផ្តល់ឯកជនភាព និងការសម្ងាត់នៅក្នុងមូលដ្ឋានផ្តល់សេវា ដើម្បីជានានូវការគោរព សេចក្តីថ្លៃថ្នូរនៃការថែទាំ និងលើកកម្ពស់ការស្វែងរកសេវាថែទាំនៅមូលដ្ឋានសាធារណៈ
- វាយតម្លៃ និងពង្រឹងលទ្ធភាពទទួលបានសេវា SRHR សម្រាប់បុរស ដើម្បីបញ្ចៀសបទដ្ឋាន នៃភាពជាបុរសដែលបង្កគ្រោះថ្នាក់ និងលើកទឹកចិត្តឱ្យមានអាកប្បកិរិយាស្វែងរកការថែទាំសុខភាពក្នុងចំណោមបុរស។

## អាទិភាពជាយុទ្ធសាស្ត្រ ២. លើកកម្ពស់ការដាក់បុគ្គលិកសុខាភិបាលឱ្យបម្រើការងារក្នុងការផ្តល់ព័ត៌មាន និងសេវារបស់ SRHR ។

### ប្រយោគបញ្ហា

បុគ្គលិកសុខាភិបាលដែលផ្តល់សេវា SRHR មិនទាន់មានគ្រប់គ្រាន់ នៅខ្វះខាតជំនាញ ការគ្រប់គ្រង ការលើកទឹកចិត្ត ឬមិនទាន់សម្របខ្លួនបានទៅនឹងវិបត្តិសុខភាពនានា ដែលនេះជាឧបសគ្គដ៏សំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវលទ្ធផល SRHR ។

### បញ្ហាប្រឈមសំខាន់ៗ

1) ការវាយតម្លៃ និងការធ្វើផែនការៈ

គ្មានទិន្នន័យគ្រប់គ្រាន់អំពីចំនួនបុគ្គលិកនៅនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស (រួមមានអ្នកផ្តល់សេវាផ្នែកឯកជន ទីតាំងផ្តល់សេវា រយៈពេលដែលត្រូវការសម្រាប់ការផ្តល់សេវាណាមួយ គុណសម្បត្តិ និងវិញ្ញា

បនប័ត្រ និងការចូលនិវត្តន៍នាពេលខាងមុខ) ដែលនេះរារាំងដល់ការធ្វើផែនការ ការបែងចែក និងការគ្រប់គ្រងអ្នកផ្តល់សេវា ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការ ។

2) ការបែងចែក ការរក្សាទុក ការបង្កើនប្រសិទ្ធភាព៖

គ្រឹះស្ថានសុខាភិបាល ១៧% មិនមានចំនួនឆ្មបមធ្យមគ្រប់គ្រាន់ទៅតាមការណែនាំនោះទេចំនួនសិស្សដែលដាក់ពាក្យសុំសិក្សាកម្មវិធីឆ្មបកំពុងថយចុះជារៀងរាល់ឆ្នាំ ហើយមានការខ្វះខាតឆ្មបនៅកម្រិតមណ្ឌលសុខភាព។ បុគ្គលិកសុខាភិបាល មិនបាននៅជាប់លាប់ក្នុងមណ្ឌលសុខភាពនោះទេ ដោយសារប្រាក់ខែទាប និងការគ្រប់គ្រងនៅមានភាពខ្វះខាត។ អ្នកផ្តល់សេវាសុខភាព មិនទទួលបានការធានាជាប់លាប់នូវបរិយាកាសសុវត្ថិភាព និងការគាំទ្រ ដែលនេះធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យពីការបៀតបៀន ។ យុទ្ធសាស្ត្រដើម្បីបង្កើនប្រសិទ្ធភាព សម្រាប់បុគ្គលិកមានដូចជាការផ្លាស់ប្តូរភារកិច្ចជាដើម ត្រូវបានគេប្រើប្រាស់តិចជាងមុន។ យុទ្ធសាស្ត្រជ្រើសរើស ការដាក់ឱ្យបម្រើការងារ និងការរក្សាទុក គឺចាំបាច់សម្រាប់ឆ្មប និងបុគ្គលិក SRMNCH សំខាន់ៗផ្សេងទៀត គឺជាបញ្ហាអាទិភាព។

3) ការបណ្តុះបណ្តាល និងការទទួលស្គាល់៖

ការអប់រំផ្នែកឆ្មបត្រូវបានរៀបចំតាមស្តង់ដារសហព័ន្ធឆ្មបអន្តរជាតិ (ICM) ដើម្បីអនុវត្តតាមការអនុវត្តល្អបំផុតជាសាកល ដូចជាការផ្អែកលើសមត្ថភាពជាដើម។ ទោះជាយ៉ាងនេះក្តី ការអប់រំផ្នែកឆ្មបមុនបម្រើការងារ ត្រូវតែបន្តពង្រឹក និងរួមបញ្ចូលនូវការអភិវឌ្ឍន៍ថ្មី និងនិន្នាការជំងឺថ្មី ដើម្បីបង្កើនប្រសិទ្ធភាពជំនាញព្យាបាល។ ជាឧទាហរណ៍ សេវាដែលត្រូវតែផ្តល់អាទិភាពសម្រាប់ការដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រនេះ រួមមាន ការធ្វើតេស្តរោគស្វាយ ការតេស្តរក EENC សម្រាប់ទារកទើបនឹងកើត ការអនុវត្តសម្រាប់ការពន្យារកំណើតរយៈពេលយូរ ការរំលូតកូននៅត្រីមាសទីពីរ ការថែទាំ និងការប្រឹក្សាអំពីភាពគ្មានកូន។ គោលការណ៍ណែនាំអំពីសេវាសុខភាពយុវវ័យប្រកបដោយមិត្តភាព ត្រូវតែកែសម្រួល និងធ្វើបច្ចុប្បន្នភាពជាប្រចាំដើម្បីធានាថាគោលការណ៍ទាំងនេះឆ្លុះបញ្ចាំងពីនិន្នាការថ្មីៗ នៃតម្រូវការសុខភាពយុវវ័យ។ ការអប់រំជំនាញឆ្មបមុនបម្រើការងារត្រូវតែបន្ត ពង្រឹងជំនាញ និងការថែទាំដោយផ្តោតលើអ្នកជំងឺ ការថែទាំប្រកបដោយការគោរព និងសេចក្តីថ្លៃថ្នូរ សមភាពយេនឌ័រ សេវាសុខភាពយុវវ័យប្រកបដោយមិត្តភាព និងការបណ្តុះបណ្តាល ស្តីពីការរើសអើង។ ការអប់រំក្នុងពេលបម្រើការងារ ត្រូវតែស្របតាមស្តង់ដារដែលបង្កើតឡើងសម្រាប់ការអភិវឌ្ឍន៍វិជ្ជាជីវៈជាបន្តបន្ទាប់ដែលបានណែនាំនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងនេះក្តីការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ នៅតែពឹងផ្អែកយ៉ាងខ្លាំងលើម្ចាស់ជំនួយ កើតឡើងដោយឥតព្រៀងទុក និងមិនត្រូវបានអនុវត្តជាលក្ខណៈទ្រង់ទ្រាយធំ ដែលនេះធ្វើឱ្យការគ្របដណ្តប់មិនបានគ្រប់គ្រាន់។ ឧទាហរណ៍ ផែនការពង្រីកភាពអាចរកបាននូវ CAC ដែលបានគូសចេញពីជំហានក្នុងការពង្រីក នៃការបណ្តុះបណ្តាលអំពី CAC នៅទូទាំងប្រទេស មិនត្រូវបានអនុវត្តពេញលេញនោះទេ ដោយសារធនធានហិរញ្ញវត្ថុ និងធនធានមនុស្សមានកម្រិត។ កម្មវិធីសិក្សាមុនពេល និងក្នុងពេលបម្រើការងារ គឺមិនមានភាពសមស្របគ្នានោះទេ ដោយសារកម្មវិធីទាំងពីរនេះត្រូវបានធ្វើបច្ចុប្បន្នភាព និងយន្តការត្រួតពិនិត្យដាច់ដោយឡែកពីគ្នា។ ការបណ្តុះបណ្តាល និងគុណភាព នៃការថែទាំរបស់អ្នកផ្តល់សេវាឯកជនមិនត្រូវបានគ្រប់គ្រង ឬត្រួតពិនិត្យនោះទេ។

4) ការត្រួតពិនិត្យ និងការគាំទ្រ៖

អ្នកផ្តល់សេវាសុខាភិបាលសាធារណៈត្រូវបានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំតាមរយៈការចុះពិនិត្យជាប្រចាំរបស់រដ្ឋាភិបាល ក៏ដូចជាតាមរយៈការវាយតម្លៃដែលគាំទ្រដោយម្ចាស់ជំនួយ ដូចជាកម្មវិធីជាតិត្រួតពិនិត្យការពង្រឹងគុណភាពក្រោមកម្មវិធី H-EQIP និង H-EQIP II និងប័ណ្ណដាក់ពិន្ទុសម្រាប់សុខភាពមាតា ទារក កុមារ និង អាហារូបត្ថម្ភ ក្រោមគម្រោងអាហារូបត្ថម្ភកម្ពុជា ប៉ុន្តែការគ្របដណ្តប់ ប្រសិទ្ធភាព និងនិរន្តរភាពនៃការវាយតម្លៃគឺនៅតែមានចន្លោះប្រហោងនៅឡើយ។ ម៉្យាងទៀតអ្នកផ្តល់សេវាឯកជនមិនត្រូវបានត្រួតពិនិត្យ ឬវាយតម្លៃតាមរយៈយន្តការដែលដឹកនាំ ឬចែករំលែកជាមួយវិស័យសាធារណៈឡើយ។ លើសពីនេះទាំងអ្នកផ្តល់សេវាសាធារណៈ និងឯកជន មិនត្រូវបានបង្វឹក និងណែនាំបានជាប់លាប់ដោយអ្នកដែលមានជំនាញជាងពួកគេនោះទេ ហើយអ្នកគ្រប់គ្រងក៏មិនបានចូលរួមពាក់ព័ន្ធក្នុងការវាយតម្លៃផងដែរ។ ការអនុវត្តនេះ មិនដូចទៅនឹងការណែនាំដោយការអនុវត្តល្អបំផុតជាសកលនោះទេ។ ការអនុវត្តបទប្បញ្ញត្តិនៅមូលដ្ឋានសាធារណៈ និងឯកជន មិនមានការទទួលស្គាល់ និងការមានវិញ្ញាបនប័ត្រ គឺនៅមានកម្រិត។

5) ការត្រៀមខ្លួនសម្រាប់វិបត្តិ៖

អ្នកផ្តល់សេវាថែទាំសុខភាព SRHR អ្នកគ្រប់គ្រងកម្មវិធី និងអ្នកដឹកនាំថ្នាក់ជាតិ មិនបានគិតគូររៀបចំដើម្បីរក្សាការផ្តល់សេវា SRHR នៅពេលប្រឈមមុខនឹងវិបត្តិសុខភាពនាពេលអនាគត ឬភាពអាសន្នផ្សេងទៀត។

**អន្តរាគមន៍ដែលបានស្នើឡើង៖**

1) ការវាយតម្លៃ និងការធ្វើផែនការ
   - អនុម័ត និងអនុវត្តផែនការអភិវឌ្ឍន៍កម្លាំងពលកម្មសុខភាព ២០២៣-២០៣៣
   - ពង្រឹងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សដើម្បីបង្កើត និងប្រើប្រាស់ទិន្នន័យសម្រាប់ការវិភាគ (រួមទាំងការវិភាគទីផ្សារការងារផ្នែកសុខភាព) ការធ្វើផែនការ ការតាមដាន និងការគ្រប់គ្រង
   - កែសម្រួលឡើងវិញនូវវិសាលភាពការងាររបស់ឆ្មប ដើម្បីឆ្លុះបញ្ចាំងពីការទទួលខុសត្រូវបន្ថែមដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ
   - បង្កើតឱកាសសម្រាប់ឱ្យឆ្មបបង្ហាញពីតម្រូវការបរិយាកាសការងារ និងចូលរួមក្នុងការដោះស្រាយបញ្ហាទាំងនោះ និងផ្តល់ឱកាសដែលផ្តល់សិទ្ធិអំណាចដល់ពួកគេក្នុងនាមជាអ្នកជំនាញ
   - វាយតម្លៃតម្រូវការថវិកាសម្រាប់ការពង្រឹងធនធានមនុស្ស និងបែងចែកថវិកាជាតិដើម្បីដោះស្រាយតម្រូវការទាំងនេះឱ្យបានគ្រប់គ្រាន់។

2) ការបែងចែក ការរក្សាទុក ការបង្កើនប្រសិទ្ធភាព
   - រៀបចំ និងអនុវត្តគោលនយោបាយដើម្បីលើកទឹកចិត្ត និងរក្សាឆ្មប ជាពិសេសផ្តោតលើការជ្រើសរើសបុគ្គលិកសម្រាប់ភូមិសាស្ត្រដែលមិនទាន់បានបម្រើសេវា និងសេវាដែលមិនទាន់បានផ្តល់ (ដូចជា CAC)
   - កំណត់ឱកាសសម្រាប់ការបង្កើនប្រសិទ្ធភាពធនធានមនុស្ស នៃសេវា SRHR តាមរយៈការផ្លាស់ប្តូរភារកិច្ច

- សាកល្បងគំរូ នៃការលើកទឹកចិត្តប្រកបដោយភាពច្នៃប្រឌិត ដូចជាការលើកទឹកចិត្តដែលមិនមែនជាហិរញ្ញវត្ថុ ឬការលើកទឹកចិត្តដោយផ្អែកលើលទ្ធផល នៃការបំពេញការងារ ដើម្បីកែលម្អការផ្តល់សេវា
- ប្រើបច្ចេកវិទ្យាដែលមានស្រាប់ ឬថ្មីសម្រាប់សេវាសុខភាពតាមប្រព័ន្ធឌីជីថល ស្របតាមតម្រូវការរបស់សហគមន៍ ដែលមិនទាន់ទទួលបានការគ្របដណ្តប់សេវា និងសហគមន៍ដែលទទួលបានសេវាមិនគ្រប់គ្រាន់ដោយសារឧបសគ្គក្នុងការទទួលបានសេវាសុខភាព
- ប្រើបច្ចេកវិទ្យាដែលមានស្រាប់ ឬថ្មីដើម្បីជួយសម្រួលដល់ប្រធាន និងបុគ្គលិកទទួលបន្ទុកការងាររដ្ឋបាល និងការងារគ្រប់គ្រងមូលដ្ឋានសុខាភិបាល ដើម្បីឱ្យពួកគេមានពេលច្រើនផ្តោតលើការថែទាំអ្នកជំងឺ។

3) ការបណ្តុះបណ្តាល និងការទទួលស្គាល់

- បណ្តុះបណ្តាលអ្នកគ្រប់គ្រងមណ្ឌលសុខភាពនៅក្នុងផ្នែក SRHR ទាក់ទងនឹងការគ្រប់គ្រងធនធានមនុស្ស និងការការពារបុគ្គលិកទាំងអស់
- ធ្វើឱ្យសម្រេចរួចរាល់នូវការដាក់ឱ្យដំណើរការ នៃការអប់រំពង្រឹងសមត្ថភាពឆ្មបនៅទូទាំងប្រទេស ដោយការកសាងសមត្ថភាពសមាជិកនៅតាមមហាវិទ្យាល័យ ដើម្បីអនុវត្តកម្មវិធីអប់រំពង្រឹងសមត្ថភាព (CBE) និងរៀបចំផែនការជ្រើសរើសអ្នកដែលមានជំនាញឱ្យទៅបន្ថែមជំនាញកាន់តែខ្ពស់ថែមទៀត
- វាយតម្លៃ និងអនុវត្តការកែលម្អជាចាំបាច់នៃអាទិភាពរបស់គ្រឹះស្ថានបង្រៀន
- ពង្រឹងកម្មវិធីបណ្តុះបណ្តាលមុនបម្រើការងារដើម្បីដោះស្រាយគម្លាត នៃសមត្ថភាពគ្លីនិក (ជាពិសេសសម្រាប់សេវាដូចខាងក្រោម៖ មធ្យោបាយពន្យារកំណើតរយៈពេលវែង ការថែទាំដំបូងចាំបាច់សម្រាប់ទារកទើបនឹងកើត (EENC) មេរោគស្វាយ រំលូតកូន វ៉ាក់សាំងHPV ការគ្រប់គ្រងរដូវ សុខភាពស្ត្រីវ័យចំណាស់ ស្ត្រីអស់រដូវ និង ការពិនិត្យមហារីកសុដន់ និងមាត់ស្បូន)
- ពង្រឹងកម្មវិធីបណ្តុះបណ្តាលមុនបម្រើការងារ ដើម្បីកំណត់សមត្ថភាពផ្តល់ប្រឹក្សា ក្នុងការបង្កើនជំនាញរបស់បុគ្គលិកសុខាភិបាល នូវការថែទាំអ្នកជំងឺដោយយកចិត្តទុកដាក់ ការគោរព និងសេចក្តីថ្លៃថ្នូរ អនុវត្តការយល់ដឹងអំពីយេនឌ័រចំពោះបុរស ស្ត្រី និងមនុស្សវ័យជំទង់ ជាពិសេសចំពោះក្រុមដែលខ្វះខាត ដោយមិនមានការរើសអើង
- បណ្តុះបណ្តាលបុគ្គលិកសុខាភិបាលលើភាពចម្រុះ នៃសមភាពយេនឌ័រ និងបរិយាបន្នសង្គម (GEDSI)
- រៀបចំសិក្ខាសាលាស្តីពីការបញ្ជាក់ពីគុណតម្លៃ និងការផ្លាស់ប្តូរឥរិយាបថ សម្រាប់បុគ្គលិកសុខាភិបាល និងបុគ្គលិកផ្សព្វផ្សាយសហគមន៍ដែលផ្តល់ព័ត៌មាន អំពីសេវាសុខភាពបន្តពូជ
- បង្កើនសមត្ថភាពអ្នកផ្តល់សេវាលើការប្រើប្រព័ន្ធឌីជីថល ដែលកំពុងត្រូវបានប្រើសម្រាប់សេវា SRHR និងM&E

- កៀរគរធនធានពីប្រភពក្នុងស្រុក និងម្ចាស់ជំនួយ ដើម្បីផ្តល់មូលនិធិដល់ការអនុវត្តអាទិភាព នៃការបណ្តុះបណ្តាល ដែលមានស្រាប់រួមទាំងផែនការពង្រីកភាពអាចរកបាននៃ CAC
- បណ្តុះបណ្តាលបុគ្គលិកមណ្ឌលសុខភាពអំពីការយល់ដឹងជាមូលដ្ឋានអំពីភាពគ្មានកូន ការផ្តល់ប្រឹក្សាជាមួយនឹងអ្នកជំងឺប្រកបដោយការគាំទ្រ ការគ្រប់គ្រងករណី ការផ្តល់សេវា ដែលងាយស្រួលសម្រាប់យុវវ័យទំនាក់ទំនងជំងឺកាមរោគជាមួយភាពគ្មានកូន ផលប៉ះពាល់ នៃជំងឺកាមរោគលើស្ត្រីនិងបុរស និងការបញ្ជូនទៅរកការថែទាំដែលមានឯកទេសខ្ពស់បន្ថែមទៀត
- បង្កើតយន្តការ និងក្របខណ្ឌគណនេយ្យភាពសម្រាប់ក្រុមការងារសុខភាពមាតា និងទារក ដើម្បីធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាបណ្តុះបណ្តាលមុន និងក្នុងពេលបម្រើការងារឱ្យបានទៀងទាត់ និងដើម្បីធានាថាកម្មវិធីទាំងពីរនេះមានភាពសមស្របជាមួយគ្នា
- ពង្រឹងការបន្តនូវឱកាស និងយន្តការ នៃការអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់ឆ្មប ជាពិសេសសម្រាប់អ្នកធ្វើការនៅទីតាំងដាច់ស្រយាល ដើម្បីកសាងជំនាញកម្រិតខ្ពស់បន្ថែមទៀតតាមរយៈបទពិសោធន៍ធ្វើការនៅតាមមន្ទីរពេទ្យបង្អែក ឬមន្ទីរពេទ្យជាតិ
- ពិនិត្យឡើងវិញនូវពិធីសារស្តីពីការសម្រាលកូនដោយការវះកាត់ និងវគ្គបណ្តុះបណ្តាលដើម្បីកាត់បន្ថយការសម្រាលកូនដោយការវះកាត់ ដែលមិនត្រូវបានចង្អុលបង្ហាញដោយវេជ្ជសាស្ត្រ
- ពង្រឹងសមត្ថភាពលើការគ្រប់គ្រងការអូសបន្លាយ និងការរាំងស្ទះក្នុងពេលសម្រាលកូនរួមទាំងការជួយក្នុងការសម្រាលកូនដោយការបូម រួមមាននៅកម្រិត BEmONC ដែលនេះនឹងកាត់បន្ថយការស្លាប់ និងការសម្រាលកូនដោយការវះកាត់ ។

4) ការត្រួតពិនិត្យ និងការគាំទ្រ

- ពង្រឹងយន្តការវាយតម្លៃគុណភាព នៃការថែទាំដែលមានស្រាប់ ដែលប្រើសម្រាប់ សេវា SRHR ដូចជា យន្តការដែលត្រូវបានបង្កើតឡើងក្រោម HEQIP II ការត្រួតពិនិត្យការគាំទ្រទៀងទាត់ និងកិច្ចប្រជុំ MCAT ដោយវាយតម្លៃ នៃគុណភាព ដើម្បីធានាបាននូវសេវា SRHR គ្រប់ជ្រុងជ្រោយ រួមមានការដាក់បញ្ចូលនូវការថែទាំដែលមិនរើសអើង និងផ្អែកលើសិទ្ធិមនុស្ស និងពង្រឹងការប្រើលទ្ធផលសម្រាប់ធ្វើផែនការសកម្មភាព និងការតាមដាន
- ពង្រឹងបទប្បញ្ញត្តិ និងយន្តការពាក់ព័ន្ធស្តីពីការទទួលស្គាល់ និងការចេញវិញ្ញាបនបត្រ ដោយសហការជាមួយក្រុមប្រឹក្សាគណៈឆ្មបកម្ពុជា និងវិស័យឯកជន
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស (ឧ. តាមរយៈយន្តការកសាងសមត្ថភាព និងការបង្វឹក) ដល់អ្នកផ្តល់សេវាឯកជន ស្របជាមួយនឹងស្តង់ដារ នៃការផ្តល់សេវាមានគុណភាព និងការអនុវត្តល្អបំផុត ស្របតាមគោលការណ៍ណែនាំ និងពិធីសារជាតិ
- បង្កើតអ្នកគ្រប់គ្រង និងបន្ថែមនូវភាពអាចរកបាន នៃប្រព័ន្ធដែលអាចត្រួតពិនិត្យ និងគាំទ្រ តាមរយៈប្រព័ន្ធឌីជីថល ដោយការពិចារណាពីរបៀបដែលកម្រិតផ្សេងៗនៃឆ្មបអាចទទួលយកការទទួលខុសត្រូវបន្ថែមទៀត រួមទាំងការគ្រប់គ្រង និងការបង្ហាត់ណែនាំ

- កំណត់ឱកាស ដើម្បីធ្វើសមាហរណកម្មការត្រួតពិនិត្យ និងការគ្រប់គ្រងជាមួយ កម្មវិធីសុខភាពមាតា និងទារក ដែលទទួលបានមូលនិធិផ្សេងគ្នា ដូចជាកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។

5) ការត្រៀមខ្លួនសម្រាប់វិបត្តិ៖

- បណ្តុះបណ្តាលអ្នកផ្តល់សេវាសុខភាព ដែលមានទីតាំងនៅក្នុងតំបន់ ដែលមានលទ្ធភាពខ្ពស់ក្នុងការប្រឈមនឹងវិបត្តិទាក់ទងនឹងអាកាសធាតុ (MISP) ស្តីពីកញ្ចប់សេវាដំបូងអប្បបរមាសម្រាប់ SRHR ក្នុងគ្រាអាសន្ន។

## អាទិភាពជាយុទ្ធសាស្ត្រ ៣. ធ្វើឱ្យប្រសើរឡើងនូវសមាហរណកម្មសេវា និងការបញ្ជូនបន្តដើម្បីធានាបានភាពទាន់ពេលវេលា លទ្ធភាពទទួលបានសេវា SRHR គ្រប់ជ្រុងជ្រោយប្រកបដោយសមធម៌ នៅគ្រប់កម្រិត នៃការថែទាំ

### ប្រយោគបញ្ហា

លទ្ធភាពទទួលបានសេវា SRHR គឺនៅមានកម្រិត ដោយសារសមាហរណកម្មសេវានៅកម្រិតមណ្ឌលសុខភាពនៅមានកម្រិត យន្តការបញ្ជូនបន្តមិនដំណើរការបានល្អ ភាពស្មុគស្មាញក្នុងការថែទាំ និងគ្រប់គ្រងស្ថានភាពជំងឺ និងការគ្មានភាពជាប្រព័ន្ធក្នុងការផ្សារភ្ជាប់ទៅនឹងសេវាសាធារណៈក្រៅវិស័យសុខាភិបាល។ កត្តាទាំងនេះធ្វើឱ្យប្រជាជនមិនបានទទួលការថែទាំគ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាព។

### បញ្ហាប្រឈមសំខាន់ៗ

1) ការដាក់បញ្ចូលសេវានៅកម្រិតមូលដ្ឋានសុខាភិបាល

កម្មវិធីជាក់លាក់ពាក់ព័ន្ធ SRHR គឺនៅដាច់ដោយឡែកពីសេវាថែទាំសុខភាពបឋម ដោយសារកម្មវិធីទាំងនេះត្រូវបានផ្តល់មូលនិធិ រៀបចំផែនការ បង្រៀន និងតាមដានដោយឡែកពីគ្នា។[52] ការមាក់ងាយ និងការរើសអើងដែលទាក់ទងនឹងតម្រូវការសុខភាពជាក់លាក់ (ដូចជាមេរោគអេដស៍ SRHR សម្រាប់វ័យជំទង់ ឬ GBV) គឺជាឧបសគ្គចំពោះការទទួលបានសេវាសុខភាព ដោយសារបុគ្គលម្នាក់ៗអាចមានការស្ទាក់ស្ទើរក្នុងការស្វែងរកការថែទាំជាសាធារណៈ ទទួលបានការថែទាំដោយខ្វះការគោរព និងសេចក្តីថ្លៃថ្នូរ ឬត្រូវបានគេបដិសេធមិនផ្តល់សេវាឱ្យទាំងស្រុង។ អ្នកជំងឺខ្វះព័ត៌មាន និងការគាំទ្រក្នុងការតម្រង់ទិសដៅសម្រាប់ដំណើរថែទាំ និងគ្រប់គ្រងសុខភាពរបស់ពួកគេ ជាពិសេសនៅពេលដែលពួកគេត្រូវទៅពិនិត្យសុខភាពជាច្រើនដង ឬទៅពិនិត្យនៅកន្លែងផ្សេងៗគ្នាសម្រាប់សេវាពាក់ព័ន្ធ។ សេវាបង្ការ ដូចជាការបង្ការការចម្លងសម្រាប់អ្នកផ្ទុកមេរោគអេដស៍ ការផ្តល់ប្រឹក្សាលើបញ្ហាទាក់ទងនឹងនិន្នាការភេទ អត្តសញ្ញាណ និងការបង្ហាញយេនឌ័រ (SOGIE) កម្រ ត្រូវបានដាក់បញ្ចូលក្នុងកញ្ចប់សេវា PHC ឬ SRHR ដែលនេះបង្កើតនូវភាពគ្មានប្រសិទ្ធភាព និងការខកខានក្នុងការទទួលបានឱកាស ។[53]

2) ការបញ្ជូនទៅកាន់ការថែទាំដែលមានជំនាញឯកទេស

ការបញ្ជូនទៅកាន់សេវាដែលមានកម្រិតឯកទេសខ្ពស់ជាងសម្រាប់ការថែទាំ គឺមិនទាន់ពេលវេលា

[52]អង្គការសុខភាពពិភពលោក។ (២០២៣)។ ក្របខណ្ឌតំបន់សម្រាប់ការឈានទៅដល់ការមិនទាន់សម្រេចនៅប៉ាស៊ីហ្វិកខាងលិច (2022-2030)។

[53]មូលនិធិប្រជាជនអង្គការសហប្រជាជាតិ។ (២០២៣)។ បទដ្ឋានសង្គមដែលបង្កគ្រោះថ្នាក់ និងអំពើហិង្សាផ្អែកលើយេនឌ័រនៅកម្ពុជា។ គន្លិះទ្វេសដែលបានរៀបរាប់។

គ្មានបុគ្គលិកដែលមានសមត្ថភាពអមទៅជាមួយឱ្យបានគ្រប់គ្រាន់ គ្មានការបំពាក់គ្រប់គ្រាន់នូវឧបករណ៍ សង្គ្រោះបន្ទាន់ដែលមានមុខងារ គ្មានទំនាក់ទំនងគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យគ្រឹះស្ថានដែលរង់ចាំទទួលអាចរៀបចំសម្រាប់ការមកដល់ នៃអ្នកជំងឺដែលបានបញ្ជូន។ ទិន្នន័យអំពីសេវាសុខភាពដែលបានផ្តល់ឱ្យអ្នកជំងឺ និងលទ្ធផលសុខភាពមិនល្អដែលកើតមានឡើងនៅកម្រិតខ្ពស់ នៃការថែទាំ មិនបង្ហាញថាតើអ្នកជំងឺទទួលបានការព្យាបាលដំបូង និងត្រូវបានបញ្ជូនមកពីមូលដ្ឋានព្យាបាលម្រិតទាបនោះឡើយ ដែលនេះរារាំងដល់ភាពច្បាស់លាស់ នៃការសិក្សា ការស្រាវជ្រាវ ការកែលម្អគុណភាព និងគណនេយ្យភាព។ នៅឆ្នាំ ២០២០ មន្ទីរពេទ្យទាំងអស់ (១០០%) និង ៩៦,១% នៃមណ្ឌលសុខភាព មានសេវារថយន្តសង្គ្រោះបន្ទាន់។ សម្រាប់មណ្ឌលសុខភាព សេវានេះមានការកើនឡើងប្រហែល ២៥% ចាប់តាំងពីឆ្នាំ ២០១៤។ ប្រហែល ៩០% នៃអ្នកបើកបរបានរៀនវគ្គសង្គ្រោះបឋម ដែលរួមមានការគ្រប់គ្រងផ្លូវដង្ហើម ការគ្រប់គ្រងការហូរឈាមខាងក្រៅ៖ ការរុំបង់ឃាត់ឈាម និងច្រើនទៀត។ ៦២% នៃអគារដែលផ្តល់ CEmONC មានលទ្ធភាពទទួលបានការផ្គត់ផ្គង់ឈាមតាមរយៈធនាគារឈាម។ ភាពខ្វះខាតគឺជាគោលដៅ នៃផែនការកែលម្អ EmONC ចំពោះការការផ្គត់ផ្គង់ឈាម ២៤ ម៉ោងក្នុង១ថ្ងៃ ពេញមួយសប្តាហ៍ នៅក្នុង ៩០% នៃអគារដែលផ្តល់ CEmONC ។ ការតស៊ូមតិកម្រិតខ្ពស់ គឺត្រូវការជាចាំបាច់ដើម្បីពង្រីកដេប៉ូ និងធនាគារឈាមប្រតិបត្តិការនៅក្នុងអគារ CEmONC ទាំងអស់។[54]

3) បណ្តាញទំនាក់ទំនងជាមួយសេវាមិនមែនវិស័យសុខាភិបាល

ការកំណត់អត្តសញ្ញាណតម្រូវការ និងការបញ្ជូនទៅកាន់សេវាគាំទ្រមិនមែនសុខាភិបាល (ឧទាហរណ៍ សម្រាប់អ្នករស់រានមានជីវិតពី GBV) គឺមិនគ្រប់គ្រាន់ទេ ដោយសារភាពមានកម្រិតនៃការបណ្តុះបណ្តាល ការផ្តល់ព័ត៌មាន និងធនធាន ភាពអាចរកបាននូវសេវា ភាពស្មុគស្មាញ នៃការបញ្ជូន និងការរើសអើងដោយបុគ្គលិកសុខាភិបាល។ សេវាមិនមែនសុខាភិបាលដែលមានសារៈសំខាន់ចំពោះសុខភាព និងសុខុមាលភាព ដូចជាកិច្ចអន្តរាគមន៍កម្រិតសហគមន៍ និងសាលារៀន ដើម្បីផ្លាស់ប្តូរបទដ្ឋានសង្គមជុំវិញអំពើហិង្សា កម្រត្រូវបានដាក់បញ្ចូលជាមួយប្រព័ន្ធសុខភាព ដែលនេះបង្កើតឱ្យមានភាពគ្មានប្រសិទ្ធភាព និងការបាត់បង់ឱកាស។

**អន្តរាគមន៍ដែលបានស្នើឡើង៖**

1) ការដាក់បញ្ចូលសេវានៅកម្រិតមូលដ្ឋានសុខាភិបាល

- បង្កើតក្រុមការងារជាមួយនឹងកម្មវិធីជាតិទាក់ទងនឹង SRHR ដើម្បីពិភាក្សា រៀបចំផែនការ និងសមាហរណកម្មផែនការកម្មវិធីជាក់លាក់ ការអភិវឌ្ឍឯកសារបទដ្ឋាន រៀបចំហិរញ្ញវត្ថុ ខ្សែចង្វាក់ផ្គត់ផ្គង់ ការបណ្តុះបណ្តាល និងការត្រួតពិនិត្យកម្លាំងពលកម្ម
- កំណត់អាទិភាពសេវា SRHR ដែលនៅខ្វះខាតក្នុងកញ្ចប់សេវា PHC ឬឈ្វេងយល់ពីភាពស្មុគស្មាញ នៃមធ្យោបាយក្នុងការដាក់បញ្ចូល (ឧទាហរណ៍ ការភ្ជាប់សេវា CAC និងសេវាមេរោគអេដស៍ជាមួយសេវាផែនការគ្រួសារ) ជាមួយភាគីពាក់ព័ន្ធ
- អនុវត្តដំណោះស្រាយដើម្បីជៀសវាងអ្នកជំងឺឈប់ទទួលការថែទាំដោយសារតែការរើសអើងពីបុគ្គលិក ឬអ្នកជំងឺផ្សេងទៀត

54ក្រសួងសុខាភិបាល និង UNFPA (ឆ្នាំ ២០២០)។ ការពិនិត្យថែទាំសម្ភព និងទារកទើបនឹងកើត 2020

- ដាក់បញ្ចូលសេវាបង្ការ (ដូចជាគ្លីនិកដាក់លាក់សម្រាប់ក្រុម LGBTQI+ ការទប់ស្កាត់ការចម្លងសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ គ្លីនិកចល័ត ការផ្តល់ប្រឹក្សាអំពីកង្វល់របស់ SOGIE) ទៅក្នុងមូលដ្ឋានសុខាភិបាលដែលមានការចូលរួមពីអ្នកគ្រប់គ្រង ត្រួតពិនិត្យមើលដំណើរក្នុងការទទួលបានការថែទាំ និងគ្រប់គ្រងជំងឺរបស់អ្នកជំងឺ និងធ្វើការទំនាក់ទំនងព័ត៌មានទៅកាន់អ្នកជំងឺ
- គាំទ្រការអនុវត្តក្របខ័ណ្ឌ សម្រាប់ការអនុវត្តកម្មវិធី ជំរុញ PHC រួមទាំងការធ្វើ សមាហរណកម្មប្រព័ន្ធសុខភាពកម្រិតសហគមន៍។

2) ការបញ្ជូនទៅការថែទាំឯកទេស

- អនុវត្តយុទ្ធសាស្ត្រសុខភាពឌីជីថល រួមទាំងឧបករណ៍ ដែលជួយសម្រួលដល់ការសម្របសម្រួលនៃការបញ្ជូនអ្នកជំងឺ ដែលអាចធ្វើឱ្យមានការទំនាក់ទំនងរវាងសមាជិកក្រុមពហុវិន័យសម្រាប់ការថែទាំបឋម ក៏ដូចជាការណែនាំ និងជំនួយការងារសម្រាប់ការថែទាំឌីជីថល ដើម្បីគាំទ្របុគ្គលិកសុខាភិបាលអំឡុងពេលបញ្ជូនសង្គ្រោះបន្ទាន់
- ប្រើយន្តការបញ្ជូនបន្តទាក់ទងនឹង SRHR និងការអនុវត្តល្អបំផុតក្នុងតំបន់ និងសកល ដើម្បីកំណត់បញ្ហារាំងស្ទះ និងអនុវត្តដំណោះស្រាយ
- សាកល្បងម្តងហើយម្តងទៀត វាយតម្លៃ កែលម្អ និងត្រួតពិនិត្យការអនុវត្តយន្តការបញ្ជូនបន្តរួមទាំងការប្រាស្រ័យទាក់ទងគ្នារវាងមធ្យោបាយនានា
- បង្កើតទិន្នន័យអំពីទីតាំង ដែលបញ្ហាសុខភាពកើតឡើង កន្លែងដែលអ្នកជំងឺត្រូវបញ្ជូនទៅ និងកន្លែងដែលពួកគេត្រូវបានទទួលការព្យាបាល។

3) ការបញ្ជូនទៅកាន់សេវាសាធារណៈដែលមិនមែនជាសេវាសុខភាព

- ពង្រឹងចំណេះដឹងរបស់បុគ្គលិកសុខាភិបាលអំពីសេវា SRHR និងការបញ្ជូនទៅកាន់វិស័យមិនមែនសុខភាព ជាពិសេសក្នុងករណី GBV ដោយធានាពីភាពជាក់លាក់ ការផ្តោតលើអ្នកជំងឺ និងអាចសម្រេចបាន
- សហការជាមួយផ្នែកផ្សេងទៀត ក្នុងការផ្តល់លទ្ធភាពដល់អ្នកជំងឺដើម្បីទទួលបាននូវអន្តរាគមន៍មិនមែនជាសេវាសុខភាពដែលមានឥទ្ធិពលលើសុខភាព និងសុខុមាលភាព ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងនូវភាពស៊ីចង្វាក់គ្នា និងការច្របាច់បញ្ចូលគ្នាជាចាំបាច់។

## អាទិភាពជាយុទ្ធសាស្ត្រ ៤. ដោះស្រាយបទដ្ឋានសង្គម និងយេនឌ័រ គោលនយោបាយ និងការអនុវត្ត ដែលបង្កគ្រោះថ្នាក់ តាមរយៈការពង្រឹងអភិបាលកិច្ច និងការផ្តល់សេវា SRHR

### ប្រយោគបញ្ហា

បទដ្ឋានសង្គម និងយេនឌ័រដែលបង្កគ្រោះថ្នាក់ ភាពលំអៀង និងវិសមភាព ធ្វើឱ្យមានការផ្តល់អាទិភាពទាបចំពោះសិទ្ធិរបស់ស្ត្រី និងកុមារី រួមទាំងសិទ្ធិរបស់ពួកគេក្នុងការទទួលបានសេវា SRHR ។

## បញ្ហាប្រឈមសំខាន់ៗ

1) គោលនយោបាយ និងផែនការ

ការយល់ដឹងអំពីរបាំងសង្គម និងយេនឌ័រចំពោះការទទួលបាន SRHR និងភាពប្រសព្វគ្នានៃបញ្ហារបស់ក្រុមប្រជាជនដែលត្រូវបានមិនអើពើ ក្នុងចំណោមអ្នកធ្វើគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺនៅមានកម្រិត។ តួនាទីភាពជាអ្នកដឹកនាំក្នុងវិស័យសុខាភិបាល ដែលត្រួតពិនិត្យលើការកំណត់គោលនយោបាយ ការសម្រេចចិត្តផ្តល់ហិរញ្ញប្បទាន ការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យ គឺជាបុរសចំណែកឯតួនាទីជួរមុខវិញ គឺកាន់កាប់ ដោយស្ត្រី។ នេះជាឧបសគ្គដល់ការបញ្ជ្រាបយេនឌ័រនៅកម្រិត នៃការដឹកនាំជាន់ខ្ពស់។ ច្បាប់ និងគោលនយោបាយក្នុងវិស័យផ្សេងទៀត លើកទឹកចិត្តឱ្យមានបទដ្ឋានសង្គម និងយេនឌ័រមិនស្មើគ្នា ដូចជាគោលនយោបាយកន្លែងធ្វើការ ដែលរារាំងជនពិការក្នុងការទទួលបានការងារ ឬការរារាំងម្តាយពីការបំបៅកូនដោយទឹកដោះម្តាយឬការរារាំងការឈប់សម្រាកព្យាបាលដើម្បីទទួលសេវាថែទាំក្រោយសម្រាល។

2) ការផ្តល់សេវា

ក្នុងករណីខ្លះ ស្ត្រីទទួលរងនូវការរើសអើង ការទុកឱ្យនៅឯកា និងអំពើហិង្សាក្នុងវិស័យផ្សេងៗនៅក្នុងសង្គម រួមមានការផ្តល់សេវានៅតាមមូលដ្ឋាន ដែលមិនមែនសេវាសុខភាពដែលមានឥទ្ធិពលលើ SRHR ។ បុគ្គលិកសុខាភិបាល ខកខានឱកាសក្នុងការធ្វើជាគំរូទំនាក់ទំនងយេនឌ័រប្រកបដោយភាពវិជ្ជមានសម្រាប់អ្នកស្វែងរកការថែទាំសុខភាព និងក្រុមគ្រួសារដែលមកជាមួយ ដោយសារពួកគេ ជាញឹកញយ គឺជាចំណុចដំបូង នៃទំនាក់ទំនងជាមួយប្រព័ន្ធសុខាភិបាល។ ស្ត្រីមិនទទួលបានការគាំទ្រជាប់លាប់ក្នុងការអនុវត្តសិទ្ធិស្វ័យភាពរាងកាយ ក្នុងអំឡុងពេលទទួលសេវា SRHR នោះទេ។ បុរស និងក្មេងប្រុស មិនចូលរួមគាំទ្រសមភាពយេនឌ័រ និងស្វ័យភាពរាងកាយទាក់ទងនឹង SRHR នោះទេ។ បុរស និងក្មេងប្រុស ទំនងជាមិនស្វែងរកការថែទាំសុខភាពនៅពេលចាំបាច់ ដូចជាជំងឺកាមរោគ ដោយសារតែបទដ្ឋាន នៃភាពជាបុរសបានរារាំងបុរសពីការស្វែងរកការថែទាំ។ ភាពមានកម្រិត នៃការរក្សាឯកជនភាព នៃការថតសម្លេង និងប្រើប្រាស់រូបភាពនៅតាមមូលដ្ឋានផ្តល់សេវាសុខភាព ធ្វើឱ្យមានការភ័យខ្លាចពីការមាក់ងាយ និងការរើសអើង ដែលនេះរារាំងប្រជាជន ក្នុងការស្វែងរកសេវាសុខភាព។

3) បរិយាកាសសង្គម និងច្បាប់

ច្បាប់ការពារស្ត្រី និងកុមារីក្នុងវិស័យផ្សេងទៀត ដូចជាអាយុអប្បបរមា សម្រាប់រៀបការ មិនត្រូវបានអនុវត្តគ្រប់គ្រាន់ទេ។ បុរស និងក្មេងប្រុស មិនបានចូលរួមដើម្បីគាំទ្រសមភាពយេនឌ័រ រួមទាំងតាមរយៈទំនួលខុសត្រូវនៅក្នុងវិស័យកម្លាំងការងារប្រកបដោយសមធម៌យេនឌ័រ ការងារផ្ទះ និងវិស័យសាធារណៈ។ សមាជិកសហគមន៍ដែលមានឥទ្ធិពល បន្តបង្កើតបទដ្ឋានយេនឌ័រមិនស្មើគ្នា ដែលរារាំងដល់សុខភាព និងសុខុមាលភាពរបស់ស្ត្រី បុរស និងសហគមន៍របស់ពួកគេ ទោះបីជាមានការខិតខំប្រឹងប្រែងតាមរយៈការផ្តល់ព័ត៌មាន អប់រំ ផ្សព្វផ្សាយ និងទំនាក់ទំនង ឬនៅតាមសាលារៀនក៏ដោយ។

**អន្តរាគមន៍ដែលបានស្នើឡើង៖**

1) គោលនយោបាយ និងផែនការពហុវិស័យ

- ចូលរួមចំណែកក្នុងការវិភាគ និងកិច្ចសន្ទនាជាពហុវិស័យស្តីពីយេនឌ័រជាទៀងទាត់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកំណត់ឧបសគ្គទាក់ទងនឹងយេនឌ័រក្នុងការទទួលបាន SRHR និងបញ្ហាប្រសព្វផ្សេងទៀត និងប្រើការរកឃើញដើម្បីកែលម្អគោលនយោបាយ និងផែនការ
- បង្កើត និងអនុវត្តយុទ្ធសាស្រ្តតស៊ូមតិសម្រាប់ក្រុមការងារសុខភាពមាតា និងទារក ដើម្បីរួមចំណែកធ្វើឱ្យប្រសើរឡើងនូវច្បាប់ និងគោលនយោបាយពហុវិស័យដែលបន្តអនុវត្តបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ រួមទាំងការតស៊ូមតិឱ្យមានការបែងចែកធនធាន ការកំណត់ស្តង់ដារសម្រាប់ការសម្របសម្រួលការឆ្លើយតបនៅថ្នាក់មូលដ្ឋាន និងវិធីសាស្រ្តប្រកបដោយបរិយាបន្នសម្រាប់ការឆ្លើយតបដែលបានសម្របសម្រួលឡើង
- កសាងសមត្ថភាពនៃភាពជាអ្នកដឹកនាំទៅលើ SRHR នៅក្នុងកម្មវិធីដែលគិតគូរពី GBV តាមរយៈការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់អ្នកធ្វើការសម្រេចចិត្ត និងអ្នកគ្រប់គ្រងកម្មវិធី

2) គោលនយោបាយ និងផែនការវិស័យសុខាភិបាល

- ប្រមូល និងប្រើប្រាស់ទិន្នន័យបែងចែកតាមយេនឌ័រ អំពីបទពិសោធន៍អ្នកជំងឺ ជាពិសេសបទពិសោធន៍របស់ស្ត្រី និងអ្នកដែលរស់នៅជាមួយកត្តាផ្សេងទៀតនៃភាពងាយរងគ្រោះ ដូចជាពិការភាព ដើម្បីជូនដំណឹងដល់ការពង្រឹងអន្តរាគមន៍ SRHR នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- វិភាគ និងកំណត់យុទ្ធសាស្រ្តដើម្បីបង្កើនចំនួនស្ត្រីក្នុងមុខតំណែងអ្នកសម្រេចចិត្តក្នុងវិស័យសុខាភិបាល និងបង្កើតឥទ្ធិពល និងអំណាចរបស់ពួកគេ ដើម្បីសម្រេចបានសមភាពយេនឌ័រក្នុងការសម្រេចចិត្ត
- សហការគ្នាបង្កើត និងអនុវត្តអន្តរាគមន៍កម្លាំងពលកម្ម ដែលអាចឱ្យបុគ្គលិកសុខាភិបាលស្ត្រី រួមទាំងឆ្មប ទទួលបានឱកាសវិជ្ជាជីវៈតាមជម្រើសរបស់ពួកគេ ដោយមិនមានការរើសអើង គ្មានការទុកឱ្យនៅឯកា និងគ្មានអំពើហិង្សា
- ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងនៅ PHD-MCH និងOD-MCH ក្នុងការចូលរួមក្នុងការសម្របសម្រួល និងអភិបាលកិច្ចក្នុងតំបន់ជុំវិញ GBV
- ដោះស្រាយកត្តាបន្ទាប់បន្សំ ដែលបង្កឱ្យមានអំពើហិង្សាលើស្ត្រី (VAW) ដូចជាគ្រឿងស្រវឹង និងការប្រើប្រាស់គ្រឿងញៀន តាមរយៈការតស៊ូមតិ និងការចូលរួមក្នុងដំណើរការគោលនយោបាយ និងផែនការ។

3) ការផ្តល់សេវាផ្នែកសុខភាព

- បញ្ចូលមេរៀនអំពីសមភាពយេនឌ័រទៅក្នុងកម្មវិធីសិក្សាមុនបម្រើការងារ សម្រាប់គិលានុបដ្ឋាក ឆ្មប និងសាលាវេជ្ជសាស្រ្ត ដែលទទួលបានការទទួលស្គាល់ដើម្បីបណ្តុះបណ្តាលអ្នកផ្តល់សេវាអំពីការកំណត់អត្តសញ្ញាណ និងដោះស្រាយឧបសគ្គទាក់ទងនឹងយេនឌ័រក្នុងការថែទាំ គំរូ

អាកប្បកិរិយាប្រកបដោយសមភាពយេនឌ័រ និងការភ្ជាប់បុរស និងក្មេងប្រុសជាសម្ព័ន្ធមិត្តរបស់ស្ត្រីនៅក្នុងបរិបទ នៃការប្រឹក្សាអំពី SRHR

- ផ្តល់អាទិភាពដល់ការថែទាំដែលផ្តោតលើអ្នកជំងឺ នៅក្នុងការបណ្តុះបណ្តាលធ្មប ដើម្បីគាំទ្រធ្មបក្នុងការលើកកម្ពស់ស្វ័យភាពរាងកាយរបស់ស្ត្រី និងការផ្តល់ជំនួយបន្ថែមសម្រាប់ស្ត្រីដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះជាពិសេស
- ពង្រឹង និងពង្រីកសេវាដែលទាក់ទងនឹង GBV រួមទាំងការកំណត់អត្តសញ្ញាណ អ្នករស់រានមានជីវិតពី GBV និងអំពើហិង្សាពីដៃគូស្និតស្នាល (IPV) ការផ្តល់ការគាំទ្រដំបូង ការថែទាំរបួស និងការព្យាបាលបន្ទាន់ ការពិនិត្យ ថែទាំការរំលោភបំពានផ្លូវភេទ ការវាយតម្លៃ និងការថែទាំសុខភាពផ្លូវចិត្ត និងចងក្រងឯកសារ នៃករណី GBV សម្រាប់ហេតុផលវេជ្ជសាស្ត្រ និងផ្លូវច្បាប់។
- បណ្តុះបណ្តាលអ្នកផ្តល់សេវា អ្នកគ្រប់គ្រង និងអ្នកគ្រប់គ្រងមូលដ្ឋានផ្តល់សេវា ដើម្បីឱ្យពួកគេធ្វើឱ្យមានការចូលរួមពីសមាជិកគ្រួសារដែលជាបុរស ក្នុងការគាំទ្រដល់ស្វ័យភាពរបស់ស្ត្រីទាក់ទងនឹងការសម្រេចចិត្តពាក់ព័ន្ធនឹង SRHR និងការអនុវត្តអាកប្បកិរិយាប្រកបដោយសមភាពយេនឌ័រ
- បណ្តុះបណ្តាល និងគាំទ្រអ្នកផ្តល់សេវាសុខភាពជាបុរស អ្នកគ្រប់គ្រង HC អ្នកគ្រប់គ្រង OD, PHD និងMCH និងបុគ្គលិក ក្រុមការងារសុខភាពមាតា និងទារក ថ្នាក់ជាតិ ដើម្បីក្លាយជាម្ចាស់ជើងឯក និងជាសម្ព័ន្ធមិត្តក្នុងការលើកកម្ពស់ និងការពារសិទ្ធិស្ត្រីដែលជាអ្នកជំងឺ និងជាបុគ្គលិកវិស័យកម្លាំងការងារ ក្នុងការកំណត់គោលនយោបាយ ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ ការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យ
- ត្រូវធានាថាបុរស និងក្មេងប្រុសអាចទទួលបានការថែទាំសុខភាពបឋម រួមមានទាំងការប្រឹក្សាប្រកបដោយការគាំទ្រ និងបរិយាបន្ន ដើម្បីលើកទឹកចិត្តដល់ការស្វែងរកការថែទាំសុខភាពសម្រាប់សេវា SRHR ដូចជាជំងឺកាមរោគ ឬភាពគ្មានកូន
- ពង្រឹងជំនាញទំនាក់ទំនងរបស់អ្នកផ្តល់សេវាសុខភាព ដើម្បីឱ្យការផ្តល់សេវាផ្តោតលើអតិថិជន។

4) បរិយាកាសសង្គម និងច្បាប់

- ឱ្យមានការចូលរួមពីអ្នកដែលមានឥទ្ធិពលនៅក្នុងសហគមន៍ អ្នកដែលមានឥទ្ធិពលលើបទដ្ឋានសង្គមដើម្បីចែករំលែកព័ត៌មានអំពី SRHR តាមរយៈកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព (HCMC) កិច្ចប្រជុំឃុំ...
- ចូលរួមជាមួយថ្នាក់ដឹកនាំឃុំទទួលបន្ទុកអភិវឌ្ឍន៍ និងអនុវត្តថវិកាសុខភាពតាមរយៈផែនការវិនិយោគឃុំ (CIPs) ដើម្បីធានាថា ថវិកាត្រូវបានបែងចែកសម្រាប់កិច្ចអន្តរាគមន៍លើកកម្ពស់សមភាពយេនឌ័រ និងសង្គម

- តស៊ូមតិឱ្យមានការផ្លាស់ប្តូរផ្លូវច្បាប់ក្នុងវិស័យការងារ ការអប់រំ និងវិស័យផ្សេងទៀតដែលមានឥទ្ធិពលវិជ្ជមានលើលទ្ធផលសុខភាពរបស់ស្ត្រី និងសមភាពយេនឌ័របន្ថែមទៀត ឧទាហរណ៍ ការបៀតបៀន ការឈប់សម្រាកលំហែមាតុភាព ការឈប់សម្រាកឈឺ...
- ស៊ើបអង្កេត និងតស៊ូមតិឱ្យមានការការពារបន្ថែមទៀតពីអំពើហិង្សាទាក់ទងនឹង SRHR សម្រាប់ស្ត្រីនៅក្នុងកន្លែង ដែលពួកគេងាយនឹងរងគ្រោះ ដូចជាពន្ធនាគារ អ្នកបម្រើផ្លូវភេទ និងសេវាកម្សាន្ត ជាដើម...
- ពង្រឹងកម្មវិធីសិក្សាអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ (CSE) ការបណ្តុះបណ្តាល និងការចែកចាយសម្រាប់យុវជនទាំងក្នុង និងក្រៅសាលា ធានាការធ្វើចេញនូវសារបែបផ្លាស់ប្តូរយេនឌ័រជុំវិញការចូលរួមរបស់បុរស និងក្មេងប្រុស ឱ្យពួកគេក្លាយជាសម្ព័ន្ធមិត្ត ដើម្បីសម្រេចបានសមភាពយេនឌ័រ
- អនុវត្តកិច្ចអន្តរាគមន៍ផ្នែកសុខភាព ដែលបានរៀបរាប់នៅក្នុងការឆ្លើយតបជាពហុវិស័យនៅថ្នាក់ជាតិ និងមូលដ្ឋាន ចំពោះ GBV រួមទាំងផ្នែកយុត្តិធម៌ ប៉ូលីស និងសេវាសង្គម
- សម្របសម្រួលការចែករំលែកទិន្នន័យដោយអាជ្ញាធរមូលដ្ឋានថ្នាក់ឃុំ អំពីអំពើហិង្សាលើកុមារ ។

## អាទិភាពជាយុទ្ធសាស្ត្រ៥. ផ្តល់អាទិភាពដល់ភាពជាម្ចាស់របស់សហគមន៍ ការចូលរួមជាមួយប្រព័ន្ធសុខាភិបាល និងការឆ្លើយតបដើម្បីពង្រឹងការផ្គត់ផ្គង់ និងតម្រូវការសេវា SRHR

**ប្រយោគបញ្ហា ៖**

សហគមន៍មិនទទួលបានសិទ្ធិអំណាច និងហិរញ្ញប្បទានគ្រប់គ្រាន់ក្នុងការដឹកនាំការកំណត់អាទិភាព និងបង្កើតដំណោះស្រាយ ការចូលរួមក្នុងការផ្សព្វផ្សាយ ឬដោះស្រាយបញ្ហាប្រឈមសុខភាពរបស់ពួកគេផ្ទាល់ តាមរយៈការថែទាំខ្លួនឯង និងការគាំទ្រពីមិត្តភក្តិ។

**បញ្ហាប្រឈមសំខាន់ៗ**

1) ការកំណត់អាទិភាព និងបង្កើតដំណោះស្រាយ

សហគមន៍ដែលងាយរងគ្រោះ តម្រូវការ និងឧបសគ្គក្នុងការចូលទៅកាន់ SRHR របស់ពួកគេ មិនត្រូវបានយល់ច្បាស់ដោយអ្នកបង្កើតគោលនយោបាយនោះទេ។ សមាជិកសហគមន៍ និងដៃគូ មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចែករំលែកអំពីតម្រូវការ និងស្នើដំណោះស្រាយចំពោះបញ្ហាប្រឈមនានាក្នុងការចូលទៅកាន់ SRHR ជាមួយអ្នកធ្វើការសម្រេចចិត្តបាននោះទេ។ សហគមន៍ មិនទទួលបានព័ត៌មានគ្រប់គ្រាន់អំពីការរាយការណ៍ និងការចូលរួមនៅក្នុងមតិកែលម្អ ការត្រួតពិនិត្យ ការវាយតម្លៃ និងដំណើរការសិក្សាដូចជា MPDSR ដោយផ្ទាល់ និងការធ្វើកោសល្យវិច័យសង្គមនោះទេ។

2) ការផ្សព្វផ្សាយ

ភាពជាអ្នកដឹកនាំ និងយន្តការសហគមន៍ដែលមានស្រាប់ មិនត្រូវបានប្រើប្រាស់ឱ្យបានពេញលេញក្នុងការផ្សព្វផ្សាយព័ត៌មាន និងផលិតផលមូលដ្ឋានរបស់ SRHR ជាមួយអ្នកដែលកំពុងស្វែងរកវា ដូចជាការពង្រីក

បណ្តាញ EmONC ជាដើម[55] ។ មូលដ្ឋានសុខាភិបាល មិនបានប្រើយន្តការសហគមន៍ដែលមានស្រាប់ឱ្យបានពេញលេញដើម្បីគ្របដណ្តប់ទៅដល់ស្ត្រី និងកុមារីនៅគ្រប់ទីកន្លែងដែលមានសេវា SRHR នោះទេ។ ក្រុមទ្រទ្រង់សុខភាពភូមិ (VHSG) មិនបានផ្តល់ព័ត៌មាន និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនឱ្យបានគ្រប់គ្រាន់ ដោយសារកង្វះការលើកទឹកចិត្ត ការគាំទ្រ ការកសាងសមត្ថភាព និងឧបករណ៍ ការគ្រប់គ្រងគ្រប់គ្រាន់ និងការត្រួតពិនិត្យ ឬការភ្ជាប់ទំនាក់ទំនងទៅនឹងអាជ្ញាធរមូលដ្ឋាន សាលារៀន ថ្នាក់ដឹកនាំឃុំ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

3) តម្រូវការពិសេសរបស់សហគមន៍

ប្រជាជនដែលរស់នៅក្នុងបរិបទដែលពិបាកទៅដល់មួយចំនួន ដូចជាទីតាំងដាច់ស្រយាល ពន្ធនាគារ ឬតំបន់អនាធិបតេយ្យក្នុងទីក្រុង មានលទ្ធភាពតិចតួចក្នុងការទទួលបានព័ត៌មាន និងសេវា SRHR។[56] ក្មេងជំទង់ និងយុវជន ទាំងក្នុង និងក្រៅសាលា មានឧបសគ្គជាក់លាក់ក្នុងការទទួលបានព័ត៌មាន និងសេវារបស់ SRHR ។

4) ការពង្រឹងអំណាច និងការថែទាំខ្លួនឯង

សមាជិកសហគមន៍មិនទទួលបានព័ត៌មាន ការគាំទ្រ និងការថែទាំដែលផ្តោតលើអ្នកជំងឺដែលពួកគេត្រូវការដើម្បីអនុវត្តអាកប្បកិរិយាបង្ការនោះទេ។ សហគមន៍មិនត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីដោះស្រាយបញ្ហាប្រឈមសុខភាពរបស់ពួកគេផ្ទាល់ តាមរយៈវិធីសាស្ត្រថែទាំខ្លួនឯង និងការអប់រំពីមិត្តភក្តិនោះទេ។

**អន្តរាគមន៍ដែលបានស្នើឡើង៖**

1) ការកំណត់អាទិភាព និងបង្កើតដំណោះស្រាយ

- កំណត់សហគមន៍ដែលខ្វះខាត តម្រូវការ SRHR របស់ពួកគេ ឧបសគ្គក្នុងការចូលប្រើប្រាស់ និងយន្តការដើម្បីចូលរួមផ្សព្វផ្សាយដល់កម្មកររោងចក្រ អ្នកបម្រើផ្លូវភេទ សេវាកម្សាន្ត ជនជាតិភាគតិច ជនចំណាកស្រុក ជនពិការ សិស្សានុសិស្ស យុវជនក្រៅសាលា LGBTQI និងអ្នកធ្វើការជាមួយអ្នកមានឥទ្ធិពលរួមមានអ្នកដឹកនាំបែបប្រពៃណី
- កសាង និងគាំទ្រជំនាញរបស់អ្នកដឹកនាំសហគមន៍សម្រាប់ការតស៊ូមតិកម្រិតខ្ពស់ ការកៀរគរធនធាន ការរៀបចំថវិកា ការធ្វើផែនការ និងការធ្វើឱ្យអ្នកដឹកនាំ SRHR ទទួលខុសត្រូវតាមរយៈ MPDSR និងការធ្វើកោសល្យវិច័យសង្គម។

2) ការចូលរួមក្នុងការផ្សព្វផ្សាយ

- ដាក់បញ្ចូលការផ្សព្វផ្សាយអំពី SRHR ជាមួយនឹងសកម្មភាពផ្សេងទៀតដែលធ្វើឡើងដោយ ក្រុមទ្រទ្រង់សុខភាពភូមិ (VSHG) អ្នកស្ម័គ្រចិត្តសុខភាពសហគមន៍ផ្សេងទៀត អ្នកអប់រំមិត្ត វេទិកាសហគមន៍ដែលមិនទាក់ទងនឹងសុខភាពដែលមានស្រាប់ដូចជា គណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ ការជួបជុំរបស់អង្គការសហគមន៍ដែលពាក់ព័ន្ធ...

[55] ក្រសួងសុខាភិបាលកម្ពុជា។ (២០២២)។ ធ្វើបច្ចុប្បន្នភាព និងពង្រីកយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិនៅកម្ពុជា (២០១៧-២០២៣)។
[56] អង្គការសុខភាពពិភពលោក។ (២០២៣)។ ក្របខណ្ឌតំបន់សម្រាប់ការឈានទៅដល់ការមិនទាន់សម្រេចនៅប៉ាស៊ីហ្វិកខាងលិច (2022-2030)។

- បង្កើតវគ្គបណ្តុះបណ្តាល ព្រមទាំងពង្រឹងជំនាញទំនាក់ទំនងដល់បុគ្គលិកសុខាភិបាល ក្រុមទ្រទ្រង់សុខភាពភូមិ ស្តីពីភាពគ្មានកូនរួមទាំងការយល់ដឹង ជាមូលដ្ឋានអំពីលក្ខខណ្ឌដែលអាចប៉ះពាល់ដល់ការមានកូន ដូចជាជំងឺកាមរោគចំពោះស្ត្រី និងបុរស ឬជំងឺស្រទាប់ក្នុងរបស់ស្បូនដុះក្រៅស្បូន (endometriosis) និងការកំណត់ករណីដែលអាចកើតមាន លើកទឹកចិត្តបុគ្គលឱ្យស្វែងរកជំបូន្មាន និងផ្តល់ការប្រឹក្សាជាមូលដ្ឋាន
- ពង្រឹងការចូលរួមរបស់សហគមន៍នៅក្នុងវិសាលភាពការងាររបស់ឆ្មប បណ្តុះបណ្តាលឆ្មប និងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ពួកគេ ដើម្បីជំរុញឱ្យមានការបញ្ជ្រាបសហគមន៍អំពីតម្រូវការ និងសេវា SRHR គ្រប់ជ្រុងជ្រោយ រួមទាំងការដោះស្រាយបញ្ហាជាក់លាក់ដែលអាចធ្វើឱ្យការស្វែងរកការថែទាំជួបការលំបាក
- សមាហរណកម្ម នៃការចូលរួមរបស់សហគមន៍ទាក់ទងនឹង SRHR ទៅក្នុងកម្មវិធីរង្វាន់ជាលក្ខណៈហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដែលមានស្រាប់ ផ្តល់ធនធានគ្រប់គ្រាន់ និងនិរន្តរភាពសម្រាប់មណ្ឌលសុខភាព និងឃុំដែលកំណត់គោលដៅសម្រាប់សកម្មភាពទប់ស្កាត់ និងលើកកម្ពស់ SRHR
- វិភាគថាវេទិកាប្រព័ន្ធផ្សព្វផ្សាយណាដែលសមស្របបំផុត ដើម្បីគ្របដណ្តប់ដល់ប្រជាជនសម្រាប់ចែកចាយព័ត៌មាន SRHR ចែករំលែកការអនុវត្តល្អបំផុតសម្រាប់ក្រុមងាយរងគ្រោះទៅតាមក្រុមនីមួយៗ ប្រាក់ចំណូលទាប យុវជន ចំណាកស្រុក កម្មកររោងចក្រ ជនពិការ LGBTQI+ ... និងអនុវត្តវិធីសាស្ត្រដែលបានកំណត់ឡើង ដើម្បីចែករំលែកព័ត៌មាន និងសារទប់ស្កាត់ទ្រង់ទ្រាយធំ
- ផ្សព្វផ្សាយអំពីព័ត៌មាន និងភាពអាចរកបាន នៃសេវា SRHR ទៅដល់គ្រប់កម្រិតសាលារៀន កែច្នៃការផ្សព្វផ្សាយឱ្យសមស្រប និងអាចទទួលយកបានទៅតាមក្រុមអាយុ និងលក្ខណៈពិសេសរបស់សិស្ស ដោយប្រើប្រាស់វិធីសាស្ត្រផ្អែកលើភស្តុតាងដើម្បីធ្វើឱ្យមានភាពប្រសើរឡើងនូវចំណេះដឹង ឥរិយាបថ និងអាកប្បកិរិយារបស់យុវជន ដូចជាមិត្តអប់រំមិត្តជាដើម
- វិធីសាស្ត្រពង្រីកបណ្តាញ EmONC ដើម្បីដាក់បញ្ចូលសុខភាពសហគមន៍ និងការចូលរួមរបស់ក្រុមគ្រួសារក្នុងការសម្រេចចិត្តស្វែងរកការថែទាំ និងបង្កើនភាពពាក់ព័ន្ធជាមួយបុគ្គលិកសុខាភិបាលតាមសហគមន៍នៅពេលចាំបាច់។

3) ភាពអាចរកបាននៃសេវា

- ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាន SRHR ដោយជនចំណាកស្រុកតាមរយៈការស្រាវជ្រាវអំពីតម្រូវការ និងឱកាសចូលប្រើប្រាស់ ធានាថាភាពខុសគ្នា នៃភាសា និងវប្បធម៌ត្រូវបានយកមកពិចារណា និងបែងចែកកម្លាំងពលកម្មទៅកាន់តំបន់ដែលមានប្រជាជនចំណាកស្រុកខ្ពស់ ធ្វើការផ្សព្វផ្សាយតាមគោលដៅ តាមដានភាពជោគជ័យ បញ្ហាប្រឈម និងការចែករំលែកការអនុវត្តល្អបំផុត

- ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាន SRHR សម្រាប់កម្មកររោងចក្រកាត់ដេរ ដោយសហការជាមួយរោងចក្រ ដើម្បីធានាបានថាសេវា SRHR មាននៅគិលានដ្ឋានរោងចក្រ តស៊ូមតិឱ្យមានអនុវត្តច្បាប់ការងារ ដូចជាការឈប់សម្រាកសម្រាប់ការណាត់ជួបព្យាបាល ត្រួតពិនិត្យគាំទ្រគ្លីនិកឯកជន និងឱសថស្ថានដែលមានទីតាំងនៅជិតរោងចក្រផ្តល់សម្ភារអប់រំផ្សព្វផ្សាយព័ត៌មាន ដល់កម្មកររោងចក្រ និងឱ្យពួកគេចូលរួមក្នុងដំណើរការកំណត់អាទិភាព និងផែនការ
- ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពប្រើប្រាស់ SRHR សម្រាប់សហគមន៍ជនជាតិដើមភាគតិច ដោយធានាថា ការជួលឬចាត់តាំងអ្នកផ្តល់សេវាសម្រាប់សហគមន៍ គឺមានជំនាញភាសាអមជាមួយជ្រើសរើសសិស្សឆ្មបពីសហគមន៍ជនជាតិដើមភាគតិច ដែលពួកគេអាចធ្វើការនៅក្នុងសហគមន៍របស់ពួកគេបន្ទាប់ពីបញ្ចប់ការសិក្សាគាំទ្រអ្នកគ្រប់គ្រងមូលដ្ឋានផ្តល់សេវា ឱ្យសហការជាមួយអ្នកដឹកនាំ សហគមន៍ជនជាតិដើមភាគតិចដើម្បីយល់កាន់តែច្បាស់អំពីតម្រូវការ និងចំណូលចិត្តជាក់លាក់របស់ពួកគេ និងបែងចែកថវិកាឱ្យស្របទៅនឹងសេចក្តីត្រូវការនៅក្នុងតំបន់ដែលមានចំនួនប្រជាជនជនជាតិដើមភាគតិចច្រើន ដូចជាការកែតម្រូវម៉ោងបើកទទួលផ្តល់សេវា ការបោះពុម្ពសម្ភារបកប្រែរួច...
- ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាន SRHR ដោយសហគមន៍ LGBTQI+ តាមរយៈការស្រាវជ្រាវអំពីតម្រូវការពិសេស និងឱកាសទទួលបាន រួមទាំងការទប់ស្កាត់ការរើសអើង និងSOGIE ក្នុងកម្មវិធីបណ្តុះបណ្តាល ការដាក់ទោសចំពោះការរើសអើងប្រឆាំងនឹងបុគ្គល LGBTQI+ ធ្វើការផ្សព្វផ្សាយព័ត៌មានអប់រំដល់អ្នកដែលមិនទាន់ទទួលបាន តាមដានភាពជោគជ័យ និងបញ្ហាប្រឈម និងការចែករំលែកអំពីការអនុវត្តល្អបំផុត។

4) ការពង្រឹងអំណាច និងការថែទាំខ្លួនឯង

- ដោយសហការជាមួយកម្មវិធីសុខភាពផ្សេងទៀត ដាក់បញ្ចូលព័ត៌មានអំពី SRHR រួមមានព័ត៌មានអំពីការមានផ្ទៃពោះដោយចៃដន្យ ការរំលូតកូនដោយគ្មានសុវត្ថិភាព ស្ថានភាពផ្លូវច្បាប់ភាពអាចរកបាន និងការចំណាយលើការថែទាំគ្រប់ជ្រុងជ្រោយនៃការរំលូតកូន ទៅក្នុងកិច្ចចូលរួមបន្តបន្ទាប់ជាមួយសហគមន៍អំពីអាកប្បកិរិយាបង្ការ និងសេវាថែទាំសុខភាពបឋម
- កសាងសមត្ថភាពបណ្តាញសហគមន៍លើឧបករណ៍ឌីជីថល និងពង្រឹងវេទិកាឌីជីថលថ្មី ឬចាស់ដែលមានស្រាប់សម្រាប់ការចែករំលែកព័ត៌មាន
- កសាងសមត្ថភាពរបស់អ្នកដឹកនាំសហគមន៍ក្នុងការរៀបចំថវិកា ការធ្វើផែនការ ការផ្សព្វផ្សាយ និងការសហការជាមួយអ្នកស្ម័គ្រចិត្តសហគមន៍ ដើម្បីកែលម្អលទ្ធផល SRHR
- លើកទឹកចិត្តឃុំសង្កាត់ឱ្យវិនិយោគលើដំណោះស្រាយទៅតាមតម្រូវការ SRHR តាមរយៈផែនការវិនិយោគឃុំរបស់ពួកគេសម្រាប់គាំពារសុខភាពមាតា ទារក និងកុមារ និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសមត្ថភាពរៀបចំថវិកា និងផែនការនៅថ្នាក់ឃុំ
- កំណត់ និងអនុវត្តអន្តរាគមន៍តាមរយៈវិធីសាស្ត្រ ដែលបានបង្កើតឡើងដោយសហគមន៍ដើម្បីកាត់បន្ថយការមាក់ងាយចំពោះស្ថានភាពសុខភាពមួយចំនួន ដូចជា ការរំលូតកូន

- ○ បង្កើនការអនុវត្តល្អបំផុតដែលបានបង្ហាញនៅក្នុងប្រទេសកម្ពុជា ដូចជាក្រុមជួយខ្លួនឯង និងមិត្តអប់រំមិត្ត ដែលបានធ្វើឡើងដោយជោគជ័យក្នុងវិស័យជំងឺអេដស៍នៅកម្ពុជា។

## អាទិភាពជាយុទ្ធសាស្រ្ត ៦. ដកចេញនូវឧបសគ្គផ្នែកហិរញ្ញវត្ថុ ក្នុងការចូលប្រើសេវាថែទាំសុខភាពឆ្ពោះទៅរកការសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល (UHC)

### ប្រយោគបញ្ហា

បញ្ហាប្រឈមផ្នែកហិរញ្ញប្បទានសុខភាពជុំវិញប្រភពចំណូល ជានាវ៉ាប់រងសុខភាពសង្គម និងការទិញផលិតផល SRHR ដែលមានគុណភាពខ្ពស់ពិបាកក្នុងការរកបាន ហើយតម្លៃគឺមិនអាចផ្គត់ផ្គង់បាន។ នេះជាយុទ្ធសាស្រ្ត នៃសេវាប្រកបដោយប្រសិទ្ធភាព។

### បញ្ហាប្រឈមសំខាន់ៗ

1) ប្រភពហិរញ្ញវត្ថុ និងចំណូល

ការគូសផែនទីធនធានដំបូង សម្រាប់ករណីវិនិយោគដែលដឹកនាំដោយរដ្ឋាភិបាលសម្រាប់សុខភាពបន្តពូជ មាតា ទារក និងមនុស្សវ័យជំទង់ និងអាហារូបត្ថម្ភ (RMNCAH-N) ក្នុងភាពជាដៃគូជាមួយស្ថាប័នហិរញ្ញវត្ថុសកល (GFF) បានរកឃើញនូវគម្លាតមូលនិធិសម្រាប់សុខភាពមនុស្សវ័យជំទង់ និងអាទិភាព SRHR។ ការផ្តល់មូលនិធិមិនគ្រប់គ្រាន់សម្រាប់សេវា PHC ជះឥទ្ធិពលអវិជ្ជមានដល់សេវាពិនិត្យ សមាហរណកម្ម នៃការព្យាបាល និងការបន្តការព្យាបាល ប្រសិទ្ធភាពនៃប្រព័ន្ធបញ្ជូនបន្ត និងគុណភាពនៃការថែទាំ។ កិច្ចខិតខំប្រឹងប្រែងកៀរគរធនធាន គឺនៅមានកម្រិត ដោយសារកង្វះទិន្នន័យដែលបង្ហាញពីការសន្សំថ្លៃដើម និងឱកាសកំណើនសេដ្ឋកិច្ចដែលផ្សារភ្ជាប់ជាមួយការផ្តល់ផលិតផល និងសេវា SRHR។ មានការខ្វះខាតទិន្នន័យស្តីពីការគូសផែនទីធនធាន និងការតាមដានការចំណាយ ដើម្បីធានាបាននូវការផ្តល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពសម្រាប់ទំនិញ និងសេវា SRHR ដែលមានគុណភាពខ្ពស់ រួមទាំងរបៀបដែលសេវា SRHR នីមួយៗត្រូវបានផ្តល់មូលនិធិនាពេលបច្ចុប្បន្នបែងចែកទៅតាមប្រភព ចេញពីរដ្ឋាភិបាល ម្ចាស់ជំនួយ...។

2) ហានិភ័យ និងធានារ៉ាប់រងសុខភាពសង្គម៖

បញ្ហាញឹកញាប់បំផុតក្នុងការទទួលបានការថែទាំសុខភាព ដែលបានលើកឡើងនៅក្នុងការស្ទង់មតិទូទាំងប្រទេស គឺការបង់ប្រាក់សម្រាប់ការណែនាំ ឬការព្យាបាល។ ៦០% នៃការចំណាយលើសុខភាព គឺចេញពីការចំណាយរបស់អ្នកជំងឺ ដែលធ្វើឱ្យប្រជាជនកម្ពុជាប្រឈមនឹងហានិភ័យ នៃការចំណាយលើមហន្តរាយសុខភាព។ មូលនិធិសមធម៌សុខភាព មិនគ្របដណ្តប់លើផលិតផល និងសេវា SRHR សំខាន់ៗមួយចំនួនទេ៖ ដូចជាការពន្យារកំណើតក្រោយការរំលូតកូន ការពន្យារកំណើតក្រោយសម្រាល និងការថែទាំពេលមានផ្ទៃពោះ (ANC ៨) ។ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) មិនគ្របដណ្តប់លើសេវា SRHR សំខាន់ៗមួយចំនួនដូចជា៖ ការពន្យារកំណើតក្រោយការរំលូតកូន ការពន្យារកំណើតក្រោយសម្រាល ការថែទាំពេលមានផ្ទៃពោះ (ANC ៨) ការពិនិត្យមហារីកមាត់ស្បូន ការព្យាបាលដោយប្រើ cryotherapy។ ឯកសារបទដ្ឋានអំពីកញ្ចប់សេវាដែលគ្រប

ដណ្តប់ក្រោមគម្រោងធានារ៉ាប់រងសុខភាពដែលបានឧបត្ថម្ភ គឺមិនស៊ីចង្វាក់គ្នាទេ៖ ឧទាហរណ៍ មានភាពមិនស៊ីចង្វាក់គ្នារវាងគោលការណ៍ណែនាំរបស់ MoH ឆ្នាំ២០១៨ ស្តីពីកញ្ចប់អត្ថប្រយោជន៍ HEF ដែលសំដៅលើការថែទាំក្រោយការរំលូតកូន (PAC) តែប៉ុណ្ណោះ និងប្រកាសអន្តរក្រសួង ខែឧសភា ឆ្នាំ២០១៨ ស្តីពីកញ្ចប់អត្ថប្រយោជន៍របស់ HEF ដែលរួមបញ្ចូលការថែទាំរំលូតកូនដោយសុវត្ថិភាព (MA MVA និងPAC) នៅក្រោម HEF ដែលនាំឱ្យមានការភាន់ច្រឡំក្នុងចំណោមអ្នកជំងឺ និងអ្នកជំនាញថែទាំសុខភាព។ អ្នកជំងឺបង់ថ្លៃសេវាដែលមានតម្លៃថ្លៃដោយប្រាក់ផ្ទាល់ខ្លួន ដែលនេះនាំឱ្យកើតមានការចំណាយលើមហន្តរាយសុខភាព។ កញ្ចប់ HEF កំពុងត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពដែលសង្ឃឹមថាសេវា SRHR កាន់តែច្រើននឹងត្រូវបានដាក់បញ្ចូល។

អ្នកជំងឺដែលបានចុះឈ្មោះក្នុងគម្រោងធានារ៉ាប់រងសុខភាព ចំណេះដឹងនៅមានកម្រិតអំពីរបៀបទទួលបានអត្ថប្រយោជន៍របស់ពួកគេ និងអំពីសេវា SRHR ត្រូវបានរ៉ាប់រង។ អ្នកជំងឺដែលមិនបានចុះឈ្មោះក្នុងគម្រោងធានារ៉ាប់រងសុខភាព ចំណេះដឹងនៅមានកម្រិតអំពីជំនួយផ្នែកហិរញ្ញវត្ថុដែលមានសម្រាប់ពួកគេ និងរបៀបចុះឈ្មោះ និងរបៀបចូលទៅប្រើ។មិនមានយន្តការគាំទ្រផ្នែកហិរញ្ញវត្ថុជាក់លាក់ណាមួយសម្រាប់យុវជននោះទេ ជាធម្មតាយុវជនមានលទ្ធភាពនៅមានកម្រិត ក្នុងការទទួលបានធនធានហិរញ្ញវត្ថុសម្រាប់ចូលប្រើសេវាថែទាំសុខភាព។ គម្រោងធានារ៉ាប់រងសុខភាពសាធារណជាតិ មិនគ្របដណ្តប់លើសេវាដែលស្វែងរកពីកន្លែងឯកជន ដែលនេះធ្វើឱ្យលទ្ធភាពក្នុងការទទួលបានការថែទាំសុខភាពរបស់អ្នកជំងឺមានកម្រិត ។

3) យុទ្ធសាស្ត្រទិញ

គំរូនៃយុទ្ធសាស្ត្រទិញ សម្រាប់ការទូទាត់ដល់អ្នកផ្តល់សេវា SRHR គួរតែត្រូវបានពិភាក្សាជាមួយអ្នកពាក់ព័ន្ធផ្នែកហិរញ្ញប្បទានសុខភាព។ ខណៈពេលដែលក្របខណ្ឌការអនុវត្តកម្មវិធីជំរុញ PHC បានបង្កើតផែនទីបង្ហាញផ្លូវមួយដើម្បីបង្កើនភាពអាចរកបាន និងតម្លៃសមរម្យ នៃសេវា SRHR ក្របខណ្ឌនេះមិនទាន់ត្រូវបានអនុវត្តនៅកម្រិតមូលដ្ឋាននៅឡើយ។ ការរាយការណ៍តាមរយៈការពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធថានៅពេលដែលមូលដ្ឋានផ្តល់សេវាអនុវត្តការសម្រាលកូន ឬការរំលូតកូន ពួកគេទទួលបានមូលនិធិគ្រប់គ្រាន់ដើម្បីរ៉ាប់រងថ្លៃដើមបន្ថែមលើការផ្តល់សេវារៀបចំផែនការគ្រួសារភ្លាមៗ ក្នុងអំឡុងពេលជួបជាមួយអតិថិជនក្នុងពេលជាមួយគ្នានោះ។ ទោះជាយ៉ាងនេះក្តីសេវាទាំងនេះមិនត្រូវបានគ្របដណ្តប់ជាផ្លូវការ ក្រោមគម្រោងធានារ៉ាប់រងសុខភាពសាធារណៈទេ ដែលនេះរារាំងដល់ការផ្តល់សេវា ប្រសិនបើសេវាពង្រីកដល់វិស័យឯកជន។[57] ការផ្តល់មូលនិធិសម្រាប់ការពង្រឹងប្រព័ន្ធ ធនធានមនុស្ស ការទិញថ្នាំ... គឺមិនគ្រប់គ្រាន់នោះទេសម្រាប់សុខភាព SRHR មួយចំនួន រួមមានការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលលើ CAC និងការទិញឧបករណ៍រំលូតកូន។[58] អ្នកជំងឺដែល

[57] ក្រសួងសុខាភិបាលកម្ពុជា។ (២០២២)។ ធ្វើបច្ចុប្បន្នភាព និងពង្រីកយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិនៅកម្ពុជា (២០១៧-២០២៣)។

[58] ក្រសួងសុខាភិបាលកម្ពុជា។ (២០២១)។ ផែនទីបង្ហាញផ្លូវគំនិតផ្តួចផ្តើមរហ័សសម្រាប់ការកាត់បន្ថយមរណភាពមាតា និងទារក 2023-2030។

ឆ្លងកាត់មណ្ឌលសុខភាព ត្រូវចំណាយខ្ពស់នៅពេលស្វែងរកការថែទាំពីកម្រិត នៃការថែទាំឯកទេសបន្ថែមទៀត។

**អនុព្វាគមន៍ដែលបានស្នើឡើង៖**

1) ប្រភពហិរញ្ញវត្ថុ និងចំណូល

- ប្រមូលធនធានរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយ ដើម្បីដោះស្រាយគម្លាតថវិកាសម្រាប់ SRHR រួមទាំង SRHR សម្រាប់មនុស្សវ័យជំទង់ ការបណ្តុះបណ្តាល SRHR មុន និងក្នុងពេលបម្រើការងារ សេវា EmONC CAC និងផ្នែកសុខភាពផ្សេងទៀត
- រៀបចំឱ្យមានការត្រួតពិនិត្យជាប្រចាំលើការគូសផែនទីធនធាន និងការតាមដានការចំណាយ ដើម្បីកំណត់ពីរបៀបដែលសេវា SRHR ត្រូវបានបង់ថ្លៃ ដោយបែងចែកតាមប្រភពចេញពីរដ្ឋាភិបាល ម្ចាស់ជំនួយ ផ្សេងទៀត ដើម្បីឱ្យមានដំណើរការត្រឹមត្រូវ នៃការបែងចែកថវិកា និងការអនុវត្ត
- រៀបចំប្រព័ន្ធបង្រួបបង្រួមទិន្នន័យហិរញ្ញវត្ថុជាមួយនឹងព័ត៌មាន និងធាតុចូលពីសហគមន៍ដើម្បីមានគណនីសម្រាប់ "ការទូទាត់ក្រៅផ្លូវការ"
- បង្កើតទិន្នន័យអំពីការសន្សំថ្លៃដើម និងផលប៉ះពាល់សេដ្ឋកិច្ច នៃការផ្តល់សេវា SRHR រួមទាំងការចំណាយកើតចេញពី GBV ដែលដកហូតស្ត្រីចេញពីកម្លាំងពលកម្ម ការមានផ្ទៃពោះដោយអចេតនា ដែលធ្វើឱ្យក្មេងស្រីឈប់រៀន និងការចំណាយ កើតចេញពីការស្លាប់របស់មាតា ទារកទើបនឹងកើត និងការស្លាប់ទារកក្នុងផ្ទៃ ឬ ក្នុងពេលកើត
- តស៊ូមតិដើម្បីឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ MEF បង្កើតស្តង់ដាសម្រាប់ការធ្វើឱ្យកើនឡើងនៃការវិនិយោគទៅលើ SRHR ។

2) ហានិភ័យ និងធានារ៉ាប់រងសុខភាពសង្គម

- ដកបន្ទុកហិរញ្ញប្បទានឱ្យឆ្ងាយពីបុគ្គលជាពិសេសស្ត្រី និងកុមារីឆ្ពោះទៅរកយន្តការហិរញ្ញប្បទាន និងគម្រោងធានារ៉ាប់រងសុខភាពជាតិ ដោយប្រើប្រាស់ចំណូលពន្ធ ថវិការដ្ឋាភិបាល និងកម្មវិធីបង់ប្រាក់ជាមុន
- តស៊ូមតិឱ្យពង្រីកគម្រោងធានារ៉ាប់រងសុខភាពសាធារណៈ ដើម្បីគ្របដណ្តប់ដល់អ្នកផ្តល់សេវាឯកជនដែលមានការទទួលស្គាល់ ផ្តល់អាទិភាពដល់គ្រឹះស្ថានឯកជនដែលអាចគ្របដណ្តប់ដល់ប្រជាជន ដែលងាយរងគ្រោះ ដូចជាកម្មកររោងចក្រ ជនចំណាកស្រុក មនុស្សវ័យជំទង់ ...
- តស៊ូមតិដើម្បីធ្វើឱ្យសេវាពន្យារកំណើត ក្រោយពេលសម្រាល និងក្រោយពេលរំលូតកូនភ្លាមៗ អាចទូទាត់បានជាសេវាដោយឡែកមួយនៅក្រោមទាំង HEF និង NSSF

- តស៊ូមតិឱ្យដាក់បញ្ចូលសេវា SRHR គ្រប់ជ្រុងជ្រោយទៅក្នុងកញ្ចប់សេវាសំខាន់ៗដែលត្រូវគ្របដណ្តប់ដោយគម្រោងធានារ៉ាប់រងសុខភាព រួមមានការរំលូតកូន និងការពន្យារកំណើតក្រោយសម្រាល ដំងឺមហារីកមាត់ស្បូន ការព្យាបាលដោយប្រើ cryotherapy
- តាមរយៈការពិនិត្យឡើងវិញនាពេលខាងមុខ នៃ HEF ក្រោម H-EQIP II និងការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ នៃកញ្ចប់ HEF បង្កើតគោលការណ៍ណែនាំច្បាស់លាស់ដែលបញ្ជាក់ថាការរំលូតកូន (MA, MVA, PAC) អាចអនុញ្ញាតនៅក្រោម HEF
- ប្រាស្រ័យទាក់ទង និងបំភ្លឺដល់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ នូវអ្វីដែលត្រូវបានដាក់បញ្ចូលក្រោម HEF និងNSSF ដោយគូសបញ្ជាក់ពីសេវារំលូតកូនដែលគ្របដណ្តប់ដើម្បីដោះស្រាយព័ត៌មានមិនពិត
- ផ្សព្វផ្សាយព័ត៌មានអំពីកញ្ចប់អត្ថប្រយោជន៍របស់ HEF ដល់មូលដ្ឋានផ្តល់សេវា ដោយសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDDS) តាមរយៈ VSHG និងយន្តការ ដែលមានស្រាប់ផ្សេងទៀត
- គាំទ្រការអនុវត្តគោលនយោបាយ ប.ស.ស. ថ្មី ដែលដាក់បញ្ចូលបុគ្គលិកបម្រើការស៊ីវិល និងកម្មករ និងអង្គការក្រៅរដ្ឋាភិបាល ហើយតស៊ូមតិសម្រាប់ការពង្រីកការគ្របដណ្តប់បន្ថែមទៀត
- គាំទ្រការអនុវត្តកញ្ចប់សេវា '១០០០ ថ្ងៃ' ដែលគ្របដណ្តប់ដោយ HEF ដោយការផ្សព្វផ្សាយព័ត៌មានច្បាស់លាស់អំពីកម្មវិធីនេះដល់បុគ្គលិកសុខាភិបាល
- ដោយសហការជាមួយអ្នកពាក់ព័ន្ធផ្នែកគាំពារសង្គម គាំទ្រអន្តរាគមន៍ដើម្បីកែលម្អដំណើរការសម្រាប់ការចុះឈ្មោះ និងការទទួលបានអត្ថប្រយោជន៍ថែទាំសុខភាព រួមទាំងការចុះឈ្មោះសម្រាប់តម្រូវការបណ្ណក្រីក្រ (ODIP)
- អនុញ្ញាតឱ្យមានកិច្ចសហការរវាងបុគ្គលិកផ្នែកសុខាភិបាល និងនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល (DPHI) ដើម្បីពង្រឹងការប្រមូលទិន្នន័យ HEF រួមទាំងទិន្នន័យដែលពាក់ព័ន្ធនឹង SRHR
- បើកកិច្ចសហប្រតិបត្តិការរវាងវិស័យសុខាភិបាល និងមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព (NCHP) នៃMOH ដើម្បីពង្រឹងការផ្សព្វផ្សាយ និងការលើកកម្ពស់អត្ថប្រយោជន៍ នៃមូលនិធិសមធម៌សុខភាព និងដំណើរការចុះឈ្មោះ។

3) យុទ្ធសាស្ត្រទិញ

- អនុវត្តអនុសាសន៍ដែលមាននៅក្នុងក្របខ័ណ្ឌអនុវត្តកម្មវិធីជំរុញ PHC ទាក់ទងនឹង SRHR ទាំងតាមរយៈវិធីសាស្ត្រសហគមន៍ និងវិធីសាស្ត្រសេវាសុខភាព ដើម្បីសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល

- លើកទឹកចិត្តអ្នកស្វែងរកសេវាសុខភាពឱ្យស្វែងរកសេវា SRHR ពីមណ្ឌលសុខភាពមុនពេលទៅមន្ទីរពេទ្យដើម្បីកាត់បន្ថយថ្លៃសេវា ដោយចែករំលែកព័ត៌មានអំពីភាពអាចរកបាន នៃមណ្ឌលសុខភាពដែលផ្តល់សេវា SRHR និងជានាគុណភាព នៃការថែទាំនៅកម្រិតនោះ
- វិនិយោគលើការផ្សព្វផ្សាយ SRHR ការបង្ការ និងសកម្មភាពរកឃើញរហ័ស ដូច្នេះការចំណាយខ្ពស់ ដែលទាក់ទងនឹងការព្យាបាលនៅពេលក្រោយអាចត្រូវបានជៀសវាងនៅពេលណា ដែលអាចធ្វើទៅបាន
- ពិចារណាយន្តការផ្នែកខាងតម្រូវការ (ឧទាហរណ៍ ប័ណ្ណទូទាត់)
- ពិចារណា ការចរចាតម្លៃយោង
- ពិចារណាចំពោះក្របខណ្ឌហិរញ្ញប្បទាន នៃ PHC ដែលមានស្រាប់ និងយន្តការទូទាត់ដល់អ្នកផ្តល់សេវាដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា (ឧទាហរណ៍ HEF NSSF ថវិការទៅតាមប្រភេទ (line-item budget) ។ល។) ហើយពិចារណាគំរូសក្តានុពលផ្សេងទៀត។

## អាទិភាពជាយុទ្ធសាស្ត្រ ៧. ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានផលិតផល និងបច្ចេកវិទ្យាវេជ្ជសាស្ត្រ

### ប្រយោគបញ្ហា

ផលិតផល SRHR សម្រាប់ការសង្គ្រោះជីវិត និងមានតម្លៃទាប គឺមិនអាចរកបាន មិនអាចចូលប្រើបាន និងមានការប្រើប្រាស់តិចតួចនៅក្នុងគ្រឹះស្ថានផ្តល់សេវាមួយចំនួន និងនៅកម្រិតផ្សេងៗគ្នា។

### បញ្ហាប្រឈមសំខាន់ៗ

1) អភិបាលកិច្ច

ជាឧទាហរណ៍ ការពង្រីកការរំលូតកូនតាមវេជ្ជសាស្ត្រទៅគ្រឹះស្ថានផ្តល់សេវាជាច្រើនទៀត នឹងតម្រូវឱ្យដាក់បញ្ចូលថ្នាំដែលត្រូវការទៅក្នុងចង្វាក់ផ្គត់ផ្គង់ជាតិ។ ប្រព័ន្ធព័ត៌មានគ្រប់គ្រងភស្តុភារបច្ចុប្បន្ន (LMIS) មិនអនុញ្ញាតឱ្យមានការពិនិត្យមើលឡើងវិញឱ្យបានត្រឹមត្រូវនូវកម្រិតស្តុកនៅតាមទីតាំងគ្រឹះស្ថាន ស្រុកប្រតិបត្តិ (OD) និងថ្នាក់ជាតិ ដោយ NMCHC និងកម្មវិធីជាតិផ្សេងទៀតឡើយ ដែលនេះរារាំងដល់ការបែងចែកឱ្យបានឆាប់រហ័ស និងនាំឱ្យមានការដាច់ស្តុកទុកក្នុងករណីមួយចំនួន។ បញ្ជីឱសថសំខាន់ៗត្រូវបានធ្វើបច្ចុប្បន្នភាពនាពេលថ្មីៗនេះ ដើម្បីដាក់បញ្ចូលផលិតផលសង្គ្រោះជីវិត SRHR ជាផលិតផលមានសារៈសំខាន់ នៅគ្រប់កម្រិតនៃប្រព័ន្ធសុខាភិបាលដែលត្រូវការប្រើផលិតផលទាំងនេះ។ ការផ្គត់ផ្គង់នូវផលិតផលសង្គ្រោះជីវិតថ្មី និងផលិតផលសង្គ្រោះជីវិតដែលមិនបានប្រើប្រាស់ឱ្យអស់លទ្ធភាព គឺមិនមានជាប់លាប់នៅក្នុងប្រទេសកម្ពុជានោះទេ។

2) លទ្ធកម្ម

តម្លៃទំនិញរបស់ SRHR គឺមានតម្លៃថ្លៃ។ ទីផ្សារសម្រាប់ការទិញផលិតផលរំលូតកូនតាម វេជ្ជសាស្ត្រដែលមានតម្លៃសមរម្យ និងមានការធានាគុណភាពនៅក្នុងប្រទេសកម្ពុជា គឺមានកម្រិត ខណៈផលិតផល ដែលមិន

មានការធានាគុណភាពមួយចំនួន មានវត្តមាននៅលើទីផ្សារ។ អ្នកលក់រាយឯកជន លក់ទំនិញដែលមានគុណភាពខុសប្លែកគ្នា ជាមួយនឹងការត្រួតពិនិត្យ ឬការអនុវត្តបទប្បញ្ញត្តិតិចតួច ដែលនេះអាចគ្មានសុវត្ថិភាព។

3) ការអស់ស្តុក

ទោះបីជាក្រសួងសុខាភិបាលបានដាក់ប្រាក់ច្រើនជាង ២លានដុល្លារក្នុងមួយឆ្នាំដើម្បីទិញទំនិញ FP ក៏ដោយ ការដាច់ស្តុកទុកនៅតាមគ្រឹះស្ថានសុខាភិបាលមួយចំនួននៅតែកើតឡើង។ ការដាច់ស្តុកផលិតផល SRHR នៅគ្រឹះស្ថានចែកចាយសេវាកម្មមួយចំនួននាំឱ្យការថែទាំមិនត្រូវបានផ្តល់ឱ្យអ្នកដែលស្វែងរកសេវា ឬគេត្រូវចំណាយពីហោប៉ៅរបស់ពួកគេសម្រាប់ការថែទាំ។ ទោះបីជាមានការផ្តល់មូលនិធិសម្រាប់មេរោគអេដស៍ និងរោគស្វាយក៏ដោយ ការដាច់ស្តុកនូវឧបករណ៍ធ្វើតេស្តទ្វេសម្រាប់រកមេរោគអេដស៍ និងរោគស្វាយ ត្រូវបានរាយការណ៍ថាកើតមាននៅគ្រប់កម្រិតទាំងអស់។ ការផ្គត់ផ្គង់ផលិតផលដល់កម្រិតមណ្ឌលសុខភាព គឺមិនទាន់ពេលវេលា។ ការស្នើស្តុក គឺធ្វើមិនបានត្រឹមត្រូវ។

4) ឧបករណ៍តាមដាន និងថែទាំ

ឧបករណ៍ និងបរិក្ខារវេជ្ជសាស្ត្រ មិនត្រូវបានតាមដានដោយតម្លាភាព និងធ្វើបច្ចុប្បន្នភាពនៅពេលមិនដំណើរការ និងជំនួសនៅពេលត្រូវការនោះទេ ដោយសារកង្វះថវិកា និងការគ្រប់គ្រងនៅកម្រិតខ្ពស់។

**អន្តរាគមន៍ដែលបានស្នើឡើង៖**

1) ការគ្រប់គ្រង និងការសម្របសម្រួល៖

- បើកដំណើរការឡើងវិញនូវក្រុមការងារសន្តិសុខពន្យារកំណើត ដើម្បីធានាសុវត្ថិភាពទំនិញ SRHR(រួមទាំងថ្នាំសម្រាប់ FP ម្តាយ និងទារក) ដោយចូលរួមជាមួយឃ្លាំងឱសថកណ្តាល (CMS) នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង (DDF) មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) និងអង្គភាពផ្សេងទៀតដែលពាក់ព័ន្ធក្នុងលទ្ធកម្ម និងការចែកចាយ ដើម្បីពង្រឹងផែនការសកម្មភាព និងគណនេយ្យភាព
- គាំទ្រកិច្ចខិតខំប្រឹងប្រែងដើម្បីវាយតម្លៃ និងធ្វើឱ្យប្រសើរឡើងនូវខ្សែចង្វាក់ផ្គត់ផ្គង់និងចែកចាយទៅដល់អ្នកប្រើប្រាស់
- គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដឹកនាំដោយ DDF ដើម្បីពង្រឹង ឬកែលម្អ LMIS រួមមានការអនុវត្តល្អបំផុតក្នុងការប្រើប្រាស់ព័ត៌មាន និងបច្ចេកវិទ្យាទំនាក់ទំនងដែលបានធ្វើបច្ចុប្បន្នភាព (ICT) ដែលរួមមានការធានានូវសង្វាក់ នៃការផ្គត់ផ្គង់ត្រូវបានគ្រប់គ្រង និងការពារបានល្អរហូតផលិតផលទៅដល់ដៃគូអនុវត្ត និងអ្នកប្រើប្រាស់ (last mile assurance)
- ក្នុងករណីដែលមិនអាចចូលប្រើ LMIS បានពេញលេញ ការត្រួតពិនិត្យតាមដានការអស់ស្តុកនៃឱសថ និងសម្ភារ SRHR គឺផ្អែកលើរបាយការណ៍ ដែលចែករំលែកដោយ CMS
- រៀបចំផែនការលម្អិតសម្រាប់ណែនាំ និងបង្កើតតម្រូវការចំពោះផលិតផលសង្គ្រោះជីវិតថ្មី ឬផលិតផលដែលមិនទាន់បានប្រើឱ្យអស់សក្តានុពល សម្រាប់អ្នកដែលត្រូវការការថែទាំ

- ដាក់បញ្ចូលឱសថ ដែលត្រូវការ ដើម្បីធ្វើការរំលូតកូនតាមវេជ្ជសាស្ត្រទៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់សាធារណៈនៅកម្ពុជាក្នុងរយៈពេលមធ្យម
- កាត់បន្ថយបន្ទុករបស់គ្រឹះស្ថានផ្តល់សេវាក្នុងការគណនាដោយដៃនូវតម្រូវការ និងសំណើស្តុកតាមរយៈការផ្តល់ជំនួយការងារ ការគាំទ្រ ឧបករណ៍ឌីជីថលដែលធ្វើការគណនាដោយស្វ័យប្រវត្តិ។ល។

2) លទ្ធកម្ម

- កំណត់ស្តង់ដារសម្រាប់លទ្ធកម្មផលិតផលរំលូតកូនដោយវេជ្ជសាស្ត្រ និងទិញផលិតផលដែលមានការធានាគុណភាពតាមរយៈថវិកាសាធារណៈ
- អនុវត្តការវាយតម្លៃទៅលើការធានាគុណភាពទំនិញនៅក្នុងក្រុមហ៊ុនឯកជន ដែលលក់រាយ ផ្តល់ព័ត៌មាន និងការណែនាំដល់ពួកគេលើការធានាគុណភាព និងផ្តល់ការណែនាំអំពីជម្រើសលទ្ធកម្មផ្សេងៗ ដើម្បីអាចឱ្យពួកគេផលិតនូវផលិតផលដែលមានគុណភាព។

3) ការអស់ស្តុក

- អនុវត្តប្រព័ន្ធព្យាករណ៍ និងកំណត់បរិមាណដែលមានគុណភាពខ្ពស់ ដើម្បីកំណត់ទំនិញសម្រាប់ផែនការគ្រួសារ (FP) ដែលត្រូវការដើម្បីគ្របដណ្តប់តម្រូវការផែនការគ្រួសារទាំងអស់នៅក្នុងបរិបទ នៃការកើនឡើងតម្រូវការ និងបទពិសោធន៍វិជ្ជមានរបស់អ្នកប្រើប្រាស់
- ធ្វើឱ្យមានការចូលរួមពីថ្នាក់ក្រោមជាតិនៅក្នុងកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ដើម្បីបង្កើតដំណោះស្រាយដែលធ្វើឱ្យប្រសើរឡើងនូវផែនការ និងការគ្រប់គ្រងសន្តិសុខទំនិញ
- ពង្រឹងការប្រជុំប្រចាំខែរបស់ OD ស្តីអំពីស្តុក រួមទាំងការពិនិត្យឡើងវិញលើការអស់ស្តុក ផែនការសកម្មភាព តួនាទី និងការកំណត់ការទទួលខុសត្រូវ និងការតាមដាន
- ពង្រឹងជំនាញជុំវិញការព្យាករណ៍ និងការស្នើសុំស្តុក និងឧបករណ៍ SRHR នៅកម្រិតគ្រឹះស្ថានផ្តល់សេវា ស្រុកប្រតិបត្តិ (OD) និងមន្ទីរសុខាភិបាល (PHD) និង ជំនាញក្នុងការពិនិត្យមើលសំណើស្តុកដែល PHD/OD ទទួលបានពីថ្នាក់ក្រោម
- តស៊ូមតិឱ្យដាក់បញ្ចូលស្តុក SRHR លើសពីផលិតផលសម្រាប់ការធ្វើផែនការគ្រួសារ ទៅក្នុងស្តុកសំខាន់ៗ ដែលត្រូវបានវាយតម្លៃជាប្រចាំតាមរយៈយន្តការតាមទម្លាប់។

4) ឧបករណ៍តាមដាន និងថែទាំ

- កែលម្អការកត់ត្រា និងការរាយការណ៍អំពីឧបករណ៍ពាក់ព័ន្ធ SRHR នៅកម្រិតគ្រឹះស្ថានផ្តល់សេវា ដោយពង្រឹង ឬធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធ ការប្រើប្រាស់កម្មវិធីដែលបានធ្វើបច្ចុប្បន្នភាពភ្ជាប់វាទៅនឹង LMIS និងបណ្តុះបណ្តាលបុគ្គលិកពាក់ព័ន្ធគ្រប់កម្រិត។

## អាទិភាពជាយុទ្ធសាស្ត្រ ៨. លើកកម្ពស់ និងពង្រឹងទិន្នន័យសម្រាប់ការស្រាវជ្រាវ ការច្នៃប្រឌិត ការត្រួតពិនិត្យ និងការរៀនសូត្រ

### ប្រយោគបញ្ហា

គម្លាត នៃការរាយការណ៍ទិន្នន័យ និងគុណភាព ប្រព័ន្ធត្រួតពិនិត្យ និងសិក្សាមានកម្រិត និងការផ្សព្វផ្សាយមិនគ្រប់គ្រាន់ការស្រាវជ្រាវ និងការច្នៃប្រឌិត រារាំងប្រទេសកម្ពុជាពីការសម្រេចបាននូវលទ្ធផល SRHR ដែលប្រសើរឡើង។

### បញ្ហាប្រឈមសំខាន់ៗ

1) ការរាយការណ៍ទិន្នន័យ និងគុណភាព

